សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

6

# សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២

ស្រាវជ្រាវដោយ៖ | សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ ក. ឆាយ វិលីយ៉ា | បណ្ឌិត យឹម គិរី

ក. ភុល ស្រីម៉ុច

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ | ឆ្នាំចូលសិក្សា ២០១៨

ជំនាន់ទី២២ | ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ



នាងខ្ញុំទាំងពីររូបឈ្មោះ ភុល ស្រីម៉ុច និង ឆាយ វីលីយ៉ា ជានិស្សិតបរិញ្ញាប័ត្រនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណ និងសូមសម្តែងនូវកតញ្ញូតាធម៌ជូនចំពោះ៖

១. លោកឪពុក ភុល អេងស្រ៊ុន និងអ្នកម្តាយ យុគ សុខា

២. លោកឪពុក ឆាយ ប៊ុនឈាន និងអ្នកម្តាយ ឌីប ឌីណា

សូមលំឱនកាយថ្វាយបង្គំគោរព ដោយកិច្ចប្រណិបត្តន៍ និងសម្តែងនូវកិច្ចកតញ្ញូធម៌យ៉ាងជ្រាលជ្រៅជាទីបំផុតដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗ ប្រកបដោយព្រហ្មវិហារធម៌ជាពិសេសទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈថវិកា ស្មារតី កម្លាំងចិត្ត និងដំបូន្មានល្អៗ តាំងពីថ្នាក់បឋមសិក្សាមកដល់បច្ចុប្បន្ននេះ ដែលអនុញ្ញាតឱ្យកូនៗមានឱកាសក្នុងការទទួលបាននូវចំណេះដឹងដែលជាប្រទីប និងជាទ្រព្យធនដែលមិនចេះបាត់បង់ជារៀងរហូតដែលជាគុណូបការៈយ៉ាងអនេកប្បការពុំអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងទ្វេ។

**ឯកឧត្តមបណ្ឌិត លុយ ចន្ធា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោក-លោកស្រីព្រឹទ្ធបុរសរង ព្រមទាំងលោក-លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកសិក្សាទាំងអស់ ដែលបានខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្ត និងបានផ្តល់នូវចំណេះដឹង បទពិសោធន៍ និងបង្កនូវបរិយាកាសងាយស្រួលនានា ដើម្បីឱ្យយើងខ្ញុំទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើន រហូតឈានទៅបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ។

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ឃីម គិរី** ព្រមទាំងជាសាស្ត្រាចារ្យណែនាំដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ហើយបានលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្តមិនខ្លាចនឿយហត់ ដើម្បីជួយដឹកនាំ និងជំរុញក្នុងការសរសេរជាស្នាដៃនេះតាំងពីចាប់ផ្តើមរហូតដល់ការបញ្ចប់ជាស្ថាពរ ដែលនេះជាគុណូបការៈដ៏វិសេសវិសាល ដែលយើងខ្ញុំមិនអាចបំភ្លេចបាន។

ជាចុងក្រោយយើងខ្ញុំ សូមបួងសួងអស់បារមីនៃវត្ថុសក្តិសិទ្ធិទាំងពួង សូមប្រសិទ្ធិពរជ័យ សិរីមង្គលវិបុលសុខគ្រប់ប្រការជូនដល់អស់លោកអ្នកមានគុណទាំងឡាយ និងសូមជួយបីបាច់ថែរក្សាលោកអ្នកមានគុណឱ្យមានសុខភាពល្អ ព្រមទាំងសូមជូនពរឱ្យលោកជួបប្រទះនូវពុទ្ធទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា



យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២២ ដែលបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ បន្ទាប់ពីបានសិក្សាអស់រយៈពេល៤ឆ្នាំ កន្លងមកនេះយើងបានទទួលនូវចំណេះដឹងជាច្រើនពីសាស្ត្រាចារ្យទាំងឡាយ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ទោះបីជាព្រះរាជាណាចក្រកម្ពុជាបានជួបវិបត្តិនៃជំងឺកូវីដ១៩ក៏ដោយ។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាយតម្លៃ និងវាស់ស្ទង់ទៅលើចំណេះដឹងរបស់យើងខ្ញុំ ដែលបានសិក្សាកន្លងមកក្នុងរយៈពេល៤ឆ្នាំមកនេះ យើងខ្ញុំបានលើកយកនូវប្រធានបទមួយដែលមានចំណងជើងថា "**ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា**" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីសរសេរជាសារណាក្នុងការបញ្ចប់ការសិក្សា ។

មូលហេតុដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទនេះមកសរសេរសារណាដើម្បីបញ្ចប់ការសិក្សាព្រោះដោយមើលឃើញពីសារៈប្រយោជន៍យ៉ាងច្រើនអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមើលឃើញពីភាពស្មុគស្មាញនៃនីតិវិធីនីមួយៗដែលរំលេចឡើងដោយគុណសម្បត្តិ និងគុណវិបត្តិនៃដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ យើងខ្ញុំនឹងធ្វើការប្រៀបធៀបនូវនីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅព្រះរាជាណាចក្រកម្ពុជាផងដែរ។ តាមរយៈស្នាដៃនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អត្ថបទសារណាមួយនេះនឹងចូលរួមជាពិសេសក្នុងការផ្សព្វផ្សាយ និងជាជំនួយដល់ស្មារតីរបស់និស្សិត និងសម្រាប់អ្នកសិក្សាទូទៅ ជាពិសេសសម្រាប់សាមញ្ញជនដែលមានគោលបំណងចង់ស្វែងយល់ និងចង់សិក្សាស្រាវជ្រាវពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែស៊ីជម្រៅ។

ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លី ហើយម្យ៉ាងវិញទៀត ដោយសារតែចំណេះដឹងយើងខ្ញុំនូវមានកម្រិត យើងខ្ញុំជឿជាក់ថានឹងមានកំហុសដែលកើតមានឡើងដោយអចេតនាមួយចំនួនដែលក្នុងនោះមានដូចជា កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ និងភាពខ្វះចន្លោះមិនគ្រប់ជ្រុងជ្រោយតាមខ្លឹមសារច្បាប់ កើតមានក្នុងសារណានេះជាក់ជាពុំខាន។ យើងខ្ញុំរីករាយទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលំអនូវកំហុសឆ្គងពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិតទាំងឡាយ ដើម្បីបំពេញនូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដោយក្ដីសោមនស្សរីករាយ។

មាតិកា

សេចក្តីផ្តើម ........ ១

ជំពូកទី១

ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

១.១. ប្រវត្តិជាសាកលនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ ៦

**១.១.១ ប្រទេសអាមេរិក** ........ ៨

**១.១.២ ប្រទេសសិង្ហបុរី** ........ ១០

**១.១.៣ ដែនដីហុងកុង** ........ ១២

១.២ ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ........ ១៣

១.៣ ការវិវត្តន៍ដែលនាំឱ្យកម្ពុជាឆ្ពោះទៅកាន់ការដោះស្រាយវិវាទ ........ ១៤

១.៤ ការរួមចំណែកក្នុងការសម្រួលដល់យុត្តិធម៌ ........ ១៦

ជំពូកទី២

ដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

២.១ ការចរចា ........ ១៩

**២.១.១ និយមន័យ** ........ ១៩

**២.១.២ នីតិវិធីនៃការចរចា** ........ ២០

**២.១.៣ វិធីសាស្រ្តនៃការចរចា** ........ ២០

២.១.៣.១ វិធីសាស្រ្តនៃការចរចាឈ្នះ-ចាញ់ ........ ២០

២.១.៣.២ វិធីសាស្រ្តនៃការចរចាឈ្នះ-ឈ្នះ ........ ២១

**២.១.៤ ដំណាក់កាលនៃដំណើរការចរចា** ........ ២១

២.១.៤.១ ដំណាក់កាលត្រៀម ........ ២១

២.១.៤.២ ដំណាក់កាលផ្តើម ........ ២៣

២.១.៤.៣ ដំណាក់កាលព័ត៌មាន ........ ២៣

២.១.៤.៤ ដំណាក់កាលបែងចែក ឬផ្តែកលើផលប្រយោជន៍ ........ ២៤

២.១.៤.៥ ដំណាក់កាលបញ្ចប់ ........ ២៤

២.១.៤.៦ គុណសម្បត្តិ និងគុណវិបត្តិ ............ ២៥

២.២ ការផ្សះផ្សា ............ ២៧

**២.២.១ និយមន័យ ............ ២៧**

**២.២.២ លក្ខណៈពិសេសនៃការផ្សះផ្សា ............ ២៨**

**២.២.៣ នីតិវិធីនៃការផ្សះផ្សា ............ ២៨**

**២.២.៤ គុណសម្បត្តិ និងគុណវិបត្តិ ............ ៣០**

២.៣ សន្ធានកម្ម ............ ៣១

**២.៣.១ និយមន័យ ............ ៣១**

**២.៣.២ ភារកិច្ចរបស់សន្ធានការី ............ ៣២**

**២.៣.៣ នីតិវិធីនៃការធ្វើសន្ធានកម្ម ............ ៣២**

**២.៣.៤ ដំណើរការសន្ធានកម្ម ............ ៣៤**

២.៣.៤.១ ការផ្តួចផ្តើមសន្ធានកម្ម ............ ៣៥

២.៣.៤.២ ការជ្រើសរើសសន្ធានការី ............ ៣៦

២.៣.៤.៣ ការប្រជុំជាឯកជន ............ ៣៦

២.៣.៤.៤ ការបញ្ចប់សន្ធានកម្ម ............ ៣៧

**២.៣.៥ គុណសម្បត្តិ និងគុណវិបត្តិ ............ ៣៨**

២.៤ មជ្ឈត្តការ ............ ៤០

**២.៤.១ និយមន័យ ............ ៤១**

**២.៤.២ ដំណើរការមជ្ឈត្តការ ............ ៤១**

២.៤.២.១ វេទិការមជ្ឈត្តកម្ម ............ ៤១

២.៤.២.២ ទីកន្លែង និងភាសា ក្នុងដំណើរការមជ្ឈត្តការ ............ ៤២

២.៤.២.៣ វិធានស្តីពីនីតិវិធី ............ ៤២

២.៤.២.៤ ការកំណត់ច្បាប់ដែលគ្រប់គ្រងដំណើរការ....................................................៤២
២.៤.២.៥ ការដាក់ឯកសារជូនវេទិកាមជ្ឈត្តកម្ម........................................................ ៤៣
២.៤.២.៦ ការជូនដំណឹងគ្នាទៅវិញទៅមក................................................................ ៤៣
២.៤.២.៧ អ្នកជំនាញ...................................................................................... ៤៣
២.៤.២.៨ សវនាការមជ្ឈត្តការ...........................................................................៤៤

ជំពូកទី៣

ការប្រៀបធៀបពីដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

៣.១ ការប្រៀបធៀបការចរចា និងសន្ទានកម្ម ........................................................... ៤៤
៣.២ ការប្រៀបធៀបការចរចា និងការផ្សះផ្សា .............................................................. ៤៧
៣.៣ ការប្រៀបធៀប ការចរចា និងមជ្ឈត្តការ................................................................ ៤៩
៣.៤ ការប្រៀបធៀបការសន្ទានកម្ម និងការផ្សះផ្សា ...................................................... ៥១
៣.៥ ការប្រៀបធៀប មជ្ឈត្តការ និងសន្ទានកម្ម ..........................................................៥២
៣.៦ ការប្រៀបធៀប ការផ្សះផ្សា និងមជ្ឈត្តការ..........................................................៥៣
សេចក្តីសន្និដ្ឋាន ............................................................................................... ៥៦
អនុសាសន៍........................................................................................................ ៦០

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស មិនអាចរស់នៅតែម្នាក់ឯងបានទេ គឺគេតែងតែមានការប្រាស្រ័យទាក់ទងនឹងគ្នា មិនថាចាស់ ឬក៏ក្មេងឡើយ។ ការទំនាក់ទំនងទាំងនោះ ជួនកាលជាការផ្តល់នូវចំណងមិត្តភាពយូរអង្វែង ឬផ្តល់នូវផលប្រយោជន៍ស្មើគ្នា ប៉ុន្តែនៅក្នុងទំនាក់ទំនងខ្លះទៀតដែលមានភាគីម្ខាងមានប្រៀបជាងភាគីម្ខាងទៀត ដែលទំនាក់ទំនងបែបនេះវាបានបង្កឱ្យមានអតុល្យភាពនៃការប្រាស្រ័យទាក់ទងគ្នា ដែលជាហេតុបង្កជម្លោះជាមួយគ្នានោះ។ ជម្លោះនេះ បានបង្កឡើងដោយសារតែភាគីម្ខាងៗ មិនមានការអធ្យាស្រ័យគ្នាទៅវិញទៅមក ជួនកាលកំហុសតូចតាចតែប៉ុណ្ណោះតែភាគីម្នាក់ៗ មិនព្រមដោះស្រាយ គិតតែទាញត្រូវរៀងៗខ្លួនហើយក៏បង្កឱ្យមានជម្លោះកាន់តែរីករាលដាលធំឡើងៗ ជម្លោះនេះជាហេតុដែលធ្វើឱ្យគូភាគីមើលមុខគ្នាមិនចំហើយក៏ជាហេតុធ្វើឱ្យសង្គមមិនមានការរីកចម្រើនផងដែរ ព្រោះថាមនុស្សម្នាក់ៗគិតតែទំនាស់របស់ខ្លួន ប៉ុន្តែមិនគិតអំពីការរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ និងសង្គមជាតិមិនមានការរីកចម្រើននោះទេ តែនេះគ្រាន់ជាភាគដ៏តូចនៃប្រជាជនតែប៉ុណ្ណោះ។ ដូចនេះដើម្បីមានសាមគ្គីភាព និងការរស់នៅជាមួយគ្នារស់នៅប្រកបទៅដោយភាពសុខដុមរមនា ឬភាពសុខសាន្តនឹងគ្នា មនុស្សរស់នៅត្រូវចេះអធ្យាស្រ័យគ្នាទៅវិញទៅមក បើមានការលើសលោះពាក្យសម្តី ឬអ្វីៗផ្សេងទៀតដែលជារឿងតូចតាចមិនបង្ករឿងនោះរីករាលដាលធំទៅៗឡើយ។

ដោយសារតែមានការកើតឡើងនូវជម្លោះរវាងប្រជាពលរដ្ឋ ទើបរដ្ឋាភិបាលនៃប្រទេសនីមួយៗ ខិតខំស្វែងរកដំណោះស្រាយតាមរយៈវិធីផ្សេងៗ ក្នុងការដោះស្រាយនូវជម្លោះរបស់ប្រជាពលរដ្ឋ។ ដោយមានការដោះស្រាយទៅតាមប្រព័ន្ធតុលាការ ខ្លះដោះស្រាយក្រៅប្រព័ន្ធតុលាការ ដែលក្នុងនោះរួមមានការដោះស្រាយតាមរយៈការចរចា ការដោះស្រាយតាមរយៈការផ្សះផ្សា ការដោះស្រាយតាមរយៈសន្ធនាកម្ម និងការដោះស្រាយតាមរយៈមជ្ឈត្តកម្ម។ នៅព្រះរាជាណាចក្រកម្ពុជា មានការដោះស្រាយតាមរយៈប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការដែលភាគច្រើនហៅថា ការដោះស្រាយវិវាទក្រៅផ្លូវការ។ ចំពោះការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការមានលក្ខណៈចាប់បង្ខំភាគីវិវាទ ត្រូវតែអនុវត្តតាមសាលក្រម ឬសាលដីការបស់តុលាការ ប៉ុន្តែចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការវិញ គឺជាការដោះស្រាយដោយមានភាគីទីបីជាអ្នកជួយស្វែងរកដំណោះស្រាយជាមួយភាគីវិវាទ ហើយដែលភាគីទីបី ជាទូទៅពុំមានសិទ្ធិចាប់បង្ខំភាគីទាំងសងខាងដែលមានវិវាទឱ្យអនុវត្តតាមឡើយ។ ជាពិសេសនៅក្នុងការអនុវត្តជាក់ស្តែង តុលាការពុំអាចដោះស្រាយគ្រប់ប្រភេទរឿងក្តីទាំងអស់ដែលកើតនៅក្នុងសង្គមឡើយ ព្រោះមានរឿងក្តីជាច្រើនត្រូវបានភាគីវិវាទព្យាយាមដោះស្រាយនៅ

ក្រៅប្រព័ន្ធតុលាការតាមរយៈយន្តការដោះស្រាយវិវាទក្រៅផ្លូវការ និងតាមប្រពៃណី ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាលមួយចំនួន។ ជាការមួយដ៏ល្អប្រសើរ បើសិនជាវិវាទដែលកើតមាននៅក្នុងសង្គមត្រូវបានដោះស្រាយដោយសន្តិវិធី ដោយប្រើប្រាស់នីតិវិធីដែលអាចឱ្យភាគីទាំងសងខាងឈ្នះ ជាជាងដូចអ្វីដែលតុលាការសម្រេចដែលចាំបាច់ត្រូវមានភាគីឈ្នះ និងមានភាគីចាញ់នោះឡើយ។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

នៅក្នុងការដោះស្រាយក្នុងប្រព័ន្ធតុលាការសព្វថ្ងៃមានការចំណាយថវិការច្រើន ហើយមានរយៈពេលយូរក្នុងការដំណើរការរឿងក្ដីមាននីតិវិធីស្មុគស្មាញ ដែលធ្វើប្រជាពលរដ្ឋមានការប្រើប្រាស់សេវាយុត្តិធម៌ក្នុងការដោះស្រាយវិវាទរបស់ពួកគេ ចំណែកឯការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានការចំណាយថវិការតិចតួចជាងការដោះស្រាយតាមប្រព័ន្ធតុលាការ ហើយការដោះស្រាយមានដំណើរការលឿនទៀតផង។ ប៉ុន្តែការដោះស្រាយជម្លោះតាមរយៈតុលាការមានលក្ខណៈផ្លូវការជាង ដែលតម្រូវឱ្យភាគីវិវាទត្រូវតែអនុវត្តតាមការសម្រេចរបស់តុលាការ តែការដោះស្រាយវិវាទក្រៅប្រព័ន្ធមិនអាចចងភាគីវិវាទឱ្យអនុវត្តតាមការសម្រេចសេចក្ដីទាំងស្រុងនោះឡើយ។ ទាំងអស់នេះហើយសុទ្ធតែជាកង្វល់សម្រាប់ការដោះស្រាយវិវាទរបស់រដ្ឋជូនដល់ប្រជាពលរដ្ឋ។

- តើដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានប៉ុន្មានប្រភេទ ?
- តើដំណើរការទាំងនោះប្រព្រឹត្តទៅយ៉ាងដូចម្ដេច?
- តើដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានរចនាសម្ព័ន្ធដូចម្ដេច?
- តើដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមាននីតិវិធីអ្វីខ្លះ?
- តើរវាងស្ថាប័នតុលាការ និងមជ្ឈត្តការមានក្ខណៈខុសគ្នា ព្រមទាំងដូចគ្នាអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ជាគម្រោងសាកល្បងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ហើយការស្រាវជ្រាវនេះ ក៏មានបំណងចង់បង្ហាញអំពីចំណុចខ្លាំង និងចំណុចខ្សោយ ក៏ដូចជាការខ្វះខាត ឬព្រំដែននៃការដោះស្រាយវិវាទ ព្រមទាំងការបែងចែកនូវនីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធទាំងនោះ ដែលជាក់ស្ដែងកើតមានឡើងជារឿយៗ ដូចជាដើម្បីបង្ហាញពីភាពខុសគ្នា រវាងប្រព័ន្ធយុត្តិធម៌ផ្លូវការ និងមិនផ្លូវការជាដើម។ ចំពោះការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ គឺវាមានការជះឥទ្ធិពលមួយចំនួន ទៅដល់ប្រជាពលរដ្ឋក្រីក្រ ព្រោះពួកគាត់ខ្វះខាតនូវថវិការ សម្រាប់ដំណើរការរឿងក្ដី និងជាពិសេសអាចចំណាចពេលវេលាយូរ ហើយ

តុលាការមានរឿងក្តីច្រើន ដែលមិនអាចដំណើការនីតិវិធីឱ្យលឿនបាន ដែលបណ្តាលឱ្យរឿងក្តីនៅសល់ច្រើន ក្នុងមួយៗឆ្នាំ ដែលនាំឱ្យមានការពន្យាពេល ឬយឺតយ៉ាវក្នុងការដោះស្រាយរឿងក្តីនៅតុលាការ។ ក្នុងការអនុវត្ត ជាក់ស្តែងតុលាការដោះស្រាយរឿងក្តីតែចំនួនប៉ុណ្ណោះ ហើយមានវិវាទជាច្រើនលើសលុប ត្រូវបានដោះស្រាយ សម្រុះសម្រួលនៅក្រៅប្រព័ន្ធតុលាការ តាមរយៈការដោះស្រាយវិវាទផ្សេងៗ ជាពិសេសនៅតាមទីជនបទមួយ ចំនួន។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងនេះក្តី ក៏នៅមានកិច្ចការជាច្រើនទៀតដែលរាជរដ្ឋាភិបាលត្រូវធ្វើ រួមមានដូចជា ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការកសាងសមត្ថភាពរបស់មន្ត្រីក្នុងការអនុវត្ត ច្បាប់ជាអាទិ៍។ ភាពចាំបាច់ក្នុងការពង្រឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា គឺជា គោលបំណងមួយ ក្នុងការដោះស្រាយវិវាទដោយសន្តិវិធី តាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅប្រទេសកម្ពុជាតាមការសម្រុះសម្រួលវិវាទ ហើយគោលបំណងនេះ ជាហេតុផលយ៉ាងសំខាន់ដែលគាំទ្រ ដល់គំនិតក្នុងការបង្កើត និងពង្រឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា។ ការដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថា ជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ មួយ ដ៏សំខាន់ ដើម្បីលើកស្ទួយសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋ និងជាពិសេសសម្រាប់ជនក្រីក្រ។ ទោះបីជាមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក៏ការធ្វើការកែទម្រង់យន្តការដោះស្រាយវិវាទនេះ ក៏វានៅតែមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដើម្បីឆ្លើយតបចំពោះតម្រូវការយុត្តិធម៌ក្នុងសង្គមរបស់ប្រជាពលរដ្ឋ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានកម្រិតត្រឹមតែការដោះស្រាយវិវាទតូចតាចតែប៉ុណ្ណោះ ហើយ ដែលមិនតម្រូវឱ្យធ្វើការដោះស្រាយលើរឿងក្តីព្រហ្មទណ្ឌឡើយ កត្តានេះបានទាមទារឱ្យមានការបង្កើតប្រព័ន្ធ ត្រួតពិនិត្យ និងតុល្យភាពអំណាចដ៏មានប្រសិទ្ធិភាពមួយដើម្បីជៀសវាងនូវការរំលោភអំណាច។

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដោយសារតែការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានសារៈសំខាន់ចំពោះប្រទេសកម្ពុជា ទើប រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុក្ខដាក់យ៉ាងខ្លាំង ដែលបានបង្កើតឱ្យមាននូវស្ថាប័នមួយចំនួនដើម្បីទទួល ការដោះស្រាយវិវាទ ជាពិសេសការដោះស្រាយតែវិវាទ ពាណិជ្ជកម្ម ដែលទាមទារឱ្យមានយន្តការនៃការដោះ ស្រាយវិវាទមួយ ដែលមានលក្ខណៈពិសេសពីការដោះស្រាយផ្សេងទៀត ដូចជា វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ និង វិវាទផ្នែករដ្ឋបាលជាដើម។ យ៉ាងណាមិញ នៅក្នុងបរិបទថ្មីស្របតាមការរីកចម្រើនរបស់ប្រទេសជាតិ និងពិភព

លោក ព្រះរាជាណាចក្រកម្ពុជាបានធ្វើសមាហរណកម្ម និងទំនើបកម្មនៃប្រព័ន្ធច្បាប់របស់ខ្លួន ដើម្បីដើរឱ្យទាន់ការរីកចម្រើននៃវិស័យពាណិជ្ជកម្ម និងការវិវត្តនរបស់ក្នុងសង្គម។

ក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានប្រើនូវវិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោម៖

ក. ប្រភពឯកសារ ឬទិន្នន័យរួមមាន

- ឯកសារច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដូចជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេចរាជរដ្ឋាភិបាល សេចក្តីប្រកាសរបស់ព្រះរាជាណាចក្រកម្ពុជា
- គេហទំព័រផ្លូវការរបស់មជ្ឈត្តកម្មនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថាប័នពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- អត្ថបទស្រាវជ្រាវដែលទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបណ្តាប្រទេសមួយចំនួន
- បណ្ណាល័យនីតិសាស្ត្រ និងបណ្ណាល័យអេឡិចត្រូនិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សៀវភៅបរទេស ដែលជាឯកសារអេឡិចត្រូនិកពាក់ព័ន្ធនឹងដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ខ. វិធីសាស្ត្រប្រមូលទិន្នន័យ

- ការអាន និងការសិក្សាស្វែងយល់ដោយសំយោគឯកសារផ្លូវច្បាប់ផ្សេងៗ
- ការចូលរួមសិក្ខាសាលា ស្តីពីការណែនាំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ការចូលរួមសិក្សាស្វែងយល់ពីវគ្គបណ្តុះបណ្តាលជំនាញមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ការសិក្សាស្រាវជ្រាវឯកសារទិន្នន័យពីបណ្ណាល័យនីតិសាស្ត្រ បណ្ណាល័យអេឡិចត្រូនិក និងគេហទំព័រដែលអាចទុកចិត្តបានផ្សេងៗទៀត។
- ការសិក្សាស្រាវជ្រាវដោយផ្អែកតាមការសង្កេតផ្ទាល់ខ្លួន ព្រមទាំងការផ្តល់មតិពីរាមច្បង

## ៥. សារប្រយោជន៍នៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ នឹងផ្តល់នូវប្រយោជន៍ជាច្រើនដល់និស្សិត ក៏ដូចជាអ្នកសិក្សាទូទៅ ដើម្បីពង្រីកនូវចំណេះដឹងរបស់ខ្លួនពាក់ព័ន្ធទៅ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាយន្តការដែលអាចអនុញ្ញាតឱ្យភាគីនៃវិវាទ ដោះស្រាយវិវាទរបស់

ខ្លួនតាមរបៀបខុសៗគ្នាដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ។ លើសនេះទៀត វិវាទដែលបានដោះស្រាយក្រៅប្រព័ន្ធតុលាការមានភាពឆាប់រហ័ស និងមានការចំណាយតិចជាងដំណើរការនៅក្នុងតុលាការ។ តាមរយៈការស្រាវជ្រាវនេះ បានប្រមូលនូវពត៌មានជាច្រើនដែលជាប្រយោជន៍ ដែលធ្វើឱ្យអ្នកសិក្សាទូទៅ ក៏ដូចជាសិស្ស និងនិស្សិតដែលធ្វើការស្រាវជ្រាវក្រោយៗទៀត ដើម្បីធ្វើការស្វែងយល់ និងយកទៅពិចារណាដើម្បីជាប្រយោជន៍តាមការតម្រូវរបស់ខ្លួន។ លើសពីនេះទៀត សារណានេះ ក៏ជាប្រភពព័ត៌មានទូទៅសម្រាប់សារធារណជន ជាពិសេសនិស្សិតផ្នែកនីតិសាស្ត្រ ដែលមានបំណងចង់ក្លាយជាអ្នកចរចា សន្ធានការី និងមជ្ឈត្តករឲ្យបានយល់កាន់តែច្បាស់ពីនីតិវិធី និងដំណើរការនៃការដោះស្រាយវិវាទនីមួយៗផងដែរ។

សារណានេះនឹងធ្វើ ការប្រៀបធៀប ដែលបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងដំណើរការទាំងបួននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផ្តល់អនុសាសន៍មួយចំនួនក្នុងការចូលរួមចំណែក ដើម្បីអភិវឌ្ឍនូវវិធីសាស្ត្រក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅព្រះរាជាណាចក្រកម្ពុជា។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សាស្តីអំពី ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជានេះ ត្រូវបានបែងចែក ជាបីជំពូកដូចខាងក្រោម៖

- **ជំពូកទី១ ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា** ដែលនៅក្នុងជំពូកទី១នេះ និងធ្វើការបកស្រាយអំពីប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាអន្តរជាតិ រួមជាមួយនឹងប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការវិវត្តន៍នៃការដោះស្រាយវិវាទនេះនៅព្រះរាជាណាចក្រកម្ពុជា ។
- **ជំពូកទី២ ដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា** ក្នុងជំពូកនេះ នឹងធ្វើការបកស្រាយផ្តោតសំខាន់ទៅលើដំណើរការទាំងបួននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រួមមានដូចជា ការចរចារ ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តកម្ម។
- **ជំពូកទី៣ ការប្រៀបធៀបពីដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** នៅក្នុងជំពូកទី៣ ដែលជាជំពូកចុងក្រោយ នឹងធ្វើការបកស្រាយ និងធ្វើការប្រៀបធៀបពីដំណើរការទាំងបួន ។

# ជំពូកទី១
# ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

# ជំពូកទី១

# ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

នៅក្នុងជំពូកនេះយើងនឹងធ្វើការសិក្សាទៅលើ ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាអន្តរជាតិ ជាពិសេសប្រវត្តិ និងការវិវត្តន៍នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដោយយើងដឹងហើយថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពិតជាមានប្រជាប្រិយភាពទូទាំងពិភពលោក ពោលគឺការដោះស្រាយក្រៅប្រព័ន្ធតុលាការ ជាការដោះស្រាយវិវាទដោយមិនឆ្លងកាត់នីតិវិធីរបស់តុលាការ ឬជាជម្រើសមួយរបស់គូភាគីនៃវិវាទ ដែលបានព្រមព្រៀង ឬឯកភាពគ្នា ធ្វើការដោះស្រាយវិវាទដោយមិនចាំបាច់ឆ្លងកាត់តុលាការ ហើយទាមទារឱ្យគូភាគីនៃវិវាទត្រូវតែព្យាយាមដោះស្រាយគ្នាដោយសន្តិវិធីដើម្បីទទួលបានជោគជ័យ។

## ១.១. ប្រវត្តិ នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាអន្តរជាតិ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនមែនទើបកើតមាននាពេលបច្ចុប្បន្ននោះឡើយ គឺមានតាំងពីយូរណាស់មកហើយ ទាំងនៅបណ្តាប្រទេសលើសកលលោក ក៏ដូចជានៅប្រទេសកម្ពុជា។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសំដៅលើយន្តការនានា ដែលគូភាគីនៃវិវាទធ្វើការដោះស្រាយដោយមិនពឹងផ្អែកលើនីតិវិធីសវនាការរបស់តុលាការទេ។

យន្តការ និងទ្រឹស្តីនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះ កើតមានឡើងៈ

- នៅព្រះរាជាណាចក្រកម្ពុជាកើតមានតាំងពីឆ្នាំ១៩៨០ មុនគ្រឹស្តសករាជ្យ
- បន្ទាប់មកកើតមាននៅប្រទេសអ៊ីស្រាអែល ៩៦០ឆ្នាំ មុនគ្រឹស្តសករាជ្យ
- ប្រទេសឥណ្ឌា ៥០០ ឆ្នាំមុនគ្រឹស្តសករាជ្យ
- ប្រទេសក្រិច ៤០០ ឆ្នាំមុនគ្រឹស្តសករាជ្យ
- សៀវភៅរបស់ អារីស្តូត ៣០០ ឆ្នាំមុនគ្រឹស្តសករាជ្យ
- ប្រទេសចិន ១០០ មុនគ្រឹស្តសករាជ្យ អាណាចក្រ)Zhoo) ។[1]

[1] Lewis, Melissa, and McCrimmon, Les, "The Role of ADR Process in the Criminal Justice System: A view from Australia" (Paper presented at At ALRAESA Conference, Entebbe, Uganda 4-8 September, 2005) p.1.

ដោយឡែក ចំពោះប្រទេសកម្ពុជាយើងមានតាមរយៈរឿងព្រេង និងទំនៀមទំលាប់តាម ភូមិ ឃុំ ឬចាស់ទុំនៅក្នុងតំបន់មួយចំនួនជាដើម។ ក្នុងសម័យសង្គមរាស្ត្រនិយម យើងមានច្បាប់មួយបានយកលំនាំតាមប្រទេសបារាំង ក្រោយមានក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដោយមានការកែប្រែជាបន្តបន្ទាប់រហូតដល់ឆ្នាំ១៩៦១ ហើយចុងក្រោយប្រទេសកម្ពុជាបានចុះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងការអនុវត្តសេចក្តីសំរេចរបស់មជ្ឈត្តការបរទេស ដែលរដ្ឋសភាបានផ្តល់សច្ចាប័នក្នុងឆ្នាំ២០០២។ [2] ក្រោយឆ្នាំ១៩៧៩ ប្រទេសកម្ពុជាមានកិច្ចព្រមព្រៀងមួយក្នុងឆ្នាំ១៩៩១ គឺជាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលចែងពីការដោះស្រាយវិវាទរវាងភាគីជម្លោះទាំងបួន។ នៅឆ្នាំ១៩៩៧ កម្ពុជាមាន ច្បាប់ស្តីពីការងារក៏មានចែងអំពីយន្តការនៃការដោះស្រាយវិវាទការងារមានទាំងសន្ទានកម្ម និងមជ្ឈត្តការ ហើយបង្កើតបាននូវក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងាររួម និងបង្កើតនូវអធិការកិច្ចការងារ ដើម្បីដោះស្រាយវិវាទការងារ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០១ និងចាប់ផ្តើមដំណើរការនៅឆ្នាំ២០០៣។ បើយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ មានការបង្កើតគណៈកម្មការសុរិយោដី មានតួនាទីផ្សះផ្សាវិវាទដីធ្លី ហើយនៅឆ្នាំ២០០៦ បានបង្កើតនូវអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី។ នៅក្នុងឆ្នាំ២០០៦ នោះផងដែរ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហើយបានឈានទៅបង្កើតមជ្ឈមណ្ឌលជាតិមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ដោយឡែកនៅឆ្នាំ២០០២ រដ្ឋសភា ក៏បានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិ២ គឺ៖

- សន្ធិសញ្ញាសហប្រជាជាតិស្តីពីការទទួលស្គាល់ការដោះស្រាយក្រៅប្រព័ន្ធតុលាការ
- សន្ធិសញ្ញាសហប្រជាជាតិស្តីពីការដោះស្រាយវិវាទរវាងអ្នកវិនិយោគិនបរទេស ជាមួយនឹងរដ្ឋាភិបាល (សន្ធិសញ្ញានេះធ្វើនៅទីក្រុងវ៉ាស៊ីនតោនឆ្នាំ១៩៦៩) ។[3]

យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ គេមានការប្រើប្រាស់មិនមែនតែសម្រាប់ផ្នែកពាណិជ្ជកម្មទេ គេក៏បានប្រើសម្រាប់ការដោះស្រាយវិវាទរវាងរដ្ឋ និងរដ្ឋផងដែរ តាមរយៈការចរចា សន្ទានកម្ម ឬការផ្សះផ្សាមុននឹងប្តឹងទៅតុលាការអន្តរជាតិ។[4]

---

[2] Phallack, Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform", in The Introduction to Cambodian Law, (Konrad-Adenauer-Stiftung, 2012) p. 12.

[3] Goldberg, Jordan, Alternative Dispute Resolution" Peperdine Dispute Resolution Law Journal, 2014, pp. 2-4.

[4] ដូចលេខ ៣

ការដោះស្រាយដោយមិនពឹងផ្អែកលើតុលាការនេះហើយ ត្រូវបានគេស្គាល់ថា **ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** (Alternative Dispute Resolution (ADR)។ ការបង្កើតយន្តការនេះឡើង គឺក្នុងគោលបំណងជួយសម្រួលដល់ដំណើរការដោះស្រាយវិវាទឱ្យកាន់តែមានភាពងាយស្រួល ឆាប់រហ័ស និងចំណាយថវិការតិច។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ អាចត្រូវបានគេយកទៅប្រើក្នុងការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ទាំងវិវាទនៅថ្នាក់ជាតិ និងវិវាទថ្នាក់ក្រោមជាតិដែលមានដូចជា វិវាទការងារ ពាណិជ្ជកម្ម អាជីវកម្ម ឬគ្រួសារ ជាដើម។

១១ ប្រទេសអាមេរិក.១.

នៅសហរដ្ឋអាមេរិកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កើតមាននៅដើមសម័យអាណានិគមរបស់ហូឡង់ និងអង់គ្លេស។ ដោយ "ពួកអាណានិគម ជឿជាក់ថា មេធាវីបានគំរាមកំហែងដល់ភាពសុខដុមរមនារបស់សាសនាគ្រិស្តរបស់ពួកគេ ទើបពួកគេជៀសវាងក្នុងការពឹងពាក់មេធាវី និងប្រើប្រាស់ប្រព័ន្ធតុលាការដោយប្រយ័ត្នប្រយែង ហើយងាកមកចូលចិត្តប្រើដំណើរការសម្របសម្រួលរបស់ពួកគេ ដើម្បីដោះស្រាយជម្លោះក្នុងសហគមន៍"។[5] នៅពេលដែលមានការខ្វែងគំនិតគ្នាកើតឡើង ស្ថាប័នបុរសនៃសហគមន៍នឹងស្តាប់ការទាមទារ កត់ត្រាកំហុស វាយតម្លៃការខូចខាត និងធានាថាភាគីទាំងពីរបានផ្សះផ្សាគ្នាទៅវិញទៅមក។ ខណៈពេលដែល ការដោះស្រាយវិវាទក្រៅប្រព័ន្ធមានសារៈសំខាន់ចំពោះការអភិវឌ្ឍន៍នៅក្នុងសហរដ្ឋអាមេរិកតែបែរជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនបានទទួលការរៀបចំឱ្យទៅជាស្ថាប័ន ដែលមានលក្ខណៈជាផ្លូវការទេ រហូតដល់ចុងសតវត្សទី១៩។[6] ភ្នាក់ងារសម្រុះសម្រួលពិសេស ដូចជាក្រុមប្រឹក្សាសម្របសម្រួល និងការផ្សះផ្សាសម្រាប់ការងារផ្លូវដែក និងសេវាសម្របសម្រួល និងការផ្សះផ្សាសហព័ន្ធ ដែលនៅតែដំណើរការរហូតមកដល់សព្វថ្ងៃនេះ ដែលវាត្រូវបានគេបង្កើតឡើង ក្នុងគោលបំណងដើម្បីធ្វើការចរចាទាក់ទងនឹងវិវាទការងារ។ នៅដំណាក់កាលនៃការអភិវឌ្ឍន៍ ការដោះស្រាយវិវាទទាំងនេះ ត្រូវបានគេយល់ថាភាគតិចវាជាជម្រើសសម្រាប់ដោះស្រាយវិវាទ និងភាគច្រើនវាគឺជាឧបករណ៍ ដែលត្រូវបានគេយកទៅប្រើប្រាស់ដើម្បីជៀសវាងភាពចលាចល កូដកម្ម និងការរំខានផ្នែកសេដ្ឋកិច្ច។ នៅដើមសតវត្សទី២០ រដ្ឋនានារបស់សហរដ្ឋអាចមេរិកបានចាប់ផ្តើមទទួលយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហើយចាត់ទុកថាជាប្រព័ន្ធ ជម្រើសនៃការដោះស្រាយវិវាទ។ ក្នុងទស្សវត្សរ៍ឆ្នាំ១៩២០ រដ្ឋជាច្រើនបានអនុម័តច្បាប់មជ្ឈត្តកម្មទំនើប ហើយសភាបានអនុម័តច្បាប់សហព័ន្ធ

---

[5] MICHAEL MCMANUS "Brief History of Alternative Dispute Resolution in the United States | Cadmus Journal."

[6] Christine Cervenak, "alternative dispute resolution practitioners Journal", 1987, p.1

មួយ គឺច្បាប់អាជ្ញាកណ្តាលសហព័ន្ធ។[7] ច្បាប់ទាំងនេះ បានធ្វើឱ្យប្រសើរឡើងនៃមជ្ឈត្តកម្មរបស់សហរដ្ឋអាមេរិក ដោយសារៈ

- ការបង្កើតកិច្ចព្រមព្រៀងដើម្បីដោះស្រាយវិវាទនាពេលអនាគតដោយស្របច្បាប់ និងអាចអនុវត្តបាន និងអាចដកហូតវិញបាន លុះត្រាតែកិច្ចសន្យាណាមួយអាចត្រូវបានលុបចោល
- ការបិទតុលាការទៅភាគីនៃកិច្ចព្រមព្រៀងអាជ្ញាកណ្តាល ដោយតម្រូវឱ្យពួកគេគោរពតាមកិច្ចព្រមព្រៀងរបស់ពួកគេ
- ការផ្តល់សិទ្ធិឱ្យតុលាការអនុវត្តការសម្រេចអាជ្ញាកណ្តាល និង
- ការផ្តល់សិទ្ធិឱ្យតុលាការចាត់តាំងអាជ្ញាកណ្តាល ហើយបើមិនដូច្នេះទេ ត្រូវពន្លឿនអាជ្ញាកណ្តាល នៅពេលដែលភាគីម្ខាងបានបរាជ័យក្នុងការបន្តទៅមុខជាមួយនឹងកិច្ចព្រមព្រៀងដើម្បីធ្វើអាជ្ញាកណ្តាល។[8]

ទាំងអស់នេះ គឺជាការវិវឌ្ឍវិជ្ជមានរួមជាមួយនឹងការច្នៃប្រឌិតទាំងនេះ ហើយដែលអនុញ្ញាតឱ្យតុលាការអនុវត្តនូវដំណោះស្រាយតាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

នៅឆ្នាំ១៩២៦ សមាគមមជ្ឈត្តកម្មអាមេរិកត្រូវបានបង្កើតឡើងដើម្បីផ្តល់ការណែនាំដល់អាជ្ញាកណ្តាល និងភាគីអំពីវិធីសាស្ត្រនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។ ពេញមួយសតវត្សរ៍ទី២០ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទទួលបានប្រជាប្រិយភាពសម្រាប់ការដោះស្រាយវិវាទ។ នៅកម្រិតរដ្ឋាភិបាល រដ្ឋ និងរដ្ឋសហព័ន្ធបានចាប់ផ្តើមប្រើប្រាស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងកម្មវិធីមួយចំនួន។ ឧទាហរណ៍ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ នាយកដ្ឋានសុខាភិបាល អប់រំ និងសុខុមាលភាព ត្រូវបានចាត់តាំងជាអ្នកគ្រប់គ្រងនៃច្បាប់ស្តីពីការរើសអើងអាយុ ដើម្បីដោះស្រាយការទាមទារអំពីការរើសអើងអាយុនៅកន្លែងធ្វើការរបស់សហព័ន្ធ។ ដើម្បីជួយសម្រួលដល់ការដោះស្រាយឱ្យបានឆាប់រហ័ស នាយកដ្ឋានបានចុះឈ្មោះជំនួយពីការផ្សះផ្សាសហព័ន្ធដើម្បីសម្រុះសម្រួលពាក្យបណ្តឹងក្រោមច្បាប់ថ្មី ដែលជាដំណើរការមួយដែលបានក្លាយទៅជាទម្លាប់នៅក្នុងឆ្នាំ១៩៧៩។ នៅ ទសវត្សរ៍ឆ្នាំ១៩៨០ អ្នកសិក្សាចាប់អារម្មណ៍យ៉ាងខ្លាំង

---

7 Christine Cervenak, "alternative dispute resolution practitioners Journal", 1987, p.102

8 MICHAEL MCMANUS "Brief History of Alternative Dispute Resolution in the United States | Cadmus Journal."

ពីអ្នកជំនាញផ្នែកច្បាប់ ក្នុងការប្រើប្រាស់ដើម្បីធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅក្នុងវិស័យផ្សេងៗគ្នា។ សាកលវិទ្យាល័យ និងសាលាច្បាប់បានចាប់ផ្ដើមណែនាំវគ្គសិក្សា ព្រមទាំងសញ្ញាបត្រជំនាញទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នាសតវត្សទី២១ ការស្ទង់មតិរបស់គណៈមេធាវីអាមេរិក បានបង្ហាញថាសាលាច្បាប់ភាគច្រើនបានរៀបចំនូវកម្មវិធីមួយចំនួន ដែលទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រួមទាំងរៀបចំឱ្យមានការប្រកួតប្រជែងស្ដីពីការដោះស្រាយវិវាទនេះ ក្រៅកម្មវិធីសិក្សា ផងដែរ។[9] សព្វថ្ងៃនេះ មជ្ឈត្តកម្ម មាននៅគ្រប់កម្រិតនៃវិជ្ជាជីវៈច្បាប់របស់សហរដ្ឋអាមេរិក ក្រុមហ៊ុនច្បាប់តែងតែជួលចៅក្រមចូលនិវត្តន៍ ឬមេធាវីដែលមានការបញ្ជាក់ពីសមាគមមជ្ឈត្តកម្មអាមេរិក ជាមួយនឹងជំនាញក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីផ្ដល់សេវាសម្របសម្រួល ការចរចា និងអាជ្ញាកណ្ដាលដល់វិវាទបុគ្គល និងវិវាទក្នុងធ្វើអាជីវកម្ម។ នៅ នៅក្នុងឆ្នាំ១៩៩៥ មានការបោះផ្សាយបញ្ជីរាយនាមដែលបានធ្វើបច្ចុប្បន្នភាព នៃអ្នកអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្ដល់លទ្ធភាពឱ្យបុគ្គលកាន់តែច្រើន ចូលទៅប្រើប្រាស់នូវសេវាកម្មដែលទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ដូច្នេះបានជាគេកំណត់ថាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាប្រព័ន្ធច្បាប់មួយដែលមានភាពរឹងមាំនៅក្នុងសហរដ្ឋអាមេរិក។

១.១.២ ប្រទេសសិង្ហបុរី

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ សិង្ហបុរីបានធ្វើឱ្យប្រសើរឡើងនូវការចូលទៅប្រើប្រាស់ជម្រើសនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗ ដើម្បីដោះស្រាយជម្លោះដោយភាពងាយស្រួល ភាគីអាចប្រើប្រាស់ជម្រើសនៃការដោះស្រាយវិវាទនេះ ជំនួសឱ្យការប្រើប្រាស់ការដោះស្រាយវិវាទតាមតុលាការ ឬមជ្ឈត្តកម្ម ហើយរដ្ឋាភិបាលសិង្ហបុរីក៏បានលើកទឹកចិត្ត ឱ្យគូវិវាទជ្រើសយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នេះដែរ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជំនួសការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ ដែលកំពុងតែរីកចម្រើនយ៉ាងឆាប់រហ័សនៅប្រទេសសិង្ហបុរី ជាមធ្យោបាយដោះស្រាយវិវាទផ្សេងៗ ចាប់តាំងពីជម្លោះក្នុងស្រុក និងសង្គម រហូតដល់ជម្លោះផ្លូវច្បាប់ឆ្លងព្រំដែន ដែលមានទ្រង់ទ្រាយធំ។[10] វិធីសាស្ត្រនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មួយចំនួនដូចជា ការចរចា ការសម្រុះសម្រួល និងមជ្ឈត្តកម្ម ជាជម្រើសចម្បងដែលអនុវត្តនៅក្នុងប្រទេសសិង្ហបុរី ហើយត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាព និង

[9] MICHAEL MCMANUS “Brief History of Alternative Dispute Resolution in the United States ׀ Cadmus Journal.”

[10] Rajoo, Sundra “The article traces the development arbitraiton in Singapore including legislative changes.” (2020), p.2

សន្សំសំចៃ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានចាប់ផ្តើមជាបណ្តោះអាសន្ននៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ នៅពេលដែលរដ្ឋាភិបាលបានចាត់ទុកប្រទេសសិង្ហបុរីថា ជាមជ្ឈមណ្ឌលដោះស្រាយវិវាទដ៏សំខាន់ ដោយយកបានដាក់ទុនលើទីតាំងភូមិសាស្ត្ររបស់ខ្លួន ក៏ដូចជាគោលដៅរបស់ខ្លួនក្នុងការអភិវឌ្ឍប្រទេសសិង្ហបុរីទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ជាពិសេសគោលដៅច្បាស់លាស់មួយទៀតគឺ ការពារប្រទេសសិង្ហបុរីពីការក្លាយទៅជាសង្គមដែលសំបូរវិវាទ។[11] ការសម្រុះសម្រួលត្រូវបានគេជ្រើសរើសថា ស្របតាមប្រពៃណី និងវប្បធម៌អាស៊ីរបស់សិង្ហបុរី។ នៅឆ្នាំ១៩៨៦ សិង្ហបុរីបានយល់ព្រមលើអនុសញ្ញាញូវយ៉កឆ្នាំ១៩៥៨ ស្តីពីការទទួលស្គាល់ និងការអនុវត្តនៃសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលបរទេស។ នៅក្រោមអនុសញ្ញានេះ រដ្ឋដែលចុះកិច្ចព្រមព្រៀងជាសមាជិក តម្រូវឱ្យទទួលស្គាល់ និងអនុវត្តសេចក្តីសម្រេចអាជ្ញាកណ្តាលដែលបានធ្វើឡើងនៅក្នុងរដ្ឋសមាជិកមួយផ្សេងទៀត។ នៅក្នុងមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី គេប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងការទាក់ទងគ្នាជាលាយលក្ខណ៍អក្សរ និងប្រើប្រាស់នៅក្នុងពេលសវនាការផងដែរ។ ប៉ុន្តែភាគីមានសេរីភាពក្នុងការប្រើប្រាស់ភាសាដទៃទៀត នៅក្នុងពេលសវនាការ ដែលសេវាក្នុងការបកប្រែភាសាទាំងក្នុងការសរសេរ និងសវនាការផ្ទាល់មាត់ គឺមានគ្រប់គ្រាន់សម្រាប់ភាគី។[12]

នៅក្នុងមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី ភាគីអាចប្រើប្រាស់មេធាវីនៅក្នុងស្រុក ឬបរទេសបាន ហើយភាគីក៏មានសិទ្ធិក្នុងការជ្រើសរើសនូវនីតិវិធីរបស់ខ្លួន។ ជាទូទៅភាគី នៅក្នុងមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី ផ្តល់ភស្តុតាងដោយផ្ទាល់តាមរយៈការស្បថជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដទៃទៀត ហើយភាគីក៏អាចសួរសាក្សីរបស់ភាគីម្ខាងទៀតបានដែរ។ មជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរីព្យាយាមធានាថា ជម្លោះត្រូវតែដោះស្រាយឱ្យទាន់ពេលវេលាតាមវិធានដែលបានចែង ដូចនេះ មជ្ឈត្តករត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួនក្នុងរយៈពេល៤៥ថ្ងៃ ក្រោយពីបានធ្វើសវនាការរួចមក។ យោងតាមមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី ជាធម្មតាជម្លោះមួយអាចត្រូវដោះស្រាយ ក្នុងរយៈពេល៦ខែ គិតចាប់ពីពេលចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្មមក។ ជាពិសេសទៅទៀត តុលាការរបស់ប្រទេសសិង្ហបុរី បានខិតខំប្រឹងប្រែងដឹកនាំឱ្យគូវិវាទជ្រើសយកការដោះស្រាយវិវាទក្រៅប្រព័ន្ធ ដើម្បីលើកទឹកចិត្តដល់ការទទួលយកការដោះស្រាយ

[11] Chan, Gary Kok Yew, “The Alternative Resolution Depute in Singapore” (2020), p.19

[12] Chan, Gary Kok Yew, "The Alternative Resolution Depute in Singapore" (2020), p.21

វិវាទក្រៅប្រព័ន្ធតុលាការរបស់មេធាវី និងអតិថិជនរបស់ពួកគេថា ជាវិធីដែលមានភាពច្បាស់លាស់ លឿនជាងមុន និងថោកជាងក្នុងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។

១.១.៣ ដែនដីហុងកុង

ចាប់តាំងពីឆ្នាំ១៩៨៥ ជាមួយនឹងការបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិហុងកុង (HKIAC) ច្បាប់អាជ្ញាកណ្តាលហុងកុង និងការអនុវត្ត បានឆ្លងកាត់ការផ្លាស់ប្តូរសំខាន់ៗជាច្រើន។ នៅដើមសតវត្សរ៍ទី១៩ ហុងកុងជាដែនដីមានប្រព័ន្ធច្បាប់រីកចម្រើនបំផុតមួយ សម្រាប់មជ្ឈត្តកម្មនៅលើពិភពលោក។ មជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិហុងកុង គឺជាមជ្ឈមណ្ឌលមួយដែលមានជំនាញ និងការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ ហើយក៏ជាសហគមន៍មជ្ឈត្តកម្មដ៏រស់រវើក រួមជាមួយនឹងមជ្ឈត្តករដែលមានចំណេះដឹង និងបទពិសោធន៍ ជាពិសេសមានទីតាំងល្អនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ឥឡូវនេះទោះបីហុងកុងជាផ្នែកមួយនៃប្រទេសចិន ប៉ុន្តែជាមួយនឹងប្រព័ន្ធច្បាប់គឺដាច់ដោយឡែក នៅក្រោមគំនិតនៃ "ប្រទេសមួយ ប្រព័ន្ធពីរ" មានឱកាសជាច្រើនសម្រាប់ការបន្តរីកចម្រើនរបស់ហុងកុងក្នុងនាមជាមជ្ឈត្តកម្មក្នុងតំបន់ និងអន្តរជាតិ ។ ពេញមួយប្រវត្តិសាស្ត្រអាណានិគមរបស់ខ្លួន ហុងកុង បានអនុវត្តតាមច្បាប់អាជ្ញាកណ្តាលនៅក្នុងប្រទេសអង់គ្លេស តែទោះជាយ៉ាងណាក៏ដោយជាមួយនឹងការអនុម័តច្បាប់គំរូ UNCITRAL ក្នុងឆ្នាំ១៩៩០ ហុងកុងបានចាប់ផ្តើមដើរលើផ្លូវឯករាជ្យជាងមុន។ ហុងកុងមានប្រព័ន្ធច្បាប់ពីរសម្រាប់មជ្ឈត្តកម្ម ដែលមួយសម្រាប់មជ្ឈត្តកម្មក្នុងស្រុក មួយទៀតសម្រាប់មជ្ឈត្តកម្មអន្តរជាតិដែនដីហុងកុង។[13]

មជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិក្រុងហុងកុង ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៥។ មជ្ឈមណ្ឌលមជ្ឈត្តកម្មនេះ ត្រូវបានផ្តត់ផ្គង់ថវិការដោយសហគមន៍អាជីវកម្មក្រុងហុងកុង និងដោយរដ្ឋាភិបាល។ ដំណើរការក្តីនៅក្នុងនៃមជ្ឈត្តកម្មអន្តរជាតិនៃមជ្ឈមណ្ឌលមជ្ឈត្តកម្មហុងកុង ត្រូវបានគ្រប់គ្រងដោយវិធានមជ្ឈត្តកម្ម UNCITRAL។ គូវិវាទដែលជ្រើសយកការ ដំណើរការក្តីនៅមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិក្រុងហុងកុង អាចប្រើភាសាណាមួយដែលពួកគេចង់ប្រើ ដោយហេតុថាមិនមានលក្ខខណ្ឌបង្ខំអំពីភាសានោះទេ ហើយភាគីវិវាទក៏អាចជ្រើសរើសមជ្ឈត្តករណាម្នាក់ដែលខ្លួនចង់បាន ឬជឿទុកចិត្ត បានផងដែរ។ ប៉ុន្តែប្រសិនបើមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិក្រុងហុងកុងមានអំណាចជ្រើសរើសមជ្ឈត្តករ នោះមជ្ឈមណ្ឌលមជ្ឈត្តកម្មនេះនឹង

[13] Philip J. McConnaughay, "Arbitration in Hong Kong" (2012), p.1

ជ្រើសរើសមជ្ឈត្តករម្នាក់ ក្នុងចំណោមគណៈមជ្ឈត្តកររបស់ខ្លួន ដោយមជ្ឈត្តករនោះត្រូវយកថ្លៃឈ្នួលសមរម្យ។ តាមនីតិវិធីមជ្ឈត្តកម្មនៃមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិក្រុងហុងកុង សាក្សីអាចផ្តល់កសិណ "ដោយផ្ទាល់" ទោះដោយផ្ទាល់មាត់ក្តី ឬជាលាយលក្ខណ៍អក្សរក្តី។ កសិណសាក្សីដោយផ្ទាល់ ជាកសិណដើមរបស់សាក្សីណាម្នាក់ ដែលបានផ្តល់ជូនតាមការស្នើសុំរបស់ភាគីវិវាទ ដែលសាក្សីនោះធ្វើកសិណឱ្យ។ ចំពោះមជ្ឈត្តវិនិច្ឆ័យទម្រង់តូច ការធ្វើកសិណដោយផ្ទាល់ជាញឹកញាប់ គឺធ្វើឡើងដោយផ្ទាល់មាត់។ ប៉ុន្តែចំពោះមជ្ឈត្តវិនិច្ឆ័យទម្រង់ធំ ជាធម្មតាភាគីត្រូវបានតម្រូវឱ្យផ្តល់សេក្តីថ្លែងការកសិណសាក្សីជាលាយលក្ខណ៍អក្សរជាធម្មតាការសាកសួរសាក្សីភាគីម្ខាងទៀតអាចអនុញ្ញាតឱ្យធ្វើបាន ។[14]

១.២ ប្រវត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានអាយុកាលជាយូរណាស់មកហើយក្នុងប្រទេសកម្ពុជា។[15] ការដោះស្រាយជម្លោះប្រភេទនេះ គឺជាយន្តការដែលប្រជាជនប្រើប្រាស់ជាជម្រើស ដើម្បីដោះស្រាយជម្លោះនៅក្រៅប្រព័ន្ធយុត្តាធិការរបស់តុលាការ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានចាប់ផ្តើម ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ ព្រមទាំងទទួលបាននូវប្រជាប្រិយភាពចាប់ពីពេលនោះមក។ ការដោះស្រាយជម្លោះប្រភេទនេះ គឺត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយរឿងគ្រួសារ ជម្លោះជាមួយអ្នកជិតខាង ក៏ដូចជាជម្លោះពាក់ព័ន្ធនឹងបរិស្ថាន ពាណិជ្ជកម្ម និងការងារ ជាអាទិ៍។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ មានជាច្រើនទម្រង់ ហើយទម្រង់ដែលត្រូវបានគេស្គាល់ជាទូទៅតាមរយៈមជ្ឈត្តកម្ម ការចរចា ការផ្សះផ្សា និងសន្ធានកម្ម។ មូលហេតុដែលនាំឲ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធនេះគឺ ទាក់ទងនឹងការចំណាយថវិកា និងពេលវេលាច្រើនសម្រាប់រឿងក្តីនៅតុលាការ។[16] នេះមានន័យថា ពេលដែលសំណុំរឿងនៅតុលាការត្រូវចំណាយពេលយូរ ការចំណាយសម្រាប់មេធាវី និងសេវាតុលាការក៏កាន់តែខ្ពស់ដែរ។ ក្រៅពីការចំណាយពេលវេលា និងថវិការ ការកកស្ទះសំណុំរឿងនៅតុលាការ ក៏ជាកត្តាដែលជំរុញឱ្យមានការប្រើប្រាស់នូវយន្តការ

[14] "Arbitration and its development in Malaysia.", (2008), p.4

[15] Phallack kong, "overview of the Cambodia legal and judicial system and recent efforts at legal and judicial reform", in the introduction to Cambodia law, (Konrad-Adenauer-stiftung, 2012) p.12

[16] មេធាវី ស៊ីវីន ផ៉ែម អូស្ទើរមីឡ័ែ សៀវភៅសិក្សាស្តីពីទស្សនានសំខាន់ៗ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា ទំព័រ.៦៦ បោះពុម្ពឆ្នាំ២០១០

ដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការដែរ។ ជារឿយៗ គេតែងសង្កេតឃើញថា ប្រជាជនដោះស្រាយជម្លោះរបស់ពួកគេដោយផ្អែកទៅលើយន្តការប្រពៃណី និងវប្បធម៌ក្នុងសហគមន៍របស់ខ្លួន។ ការអនុវត្តនេះត្រូវបានគេហៅថាជា "ការសម្របសម្រួល ឬការផ្សះផ្សា" ឧទាហរណ៍ការដោះស្រាយដោយចាស់ទុំនៅក្នុងស្រុក ឬដោយប្រធានភូមិជាដើម។ ទស្សនៈនេះមានន័យថា បុគ្គល ឬក្រុមមនុស្សនៅក្នុងភូមិ ធ្វើការជាមួយគ្នាដើម្បីឆ្លើយតបទៅនឹងបញ្ហា ដូចជាការធ្វើកិច្ចការប្រចាំថ្ងៃដោយមានការសហការ)គ្នាល្អមួយហើយនឹងការ (ចងក្រងជាគ្រួសារតូចមួយ។[17] រចនាសម្ព័ន្ធសង្គមនេះ ផ្តោតសំខាន់ដូចគ្នាទៅលើសុវត្ថិភាពរបស់សមាជិកនីមួយៗ ដែលជាលក្ខណៈប្រពៃណី បងប្អូន ឬអ្នកជិតខាងដែលមានទំនាក់ទំនងជិតដិត ហើយជាបុគ្គលទីមួយដែលភាគីវិវាទពឹងឱ្យមកជួយដោះស្រាយជម្លោះមុននឹងមានភាគីទីបីដែលជាជនឯករាជ្យមកជួយ។ តួអង្គសំខាន់ដែលដើរតួនាទីជាភាគីទីបី នៅក្នុងការសម្របសម្រួលជាចាស់ទុំ ប្រធានភូមិ ព្រះសង្ឃ អាចារ្យ និងមនុស្សសំខាន់ ឬបុគ្គលល្បីដែលជាភាគីទុកចិត្តដោយមានចាស់ទុំ ព្រះសង្ឃ និងអាចារ្យ។ ពួកគាត់បានប្រើប្រាស់បទពិសោធន៍ និងចំណេះដឹងពីប្រពៃណី ដំបូន្មានរបស់ព្រះពុទ្ធនៅក្នុងការណែនាំបង្រៀនមនុស្សដែលមានវិវាទគ្រួសារ និងវិវាទពាក់ព័ន្ធនឹងដីធ្លី ប៉ុន្តែ នៅពេលជម្លោះមានភាពធ្ងន់ធ្ងរ នោះនឹងត្រូវបញ្ជូនទៅប្រធានភូមិ។[18] ប្រធានភូមិដែលមានការរៀនសូត្រ ចំណេះដឹងផ្អែកលើប្រពៃណី និងដំបូន្មានព្រះពុទ្ធក្នុងការផ្តល់នូវដំណោះស្រាយ ចំណែកឯប្រធានភូមិដែលមិនបានរៀនសូត្រផ្តល់នូវដំណោះស្រាយដោយផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន។ មុនឆ្នាំ១៩៧០ ព្រះមហាក្សត្រក៏ដើរតួនាទីជាភាគីទីបីដែរ ព្រោះព្រះអង្គធ្វើព្រះរាជសវនាការ ដែលប្រជាជនអាចយកជម្លោះរបស់ខ្លួនថ្វាយព្រះមហាក្សត្រជួយដោះស្រាយ។[19]

១.៣ ការវិវត្តន៍ដែលនាំឱ្យកម្ពុជាឆ្ពោះទៅកាន់ការដោះស្រាយវិវាទ

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវកំណែទម្រង់ប្រព័ន្ធតុលាការ ដោយបង្កើតនូវស្ថាប័នមានសមត្ថកិច្ចជាច្រើនដូចជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងឆ្នាំ១៩៩៩ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងឆ្នាំ២០០២។ គណៈរដ្ឋមន្ត្រីក៏បានធ្វើការអនុម័តទៅ

---

[17] Luco, Fabienne, "Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices.", (UNECSO 2002.) pp. 16-17.

[18] Hughes, "An investigation of Conflict Management in Cambodian Villages: A review of the literature with Suggestions for Future Research", p. 12.

[19] YRIGOYEN FAJARDO, Kong, and Phan, Pathways to Justice: "Access to Justice with a focus on the poor, women and indigenous peoples.", p.1.

លើយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅក្នុងឆ្នាំ២០០៣ ព្រមទាំងផែនការសកម្មភាពនៅក្នុងឆ្នាំ២០០៥។[20] គោលបំណងនៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌ និងតុលាការជាការបង្កើតនូវស្ថាប័នដែលមានកិត្យានុពល ស្ថេរភាពច្បាប់ និងយុត្តិធម៌ប្រកាន់ភ្ជាប់នូវគោលការណ៍សិទ្ធិបុគ្គល នីតិរដ្ឋ និងភាពចែកដាច់ពីគ្នានៃអំណាចនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ ដែលនេះគឺជួយជំរុញដល់វិស័យឯកជនដើម្បីទទួលបាននូវភាពរីកចម្រើនសេដ្ឋកិច្ច។ ដើម្បីទទួលបាននូវភាពជោគជ័យក្នុងការអនុវត្តនូវគោលបំណងនេះ គោលដៅយុទ្ធសាស្ត្រប្រាំពីរត្រូវបានបង្កើតដែលក្នុងនោះ ការណែនាំនូវយុទ្ធសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជា គោលចំណែក ឯផែនការណ៍សកម្មភាពមានគោលបំណង ស៊ើបអង្កេត បង្កើត និងពង្រឹងវិធីផ្សេងៗនៃការដោះស្រាយវិវាទក្រៅតុលាការ និងការដោះស្រាយវិវាទបែបប្រពៃណី។

មានមូលហេតុជាច្រើន ដែលជំរុញឱ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទក្រៅផ្លូវតុលាការដោយក្នុងនោះមានដូចជា បញ្ហាទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាជនក្រីក្រ រួមទាំងក្រុមជនដែលងាយរងគ្រោះមានប្រមាណ៨០ភាគរយនៃប្រជាជនកម្ពុជាសរុប ១៣,៤លាននាក់ (ឆ្នាំ២០០៨) គឺជាអ្នករស់នៅជនបទ ហើយជម្លោះតែងតែកើតឡើងចំពោះពួកគេភាគច្រើនជាជម្លោះរវាងបុគ្គល និងបុគ្គល ដែលភាគច្រើនប៉ះពាល់ទៅដល់ អ្នកក្រីក្រ ស្ត្រី និងជនជាតិភាគតិច។ ជម្លោះទាំងនោះច្រើនកើតឡើងក្នុងមូលដ្ឋាន ហើយទាក់ទងនឹងបញ្ហាហិង្សាលើស្ត្រី ដីធ្លី និងព្រហ្មទណ្ឌ។ ប្រជាជននៅតាមតំបន់ជនបទយល់ឃើញថា ការធ្វើដំណើរទៅតុលាការមានចម្ងាយឆ្ងាយ ចំណាយថវិកា ព្រមទាំងពេលវេលាច្រើន និងមាននីតិវិធីស្មុគស្មាញ។ មូលហេតុទាំងនេះហើយ ទើបជំរុញឱ្យប្រជាជនមិនប្រើប្រាស់ប្រព័ន្ធតុលាការនៅក្នុងការដោះស្រាយវិវាទបញ្ហានេះ មួយវិញទៀតក៏អាចដោយសារមកពីការកកស្ទះសំណុំរឿង និងកង្វះខាតនូវធនធានមនុស្សនៅតុលាការ។ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងយុត្តិធម៌របស់រាជរដ្ឋាភិបាលហាក់បីដូចជាផ្តោតសំខាន់ទៅលើមូលហេតុដែលថា តុលាការមិនគួរដោះស្រាយគ្រប់ជម្លោះដែលកើតឡើងនោះទេ ហើយដំណោះស្រាយក្រៅប្រព័ន្ធតុលាការគួរតែត្រូវបានយកចិត្តទុកដាក់។[21]

១.៤ ការរួមចំណែកក្នុងការសម្រួលដល់យុត្តិធម៌

[20] រាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងឆ្នាំ (១៩៩៩) និងព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ក្នុងឆ្នាំ (២០០២)។

[21] Luco, Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices, p. 31.

ច្បាប់ជាច្រើនត្រូវបានអនុម័ត ដើម្បីជំរុញឱ្យមានដំណើរការប្រើប្រាស់ប្រព័ន្ធវិធានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងឆ្នាំ២០០១ ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ បានអនុម័តដោយផ្តល់តួនាទីឱ្យរដ្ឋបាលឃុំសម្រាប់លើកស្ទួយតួនាទីដោះស្រាយជម្លោះរវាងប្រជាពលរដ្ឋ។ បន្ថែមលើច្បាប់ខាងលើ មាត្រា៤៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានបង្កើតនូវគណៈកម្មការដោះស្រាយវិវាទដីធ្លី ដោយមានភារកិច្ចចម្បងដោះស្រាយនូវជម្លោះរបស់ប្រជាពលរដ្ឋទាក់ទងនឹងដី ដែលមិនទាន់ចុះបញ្ជីដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ។ ប្រសិនបើគណៈកម្មការនេះ មិនអាចរកនូវដំណោះស្រាយសម្រាប់ភាគីជម្លោះនេះអាចនឹងត្រូវបញ្ជូនទៅតុលាការដើម្បីដោះស្រាយ។ [22] សម្រាប់វិវាទការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីការងារត្រូវបានបង្កើតឡើង ដោយសេចក្តីប្រកាសលេខ ០៩៩ នៅក្នុងខែមេសា ឆ្នាំ២០០៤។ ដើម្បីក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាក៏បានយល់ព្រមបង្កើតនូវច្បាប់ថ្មីជាច្រើន ដោយការប្តេជ្ញាពង្រឹងបទដ្ឋាននៃបទបញ្ញត្តិសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៦ ដោយកំណត់នូវក្របខណ្ឌសម្រាប់មជ្ឈត្តកម្មឯកជននៅក្នុងការដោះស្រាយជម្លោះពាណិជ្ជកម្មដោយអនុវត្តតាមបទដ្ឋានអន្តរជាតិ។[23] មុនការអនុម័តនូវច្បាប់ពាណិជ្ជកម្ម កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស (NewYork Convention on the Recognition and Enforcement of Foreign Arbitral Awards)។ នៅក្នុងឆ្នាំ១៩៦០ ស្ថិតនៅក្រោមអនុសញ្ញានេះប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេស ប៉ុន្តែហាក់មានភាពមិនច្បាស់លាស់ ថាតើមានការអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេស ហើយឬនៅ។ នៅក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចុះហត្ថលេខាទៅលើអនុសញ្ញាស្តីពីការដោះស្រាយវិវាទទាក់ទងនឹងការវិនិយោគ (Convention on the Settlement of Investment Disputes: ICSID) ប៉ុន្តែសភាមិនទាន់ផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះនៅឡើយទេ។[24]

---

[22] អនុក្រឹត្យស្តីពីវិមជ្ឈការនៃតួនាទី មុខងារ និងអំណាចដល់ក្រុមប្រឹក្សាឃុំ (២០០២) មាត្រា ៦១

[23] អនុក្រឹត្យលេខ ៤៧ អនក្រ.បក (ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២) 'ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី'។ នីតិវិធីត្រូវបានបញ្ជាក់ដោយប្រកាសលេខ ១១២ ដនស/បរក (ថ្ងៃទី 21 ខែសីហា ឆ្នាំ 2002) "ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី"។

[24] Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform" p. 14.

ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក៏បានអនុញ្ញាតឱ្យមានការសម្របសម្រួលទាំងនៅក្នុង និងនៅក្រៅតុលាការផងដែរ ទោះបីជាភាគីបានដាក់បណ្ដឹងទៅតុលាការហើយក៏ដោយ។ មាត្រា៩៧ បានចែងថាតុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្ដឹងនោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។ មាត្រា២២០ បានកំណត់ថា ការផ្សះផ្សាអាចធ្វើនៅក្រៅតុលាការក៏បាន។ បរិបទផ្នែកច្បាប់នេះ មានតួនាទីយ៉ាងសំខាន់នៅក្នុងការទទួលស្គាល់ពីសារៈសំខាន់នៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការនៅស្ទើរគ្រប់វិស័យ។

# ជំពូកទី២
# ដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

# ជំពូកទី២

## ដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

ជំពូកនេះ នឹងធ្វើកាបកស្រាយពីដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាទាំងបួនប្រភេទ ដែលរួមមាន ការចរចា ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តកម្ម។ នៅក្នុងជំពូកនេះ ក៏នឹងសិក្សាអំពីនីតិវិធីនីមួយៗ ព្រមទាំងលើកឡើងនូវគុណសម្បត្តិ និងគុណវិបត្តិនៃដំណើរការនៃការដោះស្រាយវិវាទនេះ។

២១ ការចរចា.

២១ និយមន័យ.១.

ការចរចា គឺជាវិធីដែលមនុស្សពីរនាក់ ឬក៏មួយក្រុម ប្រើប្រាស់ដើម្បីទទួលបាននូវអ្វីដែលពួកគេចង់បានពីភាគីម្នាក់ទៀត។ ទម្រង់នេះមានលក្ខណៈសាមញ្ញក្នុងការដោះស្រាយវិវាទរបស់មនុស្ស និងត្រូវបានប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃនៅក្នុងទំនាក់ទំនងគ្រប់ប្រភេទ។ ពេលខ្លះអ្នកចរចាមិនបានដឹងថាខ្លួនកំពុងតែធ្វើការចរចានោះទេ ជាទូទៅការចរចាអាចធ្វើបានតាមវិធីសាស្ត្រជាច្រើន ដូចជាលក្ខណៈផ្លូវការ ឬជាលក្ខណៈមិនផ្លូវការ។ ការចរចា ជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទ ដែលគេឃើញមានទាំងក្នុងប្រទេសប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) និងប្រព័ន្ធច្បាប់អង់គ្លេស (Common Law)។ មនុស្សអាចធ្វើការចរចាបាន ទោះបីជាគ្មានវិវាទក៏ដោយ ជាក់ស្តែងមនុស្សអាចធ្វើការចរចាគ្នាអំពីតម្លៃ ដូចជាការលក់ទិញសម្ភារៈប្រើប្រាស់ ឬម្ហូបអាហារ ជាដើម។ ច្បាប់ប្រទេសកម្ពុជាគាំទ្រឱ្យមានការចរចា ដូចជាក្រមនីតិរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាបានធ្វើការលើកចិត្តឱ្យមានការស្រុះស្រួលគ្នាតាម ការចរចារវាងភាគី។[25]

២១..២ នីតិវិធីនៃការចរចា

[25] **ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា**, រាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជាទំព័រ៥២៩៦, ៥៣៣៦, មាត្រា៩៧ (ឆ្នាំ២០០៦) (" តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។") និងមាត្រា១០៤ ("នៅក្នុងនីតិវីធិត្រៀមសម្រាប់ការទាញរកហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាមុនសិន...") អំណឹះនេះតទៅហៅកាត់ថា"ក.នរ-ព.ក"]។ តាមមាត្រាទាំងនេះ តុលាការអាចលើកទឹកចិត្តឱ្យភាគីវិវាទធ្វើការចចារ ឬអាចដើរតួនាទីសកម្មជាងនេះ ដោយក្នុងករណីណាមួយក៏ដោយ កិច្ចអន្តរាគមន៍របស់តុលាការគឺអាចធ្វើឡើងក្នុងរូបភាពជាសន្ធានការី។

ការចរចា គឺជានីតិវិធីដំបូងក្នុងការដោះស្រាយបញ្ហាវិវាទក្រៅប្រព័ន្ធតុលាការ មុនភាគីសម្រេចចិត្តជ្រើសរើសនូវការដោះស្រាយវិវាទតាមរយៈនីតិវិធីដទៃផ្សេងទៀត។ ការចរចា អាចធ្វើឡើងក្នុងគោលបំណងជួយដល់បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងការចរចា ទោះបីការចរចាដើម្បីខ្លួនឯង ឬក្នុងនាមជួយអ្នកដទៃក៏ដោយ ក៏សុទ្ធតែដើម្បីស្វែងរកនូវដំណោះស្រាយរួមមួយ ដែលមានមូលហេតុសមស្របអាចទទួលយកបាន។ ម្យ៉ាងវិញទៀតការចរចា ជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនោះភាគីទាំងអស់បានជូននូវសំណើរ ឬពិចារណាលើសំណើរផ្សេងៗ រហូតដល់សំណើរណាមួយត្រូវបានធ្វើឡើងនឹងទទួលយក។[26]

ការចរចា អាចធ្វើឡើងតាមរយៈនីតិវិធីច្រើនយ៉ាងដូចជា៖

- ការចរចាផ្ទាល់មាត់
- ការចរចាអាចជាលាយលក្ខណ៍អក្សរ អាចធ្វើឡើងដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងរបស់ភាគីតាមបែបធម្មតា ឬលក្ខណៈជាផ្លូវការដូចជាការចរចាដែលធ្វើឡើងតាមរយៈសំបុត្រ។

### ២.១.៣ វិធីសាស្ត្រនៃការចរចា

#### ២.១.៣.១ វិធីសាស្ត្រនៃការចរចាឈ្នះ-ចាញ់

នៅក្នុងកាចរចា ភាគីអាចសន្មតថា មានមូលដ្ឋាន ជាក់លាក់នៅក្នុងការចរចា ដែលពួកគេត្រូវធ្វើការបែងចែករវាងគ្នា នៅក្នុងអំឡុងពេលនៃការចរចា មានន័យថា ភាគីនៃវិវាទបានកំណត់អំពីគោលជំហររៀងៗខ្លួន ថាចំនួនទឹកប្រាក់ប៉ុន្មានដែលខ្លួនអាចទទួលយកបាន ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងបញ្ចប់វិវាទ។ ប្រសិនបើភាគីម្ខាងទទួលបានកាន់តែច្រើន ភាគីម្ខាងទៀតទទួលបានកាន់តែតិច នៅក្នុងអំឡុងពេលចរចា ភាគីវិវាទកំណត់ពីជំហរខ្លួនឯង ដោយភាគីចុងចម្លើយដឹងអំពីចំនួនអតិបរមា ដែលខ្លួនមានឆន្ទៈក្នុងការបង់ ហើយភាគីរងគ្រោះដឹងអំពីចំនួនអប្បបរមា ដែលខ្លួនមានឆន្ទៈក្នុងការទទួលយក។

ឧទាហរណ៍ ភាគីម្ខាងអាចអះអាងថា ខ្លួនមានរបួសដោយសាររថយន្តដែលបើកបរដោយភាគីម្ខាងទៀត ដោយភាគីរងគ្រោះអាចមានរបួសដែលមានតម្លៃជាទឹកប្រាក់ចំនួន១០០០ដុល្លារអាមេរិក។ នៅពេលភាគីទាំងពីរចរចាតាមបែបបែងចែក ពួកគេប្រកាន់ជំហររៀងខ្លួនអំពីចំនួនទឹកប្រាក់ដែលត្រូវបង់ ភាគីរងគ្រោះនឹងព្យាយាមបញ្ចុះបញ្ចូលភាគីចុងចម្លើយឱ្យបង់ប្រាក់ចំនួន១០០០ដុល្លារអាមេរិក ឬប្រហាក់ប្រហែលនោះតាមដែលអាចធ្វើ

[26] ដូចលេខ១៧ ទំ.១៣

ទៅបាន។ ភាគីចុងចម្លើយ នឹងព្យាយាមបញ្ចុះបញ្ចូលភាគីរងគ្រោះ ឱ្យយល់ព្រមទទួលយកទឹកប្រាក់កាន់តែតិចតួចឡើងតាមដែលអាចធ្វើទៅបាន។[27]

២.១.៣.២ វិធីសាស្ត្រនៃការចរចាឈ្នះ-ឈ្នះ

ការចរចាឈ្នះ-ឈ្នះ គឺជាប្រភេទនៃការចរចាដែលពឹងផ្អែកទៅលើផលប្រយោជន៍ជាធំ មានន័យថាការចរចាឈ្នះ-ឈ្នះ ភាគីអាចមានលក្ខណៈជាការសហការច្រើនជាងការចរចាបែបបែងចែក ពីព្រោះនៅក្នុងនោះភាគីវិវាទបានសន្មតថាមានផលប្រយោជន៍សំខាន់ដទៃផ្សេងទៀតដែលត្រូវបានគេរកឃើញ និងតម្រូវតាម។ នៅក្នុងករណីនេះភាគីអាចមានផលប្រយោជន៍មួយចំនួនរួមគ្នា ឬយ៉ាងហោចណាស់មួយចំនួនដែលបំពេញឱ្យគ្នាទៅវិញទៅមក។

២.១.៤ ដំណាក់កាលនៃដំណើរការចរចា

ដំណើរការនៃការចរចាមិនមានប្រើវិធានអ្វីឱ្យជាក់លាក់នោះទេ មិនមានច្បាប់ ឬលក្ខន្តិកៈណាមួយដែលណែនាំអំពីដំណើរការនៃការចរចាឡើយ ប៉ុន្តែគេអាចស្វែងយល់អំពីដំណើរការរបស់វាបានកាន់តែប្រសើរតាមរយៈដំណាក់កាលចំនួនប្រាំដូចខាងក្រោម៖

២.១.៤.១ ដំណាក់កាលត្រៀម

នៅក្នុងដំណាក់កាលនេះ ភាគី ឬ/និងមេធាវីរបស់ខ្លួនត្រូវពិនិត្យមើលវិវាទយ៉ាងប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើសេចក្តីសន្និដ្ឋានជាមូលដ្ឋានមួយចំនួន មុននឹងចាប់ផ្តើមដំណើរការចរចា។ ជំហានទីមួយ គឺធ្វើការស្រាវជ្រាវ និងស្វែងរកអង្គហេតុដែលពាក់ព័ន្ធនឹងវិវាទទាំងអស់ អាចជាការសម្ភាសជាមួយមនុស្សម្នាក់ ឬច្រើននាក់ ហើយវាក៏អាចពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញនូវភស្តុតាងដូចជា កិច្ចសន្យា ឬ វិក័យប័ត្រផ្សេងៗ។ បន្ទាប់ពីយល់ច្បាស់អំពីអង្គហេតុមកហើយ ជំហានបន្ទាប់ គឺធ្វើការវិភាគច្បាប់ដោយផ្អែកលើអង្គហេតុទាំងនោះ។ ប្រការដែលសំខាន់ ភាគី ឬមេធាវីត្រូវព្យាយាមបង្កើតអំណះអំណាងផ្លូវច្បាប់ឱ្យបានច្រើនតាមដែលអាចធ្វើបាន ព្រមទាំងវាយតម្លៃដោយមិនលម្អៀងអំពីចំណុចខ្លាំងនៃអំណះអំណាងទាំងនេះ។[28]

---

[27] ដូចលេខ២៧

[28] ដូចលេខ១៧ ទំ.៦៧

ជំហានបន្ទាប់មកទៀត គឺត្រូវស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់ភាគី ដែលទាមទារឱ្យមេធាវីសួរសំណួរជាមូលដ្ឋានបន្ថែមទៀតដូចជា អាជីវកម្ម សម្ព័ន្ធភាព ការភ័យព្រួយ បំណងប្រាថ្នា និងគោលដៅរបស់ភាគី។

ខាងក្រោមនេះ ជាបញ្ជីនៃផលប្រយោជន៍មួយចំនួន ដែលភាគីអាចមានក្រៅពីបញ្ហាប្រាក់កាសៈ

- ការរក្សាសម្ងាត់
- សុវត្ថិភាពរាងកាយ
- ការរក្សាកេរ្តិ៍ឈ្មោះ
- ការរក្សាទំនាក់ទំនងល្អជាមួយភាគីម្ខាងទៀត
- ការបន្តការងារ
- ការទទួលស្គាល់ចំពោះកិច្ចប្រឹងប្រែងរបស់ភាគី
- ការទទួលបាននូវការសម្តែងភាពសោកស្តាយ ទឹកចិត្តអាណិតអាសូរ ឬការសុំទោស
- ការមាន ថ្ងៃឡើងតុលាការ"˝ របស់ភាគី
- ឱ្យភាគីម្ខាងទៀតស្តាប់ និងយល់ពីភាគី
- ការសង្គ្រោះមុខមាត់
- ការធ្វើឱ្យភាគីម្ខាងទៀតអាម៉ាសមុខ ឬអៀនខ្មាស់ជាសាធារណៈ
- ការចង់ផ្សាភ្ជាប់ខ្លួនទៅនឹងវប្បធម៌ គ្រួសារ ឬអង្គការស្ថាប័នណាមួយ
- ការសបញ្ជាក់ឱ្យឃើញថាភាគីនោះ គឺជាអ្នកត្រូវ។

នៅក្នុងករណីខ្លះផលប្រយោជន៍ និងគោលដៅទាំងនេះ អាចមានសារៈសំខាន់ជាងប្រាក់កាសសម្រាប់ភាគីម្ខាង។ ឧទាហរណ៍ ភាគី អាចមានអំណះអំណាងរឹងមាំផ្អែកលើទស្សនៈផ្លូវច្បាប់ ប៉ុន្តែផលប្រយោជន៍របស់ភាគីនោះ អាចជាការជៀសវាងនូវការប្រឈមមុខជាសាធារណៈ ឬក៏ថាភាគីអាចត្រូវការដំណោះស្រាយមួយដែលឆាប់រហ័ស ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ឬពេលកំណត់នៃអាជីវកម្មដែលទាំងអស់នេះធ្វើឱ្យដំណោះស្រាយដែលឆាប់រហ័ស កាន់តែមានសារៈសំខាន់ជាងការទទួលបានជាអតិបរមាពីការព្រមព្រៀងសុខស្រួល។

២.១.៤.២ ដំណាក់កាលផ្តើម

ជាញឹកញាប់ ការព្យាយាមបង្ហាញការមិនមានចំណាប់អារម្មណ៍នៅក្នុងការចរចារបស់ភាគី ហើយនៅតែយល់ព្រមចូលរួមក្នុងការចរចា ជួនកាលក៏ជាប្រការដែលមានសារៈប្រយោជន៍ដែរ ។ ជួនកាលសំណួរផ្សេងទៀតត្រូវបានចាត់ទុកថាជាបែបបទផ្លូវការសុទ្ធសាធ ប៉ុន្តែ សំណួរទាំងនេះអាចមានសារៈសំខាន់ផងដែរ។ ពាក់ព័ន្ធនឹងសំណួរថា "នៅពេលណា" វាជាផលប្រយោជន៍ខ្ពស់របស់ភាគីក្នុងការឱ្យមានការចរចាជាបន្ទាន់អាចចង្អុលបង្ហាញកម្រិតមួយនៃតម្រូវការ ឬសេចក្តីអស់សង្ឃឹម។ ប្រសិន បើភាគីម្ខាងយល់ថាការចរចាត្រូវតែធ្វើឡើងជាបន្ទាន់ ភាគីនោះអាចប្រឈមមុខនឹងតម្រូវការប្រាក់ ឬអាចថាភាគីនោះអាចប្រឈមមុខនឹងរយៈពេលកំណត់ផ្នែកអាជីវកម្មដ៏សំខាន់ណាមួយ ឬភាគីនោះអាចមានការភ័យខ្លាចថាវិវាទនោះនឹងត្រូវបើកចំហរជាសាធារណៈដែលអាចបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់ខ្លួនបាន។ រីឯសំណួរថា "នៅកន្លែងណា" និង "ដោយរបៀបណា" មានលក្ខណៈកាន់តែល្អិតល្អន់និងកាន់តែមានសារៈសំខាន់ ប្រសិនបើការចរចាត្រូវបានធ្វើឡើងនៅឯការិយាល័យមេធាវីរបស់អ្នក នោះអ្នកនឹងមានប្រៀបខាង"ទីតាំង"។ ម្យ៉ាងវិញទៀតសំណួរ "របៀបណា" ពាក់ព័ន្ធទៅនឹងដំណើរការចរចាផ្ទាល់ដោយមានសំណួរជាច្រើនដូចជា តើពួកគេគួរចរចាតាមទូរស័ព្ទដែរឬទេ? តើពួកគេត្រូវចរចាទល់មុខគ្នាដោយផ្ទាល់ដែរឬទេ? ប្រសិនបើជួបផ្ទាល់ តើភាគីត្រូវមានវត្តមាននៅពេលចរចាដែរឬទេ? ប្រសិនបើកូនក្តីរបស់អ្នកត្រូវបានគំរាមកំហែងដោយភាគីម្ខាងទៀត ឬឆាប់រំជួលអារម្មណ៍នោះ គួរតែជៀសវាងកុំឱ្យមានការចូលរួមរបស់កូនក្តីនៅក្នុងការជួបចរចាដោយផ្ទាល់។

២.១.៤.៣ ដំណាក់កាលព័ត៌មាន

នៅក្នុងដំណាក់កាលនេះ ភាគីទាំងពីរចាប់ផ្តើមផ្តល់ព័ត៌មានដល់គ្នាទៅវិញទៅមក ភាគីម្ខាងអាចចាប់ផ្តើមដោយរៀបរាប់ពីអង្គហេតុតាមការយល់ឃើញរបស់ភាគី រួចបន្តទៅពិនិត្យឡើងវិញដោយសង្ខេបលើលក្ខខណ្ឌច្បាប់ និងផ្តល់ជម្រើសដើម្បីដោះស្រាយ។ [29] ដូចបានរៀបរាប់ខាងលើចំណុចនេះអាចត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ តាមរយៈលិខិត ឬអាចឆ្លើយឆ្លងតាមរយៈការសន្ទនាតាមទូរស័ព្ទ។ ប៉ុន្តែ ដើម្បីធ្វើឱ្យចំណុចនេះមានលក្ខណៈសាមញ្ញ នោះការចចារនឹងប្រព្រឹត្តិទៅដោយការពិភាក្សាផ្ទាល់ទល់មុខគ្នា។ នៅពេលពិភាក្សាអំពីអង្គហេតុ និងអង្គច្បាប់ ភាគីត្រូវផ្តល់ហេតុផលដែលមិនលម្អៀងចំពោះដំហរដោះស្រាយរបស់ខ្លួន ។ នៅដំណាក់កាលនេះ មេធាវីត្រូវដើរតួនាទីឱ្យមានសមភាពរវាងការព្យាយាមដឹងព័ត៌មានឱ្យបានច្រើនបំផុតពាក់ព័ន្ធនឹង

[29] ដូចលេខ៣០

ផលប្រយោជន៍។[30] នៅក្នុងដំណើរការចរចារទាំងមូលប្រការដែលសំខាន់ គឺការសួរសំណួរទៅភាគីម្ខាងទៀត ត្រូវជំរុញពួកគេឱ្យពន្យល់អំពីជំហររបស់ពួកគេ ចំពោះអ្វីៗគ្រប់យ៉ាង តាំងពីទំនួលខុសត្រូវរហូតដល់ការខូចខាតនានា។ ជាការសំខាន់ត្រូវព្យាយាមរក្សាភាពវិជ្ជមានជានិច្ច ទោះបីជាបញ្ហាហាក់ដូចជាមិនមានភាពអនុគ្រោះចំពោះកូនក្តីរបស់អ្នកពីដំបូងមកក្តី ពោលគឺព្យាយាមប្រើប្រាស់ប្រយោគវិជ្ជមានជំនួសឱ្យការគំរាមកំហែង ឬពាក្យពេចន៍ដែលមានភាពអវិជ្ជមាន។[31] ការព្យាយាមធ្វើឱ្យភាគីម្ខាងទៀតបន្តការនិយាយនៅក្នុងកំឡុងពេលចរចា គឺជាប្រការដ៏មានសារៈប្រយោជន៍ ប្រសិនបើភាគីម្ខាងនោះនិយាយកាន់តែច្រើន គាត់អាចបញ្ចេញព័ត៌មានកាន់តែបានច្រើន។[32]

២.១.៤.៤ ដំណាក់កាលបែងចែក ឬផ្អែកលើផលប្រយោជន៍

បន្ទាប់ពីភាគីវិវាទមានឱកាសពន្យល់អំពីការយល់ដឹងរបស់ខ្លួនចំពោះអង្គហេតុ ការវិភាគរបស់ខ្លួនលើអង្គច្បាប់ព្រមទាំងជំហរ និងផលប្រយោជន៍របស់ពួកគេរួចមក ដំណាក់កាលបែងចែកផ្អែកលើផលប្រយោជន៍ក៏ចាប់ផ្តើម។[33] នេះគឺជាដំណាក់កាល ដែលភាគីទាំងពីរស្វែងរកដំណោះស្រាយផ្អែកលើផលប្រយោជន៍ដែលអាចមានជាមុនសិន ហើយបើមិនមានលទ្ធភាពណាមួយនោះទេ ទើបបន្តទៅរកដំណោះស្រាយបែបបែងចែក។

២.១.៤.៥ ដំណាក់កាលបញ្ចប់

នៅពេលដែលមានការព្រមព្រៀងនៅក្នុងកំឡុងពេលចរចាហើយ ត្រូវធានាថាលក្ខខណ្ឌព្រមព្រៀងទាំងនោះត្រូវបានសរសេរចូលជាលាយលក្ខណ៍អក្សរភ្លាមៗ ដោយហេតុថា ការចងចាំរបស់មនុស្សតែងរលត់ទៅវិញ ហើយប្រសិនបើភាគីចរចាពន្យាពេលដោយគ្រាន់តែចងចាំអំពីលក្ខខណ្ឌនៃការព្រមព្រៀងនោះ ក្រោយមកទៀតពួកគេអាច នឹងមិនការឯកភាពទៅលើលក្ខខណ្ឌជាក់លាក់ណាមួយនៅពេលដែលពួកគេព្យាយាមសរសេរវាចូល។[34]ម្យ៉ាងវិញទៀតប្រសិនបើភាគីប្រើពេលវេលាច្រើនជ្រុលពេកនោះ ពួកគេអាចពិចារណាឡើងវិញនូវសម្បទានរបស់ខ្លួន ហើយនឹងព្យាយាមចរចាឡើងវិញ ដើម្បីទទួលបានលក្ខខណ្ឌកាន់តែប្រសើរជាងមុន។ ដើម្បី

[30] ដូចលេខ៣០

[31] ដូចលេខ៣០

[32] ដូចលេខ៣០

[33] ដូចលេខ១៧ ទំ.៧១

[34] ដូចលេខ១៧ ទំ.៧២

ជៀសវាងបញ្ហានេះកើតឡើង ភាគីចរចាត្រូវត្រៀមខ្លួនជានិច្ចក្នុងការសរសេរចូលនូវលក្ខខណ្ឌមូលដ្ឋាននៃកិច្ចព្រមព្រៀង និងចុះហត្ថលេខា ហើយបន្ទាប់មកត្រូវសរសេរលក្ខខណ្ឌជាស្ថាពរឱ្យបានឆាប់។

២.១.៤.៦ គុណសម្បត្តិ និងគុណវិបត្តិ

ការចរចាផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិ ដូចជាៈ

គុណសម្បត្តិ

- **ចំណាយ** រាល់ការចំណាយអស់ប្រាក់តិចជាងវិធីសាស្ត្រដោះស្រាយវិវាទផ្សេងទៀត វាចំណែកមួយដែលនាំឱ្យការចរចាមានប្រជាប្រិយភាព វាមិនមានប្រាក់ប្រដាប់ក្តី ឬថ្លៃចំណាយផ្សេងទៀតឡើយ
- **ភាពឯកជន** ការចរចាអាចជាដំណើរការឯកជនទាំងស្រុងដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ គ្មានការចូលរួមពីតុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមទេ
- **ភាពបត់បែន** ការចរចាមានភាពបត់បែនក្នុងដំណើរការ និងលទ្ធផលដោយភាពបត់បែនក្នុងដំណើរការមានន័យថា ការចរចាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។ ឯភាពបត់បែនក្នុងលទ្ធផល គឺភាគីវិវាទផ្ទាល់ជាអ្នកឈានដល់ការស្រុះស្រួលរវាងគ្នា ដែលភាគីមិនអាចធ្វើបាននៅក្នុងការដោះស្រាយនៅមជ្ឈត្តការ ឬតុលាការឡើយ
- **ល្បឿន** ការចរចាមានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។ ភាគីមិនចាំបាច់ត្រូវរង់ចាំចៅក្រម មជ្ឈត្តករ ឬសន្ធានការីដើម្បីធ្វើសវនការ និងសម្រេចលើរឿងក្តីនោះឡើយបញ្ហាអាចត្រូវបានដោះស្រាយភ្លាមៗឱ្យតែភាគីឈានដល់ការស្រុះស្រួលគ្នា
- **គ្រប់គ្រង** ការចរចាផ្តល់ឱ្យភាគីវិវាទនូវលទ្ធភាពគ្រប់គ្រងយ៉ាងពេញលេញទៅលើដំណើរការ និងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ថាតើត្រូវធ្វើការចរចាតាមរបៀបណា និងថាតើនឹងមានការស្រុះស្រួលដែរឬទេ? ក្នុងការចរចា គេមិនបង្ខំភាគីណាមួយឱ្យចូលក្នុងដំណើរការចរចា ឬការស្រុះស្រួលណាមួយដោយគ្មានការព្រមព្រៀងពីភាគីវិវាទនោះទេ
- **រក្សាទំនាក់ទំនង** ការចរចា ផ្តល់លទ្ធភាពដល់ភាគីវិវាទក្នុងការរិះរកការស្រុះស្រួលណាមួយដែលអាចរក្សាទំនាក់ទំនងនេះបានដែលពួកគេធ្លាប់មានពីមុនមក ។

- **ការអនុវត្តដំណោះស្រាយ** ការស្រុះស្រួលតាមរយៈការចរចាលើរឿងក្តីណាមួយ អាចត្រូវបានកត់បញ្ចូលក្នុងនីតិវិធីតុលាការនៅចំពោះមុខចៅក្រម ហើយនឹងអាចអនុវត្តដូចជាសាលក្រមដែរ។[35]

គុណវិបត្តិ

- **ពន្យាពេល** ភាគីម្ខាងអាចពន្យាពេលដំណើរការនៃការចរចា បើសិនជាខ្លួនចង់នៅក្នុងស្ថានភាពចរចាសុទ្ធសាធមួយ គ្មានវិធីអ្វីអាចបង្ខំភាគីណាមួយឱ្យពន្លឿនសកម្មភាពបានឡើយ។ វាជាលទ្ធភាពមួយដែលថាភាគីល្មើស អាចមិនទាំងប្រាកដប្រជាអំពីការស្រុះស្រួលផង ហើយប្រើប្រាស់ការចរចាជាវិធីសម្រាប់ពន្យាពេលបញ្ហា ឬគេចវេសពីបណ្តឹងតុលាការ
- **ភាគីគ្មានហេតុផល** ជាកំណត់សម្គាល់ ស្រដៀងគ្នានេះ ភាគីអាចប្រទះនូវលទ្ធភាពដែលភាគីម្ខាងទៀតអាចប្រកាន់ជំហរមិនសមហេតុផលនៅក្នុងការចរចា ដូចបានរៀបរាប់ខាងលើ ករណីនេះអាចដោយសារតែពួកគេមិនប្រាកដប្រជាចំពោះការចរចា ហើយកំពុងប្រើប្រាស់មធ្យោបាយនេះដើម្បីបង្ហិនពេលវេលា ឬគេចវេសពីបណ្តឹងតុលាការ
- **ការអនុវត្តដំណោះស្រាយ** បន្ទាប់ពីការចរចារួច ភាគីអាចឯកភាពគ្នាលើកិច្ចព្រមព្រៀងសុខស្រួលមួយដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។ ប៉ុន្តែ មួយរយៈក្រោយមកភាគីណាមួយអាចមិនគោរពតាមលក្ខខណ្ឌការស្រុះស្រួលដោយសារតែការស្រុះស្រួលនោះ គ្រាន់តែជាកិច្ចព្រមព្រៀងតាមរយៈការចរចាភាគីម្ខាងទៀតគ្មានវិធីដោយផ្ទាល់ក្នុងការដាក់ឱ្យអនុវត្តតាមផ្លូវតុលាការឡើយ។ ជាលទ្ធផលភាគីនោះអាចនៅតែត្រូវដាក់ពាក្យប្តឹងទៅតុលាការ ហើយត្រូវរង់ចាំក្នុងរយៈពេលយូរដើម្បីអនុវត្តកិច្ចព្រមព្រៀងស្រុះស្រួលខាងដើមនោះ
- **ភាគីម្ខាងមានអំណាចខ្លាំងពេក** មានកាលៈទេសៈមួយចំនួនដែលភាគីមានវិសមភាពនឹងគ្នានៅក្នុងអំណាចចរចា ជាហេតុនាំឱ្យភាគីម្ខាងមានសិទ្ធិត្រួតត្រាហួសពេក ។[36]

**<u>ករណីសិក្សា</u>**

សុវណ្ណជាម្ចាស់រោងចក្រមួយកន្លែង ហើយថ្មីៗនេះគាត់ទើបតែបណ្តេញបុគ្គលិកម្នាក់ដែលជាជន

---

[35] នៅក្នុងប្រទេសកម្ពុជា មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាតចំពោះទំនាក់ទំនងជាមួយកូនក្តីរបស់ខ្លួន "ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា" មាត្រា៥៨ (ឆ្នាំ១៩៩៥)

[36] ក្រមសីលធម៌សម្រាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧ ឆ្នាំ ១៩៩៥

ជាតិចាមម្នាក់ចេញពីរោងចក្រ ដោយតែបុគ្គលិកនោះបានបញ្ឈប់ខ្សែសង្វាក់ផលិតកម្ម ហើយបែរមកធ្វើការអធិដ្ឋានបីដងក្នុងមួយថ្ងៃ។ ទង្វើនេះធ្វើឱ្យកម្រិតផលិតកម្មធ្លាក់ទាប ហើយនៅពេលសុវណ្ណស្នើឱ្យបុគ្គលិកនោះឈប់អធិដ្ឋានទៀត បុគ្គលិកនៅតែពុំព្រមបឈ្ឈប់ទង្វើនេះ។ បុគ្គលិកនោះខឹងយ៉ាងខ្លាំង ហើយគម្រាមថានឹងដាក់បណ្ដឹងទៅតុលាការដើម្បីប្ដឹងសុវណ្ណ ដោយគាត់យល់ឃើញថាសុវណ្ណរើសអើងនឹងគាត់ដោយសារតែសាសនាអុីស្លាម។ បុគ្គលិកនោះក៏បានស្នើឱ្យជនជាតិចាមដែលធ្វើការនៅក្នុងរោងចក្រទាំងអស់នោះនាំគ្នាធ្វើកូដកម្មប្រឆាំងសុវណ្ណ។ ហេតុដូច្នេះសុវណ្ណក៏បាន ការសម្រេចចិត្តធ្វើការចរចាជាមួយបុគ្គិលិកម្នាក់នោះដោយព្យាយាមពន្យល់ពីផលប៉ះពាល់ពីបញ្ឈប់នៅពាក់កណ្តាលខ្សែសង្វាក់ផលិតកម្មដោយធ្វើអោយមានការរំខានដល់កម្មករផ្សេងទៀត ទើបគាត់បានផ្តល់សំណើរឱ្យ បុគ្គលិកម្នាក់បែរមកធ្វើការអធិដ្ឋាន២ដងក្នុងមួយថ្ងៃ ពោលគឺធ្វើការអធិដ្ឋាននៅពេលម៉ោងសម្រាក។ ចំណែកឯបុគ្គលិកនោះក៏បានស្នើសំណើរដល់សុវណ្ណ ដោយសូមពន្យារពេលម៉ោងសំរាកលើស៣០នាទីដើម្បីអោយខ្លួនមានពេលធ្វើការអធិដ្ឋាន និងបានសម្រាកផងដែរ។

២.២ ការផ្សះផ្សា

ជាទូទៅការផ្សះផ្សា គឺជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានលក្ខណៈស្រដៀងនឹងសន្ទានកម្ម ដោយអ្នកផ្សះផ្សាមានភារៈណែនាំភាគីវិវាទ ដើម្បីរកដំណោះស្រាយ ។

២.២១ និយមន័យ

ការផ្សះផ្សា សំដៅទៅលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយដែលមានភាគីទីបីជាអ្នកជួយ (អ្នកផ្សះផ្សា) ដែលភាគីទីបីនោះជាអ្នកលើកជម្រើសដល់ភាគីជម្លោះហើយភាគីជម្លោះជាអ្នកសម្រេចចិត្តដោយខ្លួនឯងថា ព្រមធ្វើការផ្សះផ្សា ឬអត់។ អ្នកផ្សះផ្សា មិនត្រូវលូកលាន់នៅក្នុងដំណើរការពិភាក្សា ឬក្នុងដំណើរការដោះស្រាយទេ ប៉ុន្តែអាចដើរតួជា អន្តរការី ដើម្បីណែនាំឱ្យភាគីវិវាទត្រូវគ្នា ហើយតួនាទីសំខាន់របស់អ្នកផ្សះផ្សា ត្រូវខិតខំឱ្យគូភាគីវិវាទឈានទៅដល់ចំណុចព្រមព្រៀងមួយ ដោយការបន្ថយនូវវោហាសាស្ត្រដែលខ្វែងគំនិតគ្នា និងភាពតឹងតែង ហើយបើកចំហឱ្យមានការប្រាស្រ័យទាក់ទង និងសម្រួលឱ្យមានការចរចាជាបន្តទៅទៀត។[37]

២.២.២ លក្ខណៈពិសេសនៃការផ្សះផ្សា

[37] វិធានផ្សះផ្សានៃគណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ មាត្រា ៥ ឆ្នាំ១៩៨០

ការផ្សះផ្សា គឺជាវិធីសាស្ត្រនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការមួយដ៏មានប្រសិទ្ធភាព និងឆាប់រហ័ស ដែលមានលក្ខណៈពិសេសមួយចំនួនដូចជា៖

- ជាដំណើរការកសាងសន្តិភាព
- គឺជាការបន្តនូវដំណើរការចរចា
- មិនមែនជាដំណើរការអនុវត្តច្បាប់ មានន័យថាជួយដល់ភាគីទាំងអស់ដើម្បីកាត់បន្ថយនូវការខ្វែងគំនិតគ្នា ព្រមស្វែងរកការព្រមព្រៀងនិងដំណោះស្រាយមួយប្រកបដោយមិត្តភាព
- ភាគីទីបី ជាជនអព្យាក្រឹត្យចូលរួម
- ជាការចរចាដែលមានជំនួយ
- ចាប់ផ្តើមនៅពេលការចរចាឈានដល់ការរាំងស្ទះ
- ជាការអន្តរាគមន៍ប្រកបដោយយថាក្រមនៅក្នុងវិវាទ
- លទ្ធផលនៃការផ្សះផ្សាគ្រប់គ្រងដោយភាគីវិវាទ
- ជាដំណើរការដែលអាចបត់បែនទៅតាមកាលៈទេសៈ
- ជាដំណើរការដែលមានហានិភ័យទាប
- ជាធម្មតាមានលក្ខណៈសម្ងាត់។[38]

២.២.៣ នីតិវិធីនៃការផ្សះផ្សា

ភាគីដែលផ្តួចផ្តើមការផ្សះផ្សា ត្រូវផ្ញើរលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងទៀតដើម្បីផ្សះផ្សា ដោយធ្វើការបង្ហាញនូវកម្មវត្ថុនៃវិវាទនោះដោយសង្ខេបផងដែរ។ ដំណើរការផ្សះផ្សា ចាប់ផ្តើមនៅពេលភាគីម្ខាងទៀតទទួលយកការអញ្ជើញដើម្បីផ្សះផ្សា ប្រសិនបើភាគីម្ខាងទៀតបដិសេធការអញ្ជើញនោះ ដំណើរការផ្សះផ្សានឹងមិនកើតឡើងឡើយ ប៉ុន្តែប្រសិនបើភាគីដែលផ្តួចផ្តើមការផ្សះផ្សា មិនបានទទួលយកចម្លើយតបក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃផ្ញើលិខិតអញ្ជើញមក ឬក្នុងរយៈពេលផ្សេងទៀតដូចមានបញ្ជាក់នៅក្នុងលិខិតអញ្ជើញ ភាគីនោះអាចសម្រេចចិត្តដោយចាត់ទុកថា នេះជាការបដិសេធការអញ្ជើញដើម្បីផ្សះផ្សា ។[39]

[38] ដូចលេខ៤០

[39] ដូចលេខ៤០

នៅក្នុងដំណើការផ្សះផ្សា អ្នកផ្សះផ្សាគឺជាអ្នកជួយភាគីវិវាទ ដើម្បីជ្រើសរើសដំណោះស្រាយវិវាទប្រកប ទៅដោយភាពល្អប្រសើរសម្រាប់ភាគីទាំងសងខាង។ អ្នកផ្សះផ្សាធ្វើយ៉ាងណា ឱ្យការដោះស្រាយវិវាទបត់បែន ទៅតាមកាលៈទេសៈ ដោយដំណោះស្រាយនោះអាចធ្វើឱ្យភាគីនៃវិវាទទទួលយកបាន។ ចំពោះពេលវេលានៃ ការផ្សះផ្សា គេច្រើនធ្វើនៅក្នុងរយៈពេលពីរទៅបីថ្ងៃ ហើយការចំណាយទៅលើអ្នកផ្សះផ្សា គូវិវាទត្រូវបង់ថ្លៃ សេវាកម្មទៅតាមការកំណត់របស់អ្នកផ្សះផ្សា។ សេចក្តីសម្រេចនៃការផ្សះផ្សាមានលក្ខណៈដូចជា កិច្ចព្រមព្រៀង មួយ ដែរ ហើយសេចក្តីសម្រេចអាចធ្វើឡើងនៅក្នុងករណីដូចជា៖

- បើមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀមបញ្ចប់វិវាទដោយភាគីវិវាទ ត្រឹមកាលបរិច្ឆេទនៃកិច្ចព្រមព្រៀង នោះ។
- បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់អ្នកផ្សះផ្សាបន្ទាប់ពីផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ អ្នក ផ្សះផ្សាត្រូវមានការប្រឹក្សាយោបល់ជាមួយភាគីវិវាទថែមទៀតចំពោះលទ្ធផល ដែលបានមកពីកិច្ច ខិតខំប្រឹងប្រែងផ្សះផ្សានេះ ថាសេចក្តីប្រកាសនោះមានភាពត្រឹមត្រូវដែរឬទេ នោះសេចក្តីប្រកាសនឹង គិតត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាស។
- បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ធ្វើឡើងដោយភាគីវិវាទ ទៅកាន់អ្នកផ្សះផ្សា ចំពោះ លទ្ធផលដែលថា ដំណើរការនឹងត្រូវបញ្ឈប់គិតត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាសនោះ។
- បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ភាគីម្ខាងទៅភាគីម្ខាងទៀត ព្រមទាំងអ្នកផ្សះផ្សា នោះ ហើយមានការតែងតាំងរួចចំពោះលទ្ធផលដែលថា ដំណើរការផ្សះផ្សានឹងត្រូវបញ្ឈប់ត្រឹមកាល បរិច្ឆេទនៃសេចក្តីប្រកាសនោះ។[40]

២.២៤ គុណសម្បត្តិ និងគុណវិបត្តិ.

ការផ្សះផ្សាកំពុងក្លាយជាការពេញនិយមកាន់តែខ្លាំងឡើង ហើយបានផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិ មួយចំនួន រួមមានដូចជា៖

គុណសម្បត្តិៈ

[40] ដូចលេខ៤០

- ផ្តល់នូវជម្រើសដែលអាចបត់បែនបានសម្រាប់វិវាទជាច្រើនប្រភេទ
- រក្សាការសម្ងាត់ទូទាំងដំណើរការនីតិវិធី
- មានប្រសិទ្ធភាពចំណាយ និងបង្កើតដំណោះស្រាយវិវាទបានលឿនជាងមុន
- ជួយសម្រួលដល់ការថែរក្សាទំនាក់ទំនងបន្តរវាងភាគី សូម្បីតែបន្ទាប់ពីការដោះស្រាយ
- មិនមានវិសាលភាពសម្រាប់អំពើពុករលួយ ឬលំអៀងទេ។[41]

គុណវិបត្តិៈ

- **ការទំនាក់ទំនងមិនត្រឹមត្រូវនៃព័ត៌មាន៖** តួនាទីរបស់អ្នកផ្សះផ្សា ជាអ្នកដែលមានសក្តានុពលសម្រាប់សារចម្រុះ ឬមិនត្រឹមត្រូវដែលត្រូវបានផ្ញើរ និងទទួលដោយភាគីរៀងៗខ្លួន។ អ្នកផ្សះផ្សាអាចយល់ខុសនូវអ្វីដែលភាគីម្ខាងបាននិយាយហើយបញ្ជូនរឿងនេះទៅភាគីម្ខាងទៀត។[42]

<u>ករណីសិក្សា</u>

វិទ្ធី និងម៉ូណារស់នៅខេត្តកំពង់ចាមបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាអស់រយៈពេល១០ឆ្នាំ។ម៉ូណា យល់ឃើញថាវិទ្ធីចំណាយប្រាក់អស់យ៉ាងច្រើនទៅលើល្បែងស៊ីសង បន្ទាប់មកវិទ្ធីរអ៊ូរទាំថា ម៉ូណា ព្រងើយកន្តើយនឹងខ្លួនហើយមិនមើលថែទាំផ្ទះ និងកូនចៅឱ្យបានត្រឹមត្រូវ។ វិទ្ធីជាមនុស្សមាឌធំ និងចូលចិត្តគំរាមកំហែង ហើយម៉ូណាមិនដែលហ៊ានឈ្លោះប្រកែកជាមួយវិទ្ធីទេដោយសារខ្លាចគេវាយខ្លួន។ ពួកគេមិនសប្បាយចិត្ត ហើយកំពុងពិចារណាពីការលែងលះគ្នា ពួកគេទាំងពីរនាក់ក៏បានស្វែងរកក្រុមប្រឹក្សាឃុំក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំក្នុងមូលដ្ឋានបានដើរតួជាអ្នកផ្សះផ្សា បានផ្តល់យោបល់ឱ្យប្តីប្រពន្ធមួយគូនេះធ្វើការផ្សះផ្សាជាមុនសិន មុននឹងឈានដល់ការដាក់ពាក្យបណ្តឹងទៅតុលាការ។

២.៣ សន្ទានកម្ម

[41] ដូចលេខ៤០

[42] ដូចលេខ៤០

សន្ទានកម្ម ត្រូវបានគេប្រើលាយឡំគ្នាអស់រយៈពេលជាយូរលង់ណាស់មកហើយ ដែលមាននៅក្នុងមជ្ឈដ្ឋានអ្នកសិក្សា អ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងតុលាការ។[43] បច្ចុប្បន្នពាក្យថា **សន្ទានកម្ម និងការផ្សះផ្សា** ត្រូវបានប្រើប្រាស់ជាញឹកញាប់ដើម្បីជំនួសគ្នាទៅវិញទៅមក ។ សន្ទានកម្ម សំដៅទៅដល់ការសម្រុះសម្រួលវិវាទដែលធ្វើឡើងដោយមានបុគ្គលម្នាក់ជាអ្នកសម្របសម្រួល ដែលបុគ្គលនោះត្រូវបានហៅថា **សន្ទានការី**។

២.៣.១ និយមន័យ

សន្ទានកម្ម គឺជាការចរចាដោយមានជំនួយ ឬការជួយសម្របសម្រួលដែលអាចកំណត់បានថា ជាដំណើរការនៃការដោះស្រាយវិវាទ ដោយក្នុងនោះមានអ្នកធ្វើអន្តរាគមន៍មិនលំអៀងម្នាក់ជួយភាគីវិវាទទាំងពីរ ឬច្រើនឱ្យកំណត់ពីបញ្ហាកង្វល់ ហើយបន្ទាប់មកបង្កើតនូវសំណើរនានា ដែលអាចទទួលយកបានទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហាកង្វល់ទាំងនោះ។ ម្យ៉ាងវិញទៀត សន្ទានកម្ម ជាការដោះស្រាយវិវាទមួយដោយឈរលើដំណើរការនៃការចរចានៅក្នុងសន្ទានកម្ម ឬការសម្រុះសម្រួល ដោយផ្អែកលើភាគីអព្យាក្រឹត្យទីបីម្នាក់ ឬច្រើននាក់ដែលហៅថា សន្ទានការី។[44] សន្ទានការី ត្រូវជួយភាគីវិវាទទាំងឡាយដើម្បីដោះស្រាយវិវាទរបស់ពួកគេផ្ទាល់ ហើយមិនមានអំណាចទៅលើភាគីវិវាទទេ ឬ បង្ខិតបង្ខំដើម្បីឱ្យពួកគេទទួលយកនូវដំណោះស្រាយរបស់ខ្លួនឡើយ ដូច្នេះមានន័យថា អ្នកសម្រុះសម្រួលមិនអាចធ្វើសេចក្តីសម្រេចបានឡើយ។[45]

សន្ទានការីនៅក្នុងនីតិវិធីសន្ទានកម្ម ជាបុគ្គលអព្យាក្រឹត្យ ដែលរងចាំជួយភាគីនៃវិវាទ និងកំណត់អំពីបញ្ហាកង្វល់ ឬជួយភាគីវិវាទឱ្យចរចាសម្រេចបាននូវដំណោះស្រាយរួមមួយ ដែលមានមូលហេតុសមស្របអាចទទួលយកបាន។ ជាមួយគ្នានេះដែរ សន្ទានការីមានសិទ្ធិក្នុងការស្នើឡើងនូវជម្រើសដើម្បីស្វែងរកនូវដំណោះស្រាយជាប្រយោជន៍សម្រាប់ភាគីវិវាទទាំងសងខាង។

២.៣.២ ភារកិច្ចរបស់សន្ទានការី

នៅក្នុងដំណាក់កាលសន្ទានកម្ម សន្ទានការីមានភារកិច្ចមួយដូចជា៖

- ស្តាប់ភាគីនីមួយៗ

---

[43] ឯកសារស្រាវជ្រាវ គណៈកម្មការទី៦ “ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ” ស្រាវជ្រាវដោយវិទ្យាស្ថានសភាកម្ពុជា ខែមិថុនា ឆ្នាំ២០១៥

[44] ច្បាប់គំរូ UNCITRAL ស្តីពីការផ្សះផ្សាផ្នែកពាណិជ្ជកម្មអន្តរជាតិ, សម័យប្រជុំលើកទី ៥៧ ឯ.បន្ថែមលេខ ១៧ឯ.អសប លេខ A/57/17 ឧបសម្ព័ន្ធទី। មាត្រា៩ (ឆ្នាំ២០០២)

[45] ដូចលេខ៤៧

- លើកទឹកចិត្តភាគីនីមួយៗឱ្យស្តាប់ និងពិចារណាអំពីការសុះស្រួលគ្នា
- ជួយស្វែងរកដំណើរការដោះស្រាយដែលប្រកបដោយគំនិតច្នៃប្រឌិត
- ជួយស្វែងអំពីអង្គហេតុ អង្គច្បាប់ដូចដែលអ្នកអព្យាក្រឹត្យម្នាក់មើលឃើញនៅពេលសមស្រប
- បង្កើតចំណុចសម្របសម្រួលនៅក្នុងកិច្ចព្រមព្រៀងសម្រុះសម្រួលវិវាទ
- ជួយកាត់បន្ថយនូវភាពតានតឹងរវាងភាគីវិវាទទាំងឡាយដោយលើកទឹកចិត្តឱ្យមានការសហការគ្នា
- ជួយភាគីទាំងសងខាងឱ្យផ្តោតអារម្មណ៍ទៅលើបញ្ហាទាំងឡាយដែលចាំបាច់ត្រូវដោះស្រាយវិវាទ
- បង្កើតនូវទំនាក់ទំនងរវាងភាគីទាំងឡាយ ប្រសិនបើភាគីទាំងនោះមិននិយាយជាមួយគ្នាដោយផ្ទាល់
- ជួយភាគីម្នាក់ៗឱ្យយល់ពីប្រយោជន៍ទាំងឡាយរបស់ភាគីម្នាក់ទៀត
- ជួយភាគីទាំងឱ្យរកនូវដំណោះស្រាយវិវាទតាមវិធីផ្សេងៗទៀត ដោយធ្វើការផ្តល់ពីវិធីប្រាកដនិយម និង សត្យានុម័តសម្រាប់ឱ្យភាគីទាំងឡាយធ្វើការវិភាគទៅលើផលប្រយោជន៍របស់ពួកគេ។[46]

២.៣.៣ នីតិវិធីនៃការធ្វើសន្ទានកម្ម

មុនការចាប់ផ្តើមដំណើរការសន្ទានកម្ម ភាគីត្រូវដឹងពីទីកន្លែង ដឹងពីរបៀបដែលត្រូវធ្វើសន្ទានកម្ម បន្ទាប់មកសម្រាប់ការធ្វើសន្ទានកម្មត្រូវរៀបចំឱ្យបានសមរម្យគួរ មានតុធំមួយសម្រាប់អ្នកសម្រុះសម្រួល និង ភាគីនៃវិវាទ ហើយអ្នកសម្រុះសម្រួលគួរមានបន្ទប់មួយទៀតសម្រាប់ជួបជាមួយភាគីវិវាទ។[47]

**ក. សេចក្តីថ្លែងបើកការប្រជុំ**

អ្នកសម្រុះសម្រួលត្រូវណែនាំខ្លួនឱ្យភាគីទាំងពីរស្គាល់ខ្លួន ហើយពន្យល់អំពីដំណើរការនៃការសម្រុះសម្រួល ដោយប្រាប់ពីលក្ខខណ្ឌនៃការសម្រុះសម្រួល និងបញ្ជាក់ពីតួនាទីការងាររបស់អ្នកសម្រុះសម្រួល។ ការចាប់ផ្តើមការសម្រុះសម្រួលមានគោលបំណងនៃការប្រជុំដូចជា៖

១. ធ្វើឱ្យមានការទុកចិត្តគ្នារវាងភាគីទំនាស់ និងអ្នកសម្រុះសម្រួល

---

[46] ដូចលេខ៤៧

[47] Douglas Henderson, "ភាពជោគជ័យនៃការសម្រុះសម្រួល ការវិភាគដែលសំអាងលើការពិសោធន៍" លេខ១១ ទំព័រ ១៥០

២. ជួយឱ្យមានការប្រាស្រ័យទាក់ទងគ្នា

៣. យល់ពីទស្សនៈរបស់ភាគីនីមួយៗ ចំពោះហេតុការណ៍ដែលនាំឱ្យមានការប្តឹងផ្តល់គ្នានោះ

៤. រកឱ្យឃើញគោលជំហររបស់ភាគី

៥. រកឱ្យឃើញផលប្រយោជន៍របស់ភាគី

៦. បង្កើតជម្រើសផ្សេងៗ

៧. វាយតម្លៃលើជម្រើសទាំងនោះ

**ខ. ការជួបប្រជុំជាមួយភាគីម្នាក់ម្តងជាឯកជន**

ប្រសិនបើការសម្រុះសម្រួលនេះជួបនូវការលំបាក អ្នកសម្រុះសម្រួលអាចអញ្ជើញភាគីម្ខាងឱ្យចេញទៅក្រៅបន្ទប់ ដើម្បីអាចឱ្យអ្នកសម្រុះសម្រួល និយាយទៅកាន់ភាគីម្ខាងទៀតដោយផ្ទាល់។ បន្ទាប់ពីនិយាយផ្ទាល់ជាមួយភាគីម្ខាងរួចហើយ គេអញ្ជើញគាត់ចេញទៅក្រៅបន្ទប់ម្តង ហើយនាំភាគីម្ខាងទៀតចូលមកក្នុងបន្ទប់វិញ។ ការប្រជុំលក្ខណៈឯកជនបែបនេះ អាចជួយអ្នកសម្រុះសម្រួលបានដូចជា៖

- ធ្វើឱ្យភាគីស្ងប់អារម្មណ៍ចំពោះភាគីដែលមានចរិតខឹងរឹងរូស ពុំអាចគ្រប់គ្រងបានដោយខ្វះការគោរព ឬមិនចេះអត់អោន
- ទទួលបានព័ត៌មានថា ភាគីម្ខាងមិនសូវចង់និយាយ ឬមានការខ្មាស់អៀន មិនចង់ពិភាក្សានៅចំពោះមុខគ្នា
- ជួយឱ្យភាគីមួយពិចារណាមើលថា តើការទាមទាររបស់គេមានភាពប្រាកដនិយមឬអត់ ហើយពួកគេពិតជាចង់ដោះស្រាយបញ្ហាឬអត់ ដោយមិនធ្វើឱ្យគេខ្មាស់អៀន ឬប៉ះពាល់ដល់អព្យាក្រឹតភាព។[48]

**គ.ការប្រជុំរួមគ្នាលើកទី២**

ការប្រជុំរួមលើកទី២មាន ដំណើរការដូចដំណើរការប្រជុំលើកទីមួយដែរ។ អ្នកសម្រុះសម្រួលត្រូវដឹកនាំគូវិវាទឱ្យឈប់គិតពីផលប្រយោជន៍ ហើយបែរមកគិតពីជម្រើសដោះស្រាយវិញម្តង ដោយការបំផុសគំនិតឆ្លោះ

[48] keith G. Allred, "ភាពសកម្មនៃទំនាក់ទំនងក្នុងវិវាទសៀវភៅណែនាំអំពីដំណោះស្រាយវិវាទ" ទំព័រ៨៣.៩១ ឆ្នាំ២០០៥

ទៅរកដំណោះស្រាយ។[49] បន្ទាប់មកជួយភាគីវិវាទឱ្យវាយតម្លៃលើជម្រើសរបស់ពួកគេ និងជួយសរសេរកិច្ចព្រមព្រៀង ជាពិសេសនៅពេលចុងក្រោយបំផុតនៃការសម្រុះសម្រួល ត្រូវឱ្យពួកគេបំពេញបែបបទទាំងអស់ដែលចាំបាច់។[50]

**ឃ.ការពិនិត្យបញ្ជាក់សារជាថ្មី**

ក្រោយពីការសម្រុះសម្រួលត្រូវពិនិត្យពិចារណាឡើងវិញលើការសម្រុះសម្រួលជាមួយដៃគូសម្រុះសម្រួលឯទៀត ដូចនេះអ្នកសម្រុះសម្រួលត្រូវ៖

- កត់ត្រាលើក្រដាសនូវចំណុចល្អៗនៃការសម្រុះសម្រួល និងចំណុចដែលត្រូវកែលំអនៅពេលក្រោយ
- សុំឱ្យដៃគូសម្រុះសម្រួលឯទៀតៗធ្វើដូចគ្នា ហើយប្តូរយោបល់គ្នាអំពីអ្វីៗដែលមានដំណើរការល្អ និងរបៀបដែលម្នាក់ៗអាចធ្វើឱ្យប្រសើរឡើងនៅពេលអនាគត។[51]

២.៣.៤ ដំណើរការសន្ធានកម្ម

នីតិវិធីសន្ធានកម្ម គឺជាកត្តាចម្បងសម្រាប់ភាពជោគជ័យនៃសន្ធានកម្ម។ ប្រសិនបើភាគីយល់ឃើញថាដំណើរការនោះមានភាពយុត្តិធម៌ ពួកគេអាចនឹងចង់ដោះស្រាយនៅពេលដែលភាគីបង្កើតវិធាននីតិវិធីដោយខ្លួនឯង អត្រានៃការព្រមព្រៀងនឹងរឹតតែខ្ពស់ថែមទៀត ។[52]

២.៣.៤.១ ការផ្តួចផ្តើមសន្ធានកម្ម

ដំណាក់កាលដំបូងបំផុតនៅក្នុងសន្ធានកម្មនីមួយៗ គឺការផ្តួចផ្តើមសន្ធានកម្មដូចគ្នានឹងដំណើរការការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃទៀតដែរ សន្ធានកម្មតែងកើតឡើងប្រសិនបើមានកាលៈទេសៈណាមួយក្នុងចំណោមបីខាងក្រោមកើតឡើង៖

១. ភាគីវិវាទមានខចែងស្តីពីដំណោះស្រាយវិវាទនៅក្នុងកិច្ចសន្យា ដែលមានស្រាប់របស់ពួកគេដែលបានជ្រើសរើសយកមធ្យោបាយសន្ធានកម្មមកប្រើ។

២. ភាគីវិវាទសម្រេចចិត្តធ្វើសន្ធានកម្ម បន្ទាប់ពីវិវាទបានកើតឡើង ឬ

[49] ដូចលេខ៥០

[50] ដូចលេខ៥០

[51] ដូចលេខ៥០

[52] ដូចលេខ៥០

៣. តុលាការបានបង្គាប់ ឬណែនាំឱ្យភាគីវិវាទធ្វើសន្ធានកម្ម ។

នៅក្នុងកាលៈទេសៈ ភាគីវិវាទដែលផ្តួចផ្តើមសន្ធានកម្មត្រូវផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរដើម្បីសម្រុះសម្រួលវិវាទនោះ។ លិខិតអញ្ជើញនោះអាចដាក់បញ្ចូលនូវការស្នើឡើងអំពីទីតាំង និងវិធានសម្រាប់សន្ធានកម្មនោះ រីឯភាគីម្ខាងទៀតអាចយល់ព្រមតាមការអញ្ជើញ ឬបដិសេធការស្នើ។ ប្រសិនបើភាគីម្ខាងទៀតយល់ព្រមនោះភាគីទាំងពីរត្រូវចាប់ផ្តើមកំណត់វិធាន និងស្វែងរកសន្ធានការី។ ប្រសិនបើភាគីម្ខាងទៀតបដិសេធសន្ធានកម្មនឹងមិនកើតមានឡើយ ហើយភាគីអាចអនុវត្តវិធីផ្សេងទៀត។ ប្រសិនបើភាគីមានខស្តីពីសន្ធានកម្មនៅក្នុងកិច្ចសន្យាពីមុនមក ហើយភាគីម្ខាងបដិសេធមិនព្រមធ្វើសន្ធានកម្មនោះ ភាគីម្ខាងទៀតអាចស្វែងរកសេចក្តីបង្គាប់ពីតុលាការដែលតម្រូវឱ្យធ្វើសន្ធានកម្ម។ សេចក្តីបង្គាប់របស់តុលាការបែបនេះនឹងតម្រូវឱ្យភាគីចូលរួមយកសន្ធានកម្ម ប៉ុន្តែមិនអាចបង្គាប់ឱ្យភាគីត្រូវតែយល់ព្រមដោះស្រាយនៅក្នុងសន្ធានកម្មនោះឡើយ ។

វិធានរបស់ UNCITRAL បានកំណត់ថា ប្រសិនបើភាគីដែលផ្តួចផ្តើមការសម្រុះសម្រួលមិនទទួលបានចម្លើយតបនៅក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃផ្ញើលិខិតអញ្ជើញនោះ ឬក្នុងរយៈពេលមួយដែលមានចែងនៅក្នុងលិខិតអញ្ជើញនោះ ភាគីនោះអាចចាត់ទុកថា ភាគីម្ខាងទៀតបដិសេធចំពោះការអញ្ជើញឱ្យមកធ្វើការសម្រុះសម្រួលនោះ ប្រសិនបើភាគីនោះបានចាត់ទុកថាដូច្នេះ ភាគីនោះត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត។ ប្រសិនបើតុលាការបានបង្គាប់ឱ្យមានសន្ធានកម្មដែលពាក់ព័ន្ធនឹងកម្មវិធីសន្ធានកម្មចំណុះឱ្យស្ថាប័នតុលាការ នោះតុលាការទំនងជានឹងផ្តល់ដល់ភាគីនូវសន្ធានការី និងវិធានអនុវត្តន៍ផងដែរ ។[53]

២.៣.៤.២ ការជ្រើសរើសសន្ធានការី

បន្ទាប់ពីសន្ធានកម្មត្រូវបានបង្កើតឡើងជាយន្តការដំណោះស្រាយវិវាទរួចមក ភាគីវិវាទត្រូវតែជ្រើសរើសយកសន្ធានការីមួយរូប។ ប្រសិនបើពួកគេយល់ព្រមប្រើប្រាស់មជ្ឈមណ្ឌលសន្ធានកម្មជាក់លាក់ណាមួយនោះ ដូចជាមជ្ឈមណ្ឌលសន្ធានកម្មនៃប្រទេសសិង្ហបុរី វិធានរបស់មជ្ឈមណ្ឌលនោះនឹងកំណត់ថា តើមានសន្ធានការីណាខ្លះដែលអាចធ្វើបាន ព្រមទាំងរបៀបជ្រើសរើសពួកគេផងដែរ ។ យ៉ាងណាមិញ គេក៏អាចធ្វើសន្ធានកម្មដែលមានសន្ធានការីពីរនាក់ ឬរហូតដល់បីនាក់ផងក៏បាន លើកលែងតែមានមូលហេតុច្បាស់លាស់ក្នុងការធ្វើបែបនេះជាទូទៅ គេគួរធ្វើវាជាមួយសន្ធានការីតែម្នាក់តែប៉ុណ្ណោះ។ ប្រសិនបើភាគីមិនមានការព្រមព្រៀងក្នុងការជ្រើសរើស

---

[53] Douglas Henderson, "ភាពជោគជ័យនៃការសម្រុះសម្រួល ការវិភាគដែលសំអាងលើការពិសោធន៍" លេខ១១ ទំព័រ ១៥០ ឆ្នាំ១៩៩៦

សន្ធានការីណាម្នាក់ទេ មជ្ឈមណ្ឌលសន្ធានកម្ម អាចតែងតាំងសន្ធានការីម្នាក់សម្រាប់រឿងវិវាទនោះ ផងដែរ។[54] ភាគីអាចធ្វើការពិចារណានៅពេលខ្លួនធ្វើការជ្រើសរើសសន្ធានការី ដូចជាថាតើសន្ធានការីនោះមានអព្យាក្រឹត បទពិសោធន៍ ចំណេះជំនាញ ពូកែស្តាប់ ឬ ជាអ្នកពូកែបញ្ចុះបញ្ចូលជាដើម។

២.៣.៤.៣ ការប្រជុំជាឯកជន

ប្រសិនបើសន្ធានកម្មនៅនឹងថ្កល់មួយកន្លែង ដោយសារការជៀសវាងការសម្រេចចិត្ត ឬមូលហេតុផ្សេងទៀត មានដំណោះស្រាយជានីតិវិធីរួមមួយដែលសន្ធានការីអាចនឹងប្រើប្រាស់ គឺការប្រជុំជាឯកជន។ ជាទូទៅការប្រជុំជាឯកជនធ្វើឡើងក្នុងកំឡុងពេល ដែលភាគីកំពុងពិភាក្សាគ្នារកដំណោះស្រាយដែលអាចធ្វើបានចំពោះបញ្ហាវិវាទរបស់ខ្លួន។ វាមិនមែនជារឿងចម្លែកនោះទេ ដែលសន្ធានការីត្រូវជួបប្រជុំជាឯកជនចំនួនប្រាំ ឬរហូតដល់ដប់ដងនៅក្នុងពេលមានសន្ធានកម្មដែលលំបាកនោះ ជាទូទៅប្រសិនបើសន្ធានការីជួបប្រជុំគ្នាជាឯកជនជាមួយភាគីម្ខាង គាត់នឹងជួបប្រជុំជាឯកជនជាមួយភាគីម្ខាងទៀតដែរ។ បន្ទាប់ពីមានការប្រជុំជាឯកជនទាំងពីរនេះ សន្ធានការីអាចកោះប្រជុំជាក្រុមរួម ឬបន្តជួបប្រជុំជាឯកជនចុះឡើងតទៅទៀត។

ជំនួបឯកជនអនុញ្ញាតឱ្យភាគីចែករំលែកព័ត៌មានឯកជនជាមួយសន្ធានការី ដែលពួកគេអាចមានភាពមិនស្រួលក្នុងចិត្តដើម្បីចែករំលែកនៅចំពោះមុខភាគីម្ខាងទៀត។ តាមទស្សនៈរបស់សន្ធានការីការប្រជុំជាឯកជនអនុញ្ញាតឱ្យខ្លួនទទួលបាននូវជំនឿទុកចិត្តកាន់តែខ្លាំងពីអ្នកចូលរួម។ សន្ធានការីអាចបង្ហាញនូវការយល់ចិត្តកាន់តែច្រើនចំពោះភាគីវិវាទនៅក្នុងកំឡុងពេលប្រជុំជាឯកជននោះដែល ប្រហែលជាគាត់មិនអាចធ្វើបែបនេះបានឡើយនៅក្នុងសម័យប្រជុំជាក្រុម ដោយខ្លាចថាខ្លួននឹងមានកាយវិការលម្អៀង។ ចំពោះបរិយាកាសឯកជនក៏អនុញ្ញាតឱ្យសន្ធានការីមានលទ្ធភាពទម្លាក់ជំហររបស់ភាគីកាន់តែខ្លាំង និងបង្ខំពួកគេឱ្យពិចារណាយ៉ាងហ្មត់ចត់នូវអ្វីដែលភាគីម្ខាងទៀតបានស្នើឡើង សន្ធានការីថែមទាំងអាចស្នើឡើងនូវដំណោះស្រាយសក្តានុពលនានានៅក្នុងជំនួបជាឯកជននោះដែលអាចហាក់មានភាពលម្អៀង ឬមិនសមស្របប្រសិនបើការស្នើមានឡើងនៅក្នុងកិច្ចប្រជុំជាក្រុម។ បរិយាកាសឯកជនក៏លើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនពីសំណាក់ភាគីខ្លួនឯងពីព្រោះជាញឹកញាប់មេធាវី ជាអ្នកដែលនិយាយនៅក្នុងការប្រជុំជាក្រុម (ជួនកាលមេធាវីប្រាប់កូនក្តីរបស់ខ្លួនកុំឱ្យនិយាយអ្វីទាំងអស់ លុះត្រាតែពួកគេឱ្យនិយាយ) ។

[54] វិធានផ្សះផ្សានៃគណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ មាត្រា ២(៤) ឆ្នាំ១៩៨០

ជំនួបឯកជនមិនមានភាពចាំបាច់ហួតនោះទេ ប៉ុន្តែជាញឹកញាប់វាមានសារៈប្រយោជន៍ក្នុងការជួយឱ្យភាគីស្ថិតនៅជាមួយគ្នា ជាពិសេសប្រសិនបើពួកគេជួបប្រទះនឹងស្ថានភាពទ័លច្រក។ លក្ខខណ្ឌសមស្របបំផុតដែលជំនួបឯកជនមានភាពចាំបាច់មានដូចខាងក្រោម៖

- នៅពេលដែលមានភាគីវិវាទច្រើនជាងពីរ ដូចជាក្នុងរឿងក្តីខូចខាតទ្រព្យសម្បត្តិដែលមានដើមបណ្តឹងដែលជាអ្នកទទួលរងការខូចខាត ចុងចម្លើយដែលគេចោទថាបានបង្កការខូចខាត និងក្រុមហ៊ុនធានារ៉ាប់រងជាដើម។
- នៅពេលវិវាទមានភាពស្មុគស្មាញខ្លាំង
- នៅពេលមានភាពខុសគ្នាខ្លាំងនៅក្នុងតុល្យភាពនៃអំណាច
- នៅពេលភាគីរំលោភបំពាន ឬគំរាមកំហែងគ្នាទៅវិញទៅមក នេះគឺជាមូលហេតុទូទៅបំផុតសម្រាប់ជំនួបជាឯកជន។[55]

២.៣.៤.៤ ការបញ្ចប់សន្ទានកម្ម

សន្ទានកម្មនឹងបញ្ចប់ដោយមានលទ្ធផលដូចខាងក្រោម៖

១. ភាគីបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង។

២. ភាគីមិនបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ប៉ុន្តែនឹងបន្តសន្ទានកម្មនៅពេលក្រោយ ឬ

៣. ភាគីបានឈានទៅដល់ស្ថានភាពជាប់គាំង ហើយសន្ទានកម្មត្រូវបានបញ្ចប់ ។

នៅក្នុងករណីទីមួយ សន្ទានការីនឹងលើកទឹកចិត្តឱ្យភាគីធ្វើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយមួយ។ ភាគីអាចទទួលរងសម្ពាធពីគ្រួសារ មិត្តភក្តិ ឬមិត្តរួមការងារឱ្យបន្តទាមទារផលប្រយោជន៍កាន់តែច្រើនជាងនោះ ប្រសិនមិនបានចុះកិច្ចព្រមព្រៀង។

ភាគីខ្លួនឯងផ្ទាល់គួរជាអ្នកធ្វើព្រាងនូវកិច្ចព្រមព្រៀងនោះ ប្រសិនបើសន្ទានការីជាអ្នកព្រាងកិច្ចព្រមព្រៀង គាត់អាចប្រថុយជាមួយនឹងការលម្អៀងទៅ ពាក្យពេចន៍ដែលគាត់ជ្រើសរើសយកដែលសន្ទានការីយកមកប្រើ។ សន្ទានការីគួរសរសេរចូលនូវចំណុចភាគីម្ខាង ដោយសារជាមូលដ្ឋាននៃកិច្ចព្រមព្រៀងនៅចុងបញ្ចប់សម័យ

[55] ដូចលេខ១៧ ទំ.១១៩

ប្រជុំដើម្បីឱ្យភាគីចុះហត្ថលេខាលើនោះ ហើយទុកពេលវេលាដល់ភាគីជាអ្នកធ្វើព្រាងកិច្ចព្រមព្រៀងទាំងមូលដោយខ្លួនឯង ហើយសន្ធានការីអាចជួយត្រួតពិនិត្យកិច្ចព្រមព្រៀងនោះបាន។

ទោះបីជាសន្ធានកម្ម ជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ដោះស្រាយ ក៏ទីបំផុតគឺវាអាស្រ័យតែទៅលើភាគីវិវាទខ្លួនឯង ហើយវិវាទមួយចំនួនក៏មិនអាចយកមកសម្រុះសម្រួលដោយជោគជ័យដែរនៅពេលសន្ធានកម្មត្រូវបានបញ្ចប់បែបនេះ ភាគីមានសេរីភាពក្នុងការបន្តវិវាទរបស់ពួកគេនៅក្នុងវេទិកាផ្សេងទៀត ដូចជាមជ្ឈត្តការ ការចរចាជាឯកជន ព្រមទាំងបណ្តឹងទៅតុលាការ ។[56]

២.៣.៥ គុណសម្បត្តិ និងគុណវិបត្តិ

ការធ្វើនូវសន្ធានកម្មបានផ្តល់នៅគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនដូចជា៖

គុណសម្បត្តិ

- **ឆាប់រហ័ស** សន្ធានកម្មអនុញ្ញាតឱ្យភាគីដោះស្រាយវិវាទលំបាកៗក្នុងរយៈពេលដ៏ខ្លី ជាទូទៅក្នុងរយៈពេលមួយថ្ងៃ ឬច្រើនជាងនេះ
- **ការចំណាយ** ការចំណាយសម្រាប់សន្ធានកម្មក៏នៅតែមានតម្លៃទាបជាងជម្រើសដទៃទៀត ដោយសាររយៈពេលដោះស្រាយត្រឹមមួយ ឬពីរថ្ងៃ
- **ការរក្សាសម្ព័ន្ធភាពជាបន្ត** សន្ធានកម្មអនុញ្ញាតឱ្យភាគីអាចរៀបចំដំណោះស្រាយមួយដែលអាចរក្សាសម្ព័ន្ធភាពរបស់ពួកគេជាបន្តទៅទៀតបាន
- **ភាពជាឯកជន** នៅក្នុងដំណើរការសន្ធានកម្ម គឺតម្រូវឱ្យរក្សាជាការសម្ងាត់ យុត្តាធិការជាច្រើនផ្តល់ការការពារដល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការចរចា ឬសន្ធានកម្ម
- **លទ្ធភាពបត់បែន** ភាគីវិវាទ មានលទ្ធភាពបត់បែនជាច្រើនក្នុងការរៀបចំដំណើរការសន្ធានកម្ម។ សន្ធានការី អាចដើរតួនាទីត្រឹមតែជួយសម្របសម្រួលធម្មតាដោយស្គាល់ភាគីនីមួយៗ និងលើកទឹកចិត្តដល់ពួកគេ ។

[56] ដូចលេខ១៧ ទំ.១២១

- **ការអនុវត្តដំណោះស្រាយ** ជាទូទៅកិច្ចព្រមព្រៀងដែលកើតពីសន្ធានកម្មដែលចំណុះឱ្យស្ថាប័នតុលាការអាចយកមកអនុវត្តដូចសាលក្រមតុលាការដែរ ហើយមានន័យថាវាមានដំណើរការអនុវត្តឆាប់រហ័ស។[57]

គុណវិបត្តិ

- **អំណាចនៃការសម្រុះសម្រួលមិនស្មើភាពគ្នា** ប្រសិនបើភាគីមានអំណាចសម្រុះសម្រួលមិនស្មើភាពគ្នា វាអាចធ្វើឱ្យភាគីម្ខាងទៀតដែលទុនខ្សោយងាយទទួលរងនូវការគំរាមកំហែង ឬការធ្វើកិច្ចព្រមព្រៀងលើដំណោះស្រាយនោះមានភាពអយុត្តិធម៌
- **ប្រសិទ្ធភាពនៃការអនុវត្តដំណោះស្រាយ** តាមយុត្តាធិការនីមួយៗ ដំណោះស្រាយតាមរយៈសន្ធានកម្ម មានលក្ខណៈជាឯកជនខ្លះ និងខ្លះមិនអាចមានវិធានអនុវត្តឆាប់រហ័ស
- **ការចំណាយ** ប្រសិនបើវិវាទបានកើតឡើងជាទូទៅសន្ធានការី គឺជាភាគីអព្យាក្រឹត្យដែលយកថ្លៃឈ្នួល
- **ភាពជាឯកជន** ការទំនាក់ទំនងរវាងភាគីពាក់ព័ន្ធនឹងសន្ធានកម្មអាចនិងមិនត្រូវបានរក្សាជាការសម្ងាត់ ។[58]

**<u>ករណីសិក្សា</u>**

ឈុត លីសា អាយុ ២០ឆ្នាំ មកពីខេត្តស្វាយរៀងបានមករស់នៅទីក្រុងភ្នំពេញក្នុងឆ្នាំ២០១៣ ជាមួយប្អូនស្រី ដើម្បីស្វែងរកការងារធ្វើនៅរោងចក្រកាត់ដេរ។ នាងធ្វើការនៅក្រុមហ៊ុន **Din Han Enterprise Co,.Ltd** ដែលជារោងចក្រផលិតអាវម៉ាក **Adidas** ។ នាងបានលើកឡើងថា កម្មកររោងចក្រកាត់ដេរជាច្រើននាក់ដែលកំពុងធ្វើការយ៉ាងលំបាកក្នុងការទទួលបានប្រាក់ឈ្នួលទាប ហើយនៅតែមិនអាចបង់ថ្លៃឈ្នួលផ្ទះ ម្ហូប និងផ្ញើប្រាក់ទៅគ្រួសាររបស់ពួកគេ ដោយសង្ឃឹមថាស្ថានភាពរបស់ពួកគេនឹងផ្លាស់ប្តូរក្នុងពេលឆាប់ៗនេះដោយការដោះស្រាយពីសំណាក់ក្រុមហ៊ុន **DIN HAN**។ ក្រុមហ៊ុនក៏បានចាត់តំណាង

---

[57] Austermiller, "សន្ធានការីដែលពុករលួយនៅតែអាចព្យាយាមបង្ខំឱ្យភាគីព្រមព្រៀង តាមរយៈឧបាយកលដោះខ្លួន ឬការបង្ខិតបង្ខំ" លេខ៨៥ ទំព័រ១៤២

[58] betty southard Murphy, "ផលប៉ះពាល់នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទៅលើពាណិជ្ជកម្មអន្តរជាតិ" លេខ ៤៨ ទំព័រ៦៨.៧៣ ឆ្នាំ១៩៩៣

សន្ធានការីរបស់ខ្លួនធ្វើការសម្រុះសម្រួលជាមួយកម្មកររោងចក្រទាំងនោះ ដោយអ្នកសម្រុះសម្រួលត្រូវចរចាជាមួយនិយោជក ដើម្បីថែរក្សាកម្មករទាំងនោះឱ្យបានល្អប្រសើរ ជាពិសេសប្រសិនបើពួកគេមកពីខេត្តដែលប្រឈមនឹងបញ្ហាជាមួយនឹងការចំណាយប្រចាំខែរបស់ពួកគេ។ គួរបញ្ជាក់ផងដែរថា ក្រោយពីមានការចរចាដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករកាត់ដេរ ជាមួយសន្ធានការីដោយធ្វើការទាមទារយ៉ាងតិច ២១៤ ដុល្លារក្នុងមួយខែ ប៉ុន្តែជុំវិញការធ្វើសន្ធានកម្មអស់ជាច្រើនដងមកនោះ ក្រុមហ៊ុន **Din Han**និងកម្មករក៏បានព្រមព្រៀងឈានដល់លទ្ធផលបានត្រឹមតែ១៩៤ ដុល្លារប៉ុណ្ណោះជាប្រាក់ខែគោលរបស់ពួកគេ។ សន្ធានការីក៏ផ្ដល់យោបល់ថា ការដំឡើងប្រាក់ឈ្នួលសម្រាប់កម្មករកាត់ដេរ នឹងត្រូវបានទទួលយកដោយនិយោជកដោយសារនេះជាមួយផ្នែកនៃអតិផរណានៅក្នុងប្រទេសទាំងមូល។[59]

## ២.៤ មជ្ឈត្តការ

ជាគោលការណ៍ ការដោះស្រាយវិវាទតាមវិធីមជ្ឈត្តការត្រូវធ្វើឡើងតាមវិធានដែលគ្រប់គ្រងទៅលើការដោះស្រាយវិវាទតាមរយៈអាជ្ញាកណ្ដាលនៃប្រទេសកម្ពុជា។ ក្នុងនោះ ការដោះស្រាយត្រូវតែគោរពទៅតាមនីតិវិធីច្បាស់លាស់ដែលមានចែងក្នុងច្បាប់ ហើយការដោះស្រាយក៏មានលក្ខណៈដូចតុលាការដែរ ដោយក្នុងរូបភាជាសវនការ និងមានសិទ្ធិចេញសេចក្ដីសម្រេចដូចគ្នា តែសេចក្ដីសម្រេចរបស់អាជ្ញាកណ្ដាល ឬមជ្ឈត្តវិនិច្ឆ័យមិនមានលក្ខណៈដូចទៅនឹងសេចក្ដីសម្រេចរបស់តុលាការឡើយ។[60]

### ២.៤១ និយមន័យ

យោងតាមមាត្រា២(ក) នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬនៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។[61]

មជ្ឈត្តការត្រូវបានគេចាត់ទុកថា ជាយន្តការដែលមានប្រសិទ្ធិភាពក្នុងចំណោមយន្តការនៃការដោះស្រាយវិវាទផ្សេងទៀតដូចជា ការចរចា ការធ្វើសន្ធានកម្ម ឬការផ្សះផ្សា។ តាមរយៈយន្តការនេះ ភាគីវិវាទអាចធ្វើការជ្រើសរើស ភាសា ស្ថាប័នដោះស្រាយវិវាទ ច្បាប់ និងវិធានសម្រាប់ប្រើប្រាស់ក្នុងនីតិវិធីនៃការដោះស្រាយវិវាទ

---

59 Yin Soeum, "Garment workers reveal how wages don't cover living costs - Khmer Times",2021.
https://www.khmertimeskh.com/50949774/garment-workers-reveal-how-wages-dont-cover-living-costs/

60 ការដោះស្រាយក្រៅប្រព័ន្ធតុលាការ រៀបរាងដោយ៖ បេក្ខអនុបណ្ឌិតច្បាប់ កៅ សីហា ឆ្នាំ២០១០

61 ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ០៦ មីនា ២០០៦ មាត្រា២(ក)

របស់ខ្លួនទាំងមូល។ បន្ថែមពីលើនេះ នីតិវិធី និងព័ត៌មានរបស់ភាគីពាក់ព័ន្ធនៅក្នុងយន្តការនៃការដោះស្រាយវិវាទនេះនឹងត្រូវបានរក្សាជាសម្ងាត់។[62]

២.៤ ២.ដំណើរការមជ្ឈត្តការ

ក្នុងការរៀបចំដំណើរការមជ្ឈការនៃប្រទេសកម្ពុជា បានផ្តល់សិទ្ធិសេរីភាពដល់ភាគីវិវាទក្នុងការជ្រើសរើស មិនថាទីកន្លែង ច្បាប់ ភាសា គឺភាគីនៃវិវាទមានសិទ្ធិក្នុងការធ្វើការព្រមព្រៀងគ្នា និងអាចកំណត់បាន។[63]

២.៤.២.១ វេទិកាមជ្ឈត្តកម្ម

វេទិកានេះ គឺសំដៅទៅលើវេទិកាមជ្ឈត្តកម្មដែលត្រូវបានបង្កើតឡើងក្រោមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងវេទិកានេះត្រូវមានមជ្ឈត្តករមួយរូប ឬច្រើនរូបដែលត្រូវបានជ្រើសតាំងដោយភាគីវិវាទ ឬដោយគណៈកម្មាធិការតែងតាំងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ នៅក្នុងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទវិវាទមានសិទ្ធិសេរីភាពពេញលេញក្នុងការជ្រើសរើសនូវចំនួនមជ្ឈត្តការក៏ដូចជា ការកំណត់នូវលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលនឹងត្រូវចូលខ្លួនមកធ្វើការដោះស្រាយវិវាទ ទោះបីជាច្បាប់បានផ្តល់សិទ្ធិសេរីភាពទាំងនេះជូនភាគីវិវាទវិវាទមែនតែច្បាប់នៅតែបានបញ្ញត្តិលម្អិតលើសិទ្ធិសេរីភាពទាំងអស់នោះផងដែរ។[64]

២.៤.២.២ ទីកន្លែង និងភាសា ក្នុងដំណើរការមជ្ឈត្តការ

ក្នុងករណីដែលគូវិវាទមិនបានធ្វើការព្រមព្រៀងជ្រើសយកទីកន្លែងណាមួយ នោះវេទិកាមជ្ឈត្តកម្មនឹងធ្វើការពិចារណាទៅលើលក្ខណៈពិសេសនៃវិវាទ ឬកាលៈទេសៈនានាជុំវិញសំណុំរឿងដើម្បីធ្វើការកំណត់យកទីកន្លែងមជ្ឈត្តការដែលធ្វើឡើងដោយវេទិកាមជ្ឈត្តកម្មនេះ ក៏ត្រូវទទួលបានការឯកភាពពីភាគីវិវាទផងដែរ។[65] ជាទូទៅ ទីកន្លែងមជ្ឈត្តការនៃមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងក្រោមវិធាននេះ គឺធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា វៀរលែងតែមានករណីដូចដែលរៀបរាប់ខាងលើ។[66] ចំណែក ភាសាក្នុងដំណើរ

---

[62] ដូចលេខ៤៦

[63] ឯកសារកម្មវិធីមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្ម ម៉ូឌុលទី២ ស្តីពីការចាប់ផ្តើមដំណើរការមជ្ឈត្តការ និងវេទិកាមជ្ឈត្តកម្ម

[64] ដូចលេខ៦១ មាត្រា១៥

[65] ដូចលេខ៦១ មាត្រា១៦

[66] ដូចលេខ៦១ មាត្រា១៦

ការមជ្ឈត្តការមានលក្ខណៈមិនខុសគ្នាប៉ុន្មានពីទីកន្លែង និងច្បាប់សម្រាប់ប្រើប្រាស់ក្នុងវេទិកាមជ្ឈត្តកម្មដែរ ដោយភាគីវិវាទនៃវិវាទមានសិទ្ធក្នុងការសម្រេច និងកំណត់ទៅតាមភាសាដែលចង់បាន។[67]

២.៤.២.៣ វិធានស្ដីពីនីតិវិធី

ភាគីវិវាទអាចព្រមព្រៀង ឬមិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ។ ករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណា ដែលវេទិកាយល់ឃើញថាសមស្របដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មរួមមានអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ។[68]

២.៤.២.៤ ការកំណត់ច្បាប់ដែលគ្រប់គ្រងដំណើរការ

ភាគីមានសិទ្ធិព្រមព្រៀងជាមុនក្នុងការព្រមព្រៀងកំណត់យកច្បាប់ចម្បងដែលនឹងគ្រប់គ្រងដំណើរការនេះ ដែលហៅថាការកំណត់នេះថាប្បញ្ញត្តិស្ដីពីជម្រើសនៃច្បាប់។ ប្រសិនបើភាគីពុំបានកំណត់នូវជម្រើសច្បាប់នេះជាមុនទេ នៅពេលមានវិវាទកើតឡើងគេអាចព្រមព្រៀងគ្នាជ្រើសរើសវិធានច្បាប់ណាមួយដែលអាចអនុវត្តទៅលើកម្មវត្ថុនៃវិវាទបាន។[69]

២.៤.២.៥ ការដាក់ឯកសារជូនវេទិកាមជ្ឈត្តកម្ម

ក្នុងរយៈពេលដែលភាគីវិវាទ បានកំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្ដឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុដើម្បីគាំទ្រការទាមទាររបស់ខ្លួន ព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសារលើចំណុចនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្ដឹងទាមទារ ឬការដោះស្រាយត្រូវបញ្ជាក់ផ្សេងពីនេះ។[70]

ភាគីវិវាទ អាចភ្ជាប់ឯកសារទាំងអស់ដែល ទាក់ទងនឹងពាក្យបណ្ដឹងទាមទារ ឬការដោះស្រាយ ឬអាចបន្ថែមការយោងលើឯកសារ ឬភស្តុតាងដទៃទៀតដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម។ លើកលែង

[67] ដូចលេខ៦១ មាត្រា១៧

[68] ដូចលេខ៦១ មាត្រា២៧

[69] វិធាន១៧.១ វិធានស្ដីពីមជ្ឈការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ ថ្ងៃទី ១១ កក្កដា ឆ្នាំ២០១៤

[70] ដូចលេខ៦១ មាត្រា៣១

តែភាគីបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬបំពេញបន្ថែមលើពាក្យបណ្ដឹងទាមទារ ឬពាក្យដោះសាររបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យាពេលដើម្បីកែសម្រួលនេះ ពុំមានលក្ខណៈសមស្រប។[71]

២.៤.២.៦ ការជូនដំណឹងគ្នាទៅវិញទៅមក

យោងតាមច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីវិវាទត្រូវបង្ហាញពត៌មានដល់គ្នាទៅវិញទៅមកនូវរាល់សេចក្ដីថ្លែងឯកសារ ឬពត៌មានដទៃទៀត ដែលបានដាក់ជូនវេទិកាមជ្ឈត្តកម្ម។ មុនពេលមានសវនការមជ្ឈត្តការណាមួយ ភាគីវិវាទមានឱកាសក្នុងការត្រួតពិនិត្យសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ ឬឯកសារផ្សេងៗ។[72]

២.៤.២.៧ អ្នកជំនាញ

ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានផ្ដល់សិទ្ធិអំណាចដល់មជ្ឈត្តករក្នុងការតែងតាំងអ្នកជំនាញ លើកលែងតែភាគីវិវាទបានយល់ព្រមផ្សេងពីនេះ។ ភាគីវិវាទត្រូវផ្ដល់ដល់អ្នកជំនាញនូវពត៌មានដែលពាក់ព័ន្ធទាំងអស់ និងមានសិទ្ធត្រួតពិនិត្យអ្នកជំនាញនោះនៅពេលសវនការ ក្រោយពេលសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញនោះត្រូវបានដាក់ជូនទៅវេទិកាមជ្ឈត្តកម្មរួច។[73]

២.៤.២.៨ សវនាការមជ្ឈត្តការ

នៅក្នុងដំណើការមជ្ឈត្តការ ភាគីវិវាទតែងធ្វើសេចក្ដីថ្លែងបើក ដែលបញ្ជាក់ពីអង្គហេតុ និងអង្គច្បាប់ បន្ទាប់មកភាគីប្ដឹងធ្វើការបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួន។ សាក្សីត្រូវការស្បថដូចនៅតុលាការដែរ។ ភាគីប្ដឹងបានបង្ហាញនូវភស្តុតាងទាំងអស់របស់ខ្លួនរួច ភាគីឆ្លើយតបនឹងបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួនវិញម្ដង។ វេទិកាមជ្ឈត្តកម្ម និងភាគីប្ដឹងក៏អាចសួរសំណួរទៅសាក្សីទាំងនោះបានដែរ ។ បន្ទាប់មក គូភាគីនឹងផ្លាស់វេនគ្នាធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ ហើយបន្ទាប់ពីនោះមក វេទិកាមជ្ឈត្តកម្មនឹងពិភាក្សាដើម្បីសម្រេចរឿងក្ដីនេះ ។[74]

ប្រសិនបើគូភាគីយល់ព្រម ពួកគេមិនចាំបាច់ធ្វើសវនាការផ្ទាល់មាត់នោះទេ គូភាគីអាចជ្រើសរើសធ្វើត្រឹមតែការបង្ហាញភស្តុតាងជាឯកសារ និងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដាក់ជូនវេទិកាមជ្ឈត្តកម្មដើម្បី

---

[71] ដូចលេខ៧០

[72] ដូចលេខ៦១ មាត្រា៣២

[73] ដូចលេខ៦១ មាត្រា ២៧

[74] ដូចលេខ៦១ មាត្រា៣២

ពិចារណាក៏បាន។ ប៉ុន្តែ ប្រសិនបើភាគីណាមួយចង់ឱ្យមានសវនាការផ្ទាល់មាត់នោះ ពេលនោះសវនាការផ្ទាល់មាត់ត្រូវតែធ្វើឡើង ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏តម្រូវឱ្យគូភាគីទទួលបាននូវការជូនដំណឹងអំពីសវនាការបែបនោះឱ្យបានគ្រប់គ្រាន់ផងដែរ។[75]

ក្រោយពេលសវនាការមជ្ឈត្តការបានបញ្ចប់សព្វគ្រប់ការធ្វើសេចក្តីសម្រេច យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីវិវាទអាចជ្រើសរើសច្បាប់ណាមួយនៃយុត្តាធិការមកអនុវត្តក៏បាន ក្នុងករណីដែលគ្មានបញ្ញត្តិស្តីពីជម្រើសនៃច្បាប់នោះទេ វេទិកាមជ្ឈត្តកម្មមានសេរីភាពក្នុងការជ្រើសរើសច្បាប់ណាមួយដែលខ្លួនយល់ថាសមស្របមកអនុវត្ត។[76]

<u>**ករណីសិក្សា**</u>

ជម្លោះរវាងក្រុមហ៊ុន **Parkson (Cambodia) Co,.Ltd (PCCO)** និងក្រុមហ៊ុន **Hassan (Cambodia) Development Co Ltd (HCDC)** ដោយជម្លោះរវាងក្រុមហ៊ុនទាំងពីរបានចាប់ផ្តើមនៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ ២០១៨ នៅពេលដែល Parkson Cambodia បានចេញសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មទៅ **Hassan cambodia** បន្ទាប់ពីគូភាគីបានធ្លាក់ក្នុងជម្លោះជុំវិញការពន្យារពេល ដែលត្រូវបានចោទប្រកាន់ទៅក្រុមហ៊ុន **Hassan cambodia** ក្នុងការប្រគល់ទីតាំងហាងថ្មីទៅក្រុមហ៊ុន **Parkson Cambodia** ។ យោងតាមភាគីទាំងពីរ ត្រូវបានគេសន្មត់ថាសំណង់នឹងត្រូវបានបញ្ចប់ និងប្រគល់កន្លែងនៅក្នុងអគារថ្មីមួយដែលត្រូវសាងសង់នៅចុងខែធ្នូ ឆ្នាំ២០១៦ ប៉ុន្តែបែរជាមានបញ្ហាចំពោះការប្រគល់មិនបានសម្រេច។ ហេតុដូច្នេះហើយទើបក្រុមហ៊ុន **Parkson Cambodia** បានបញ្ចប់កិច្ចព្រមព្រៀងជួលហើយបានចាប់ផ្តើមធ្វើមជ្ឈត្តកម្ម។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ក្រុមហ៊ុន **Parkson Cambodia** បានប្រកាសថាខ្លួនបានចេញសេចក្តីជូនដំណឹងអំពីអាជ្ញាកណ្តាលដល់ក្រុមហ៊ុន **Hassan cambodia** ក្រោមការដោះស្រាយវិវាទនៅឯមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី **(SIAC)** ជុំវិញការជួលនេះ។ ក្រុមហ៊ុន **Parkson Cambodia** បានបន្តទៀតថា នៅថ្ងៃទី១២ ខែធ្នូ

[75] ដូចលេខ៦១ មាត្រា ៣៦(១)

[76] ដូចលេខ៦១ មាត្រា ៣៦(២)

ឆ្នាំ២០១៨ ក្រុមហ៊ុន **Hassan cambodia** បានដាក់ពាក្យប្តឹងទៅក្រុមហ៊ុន **Parkson Cambodia** នៅឯសាលាដំបូងរាជធានីភ្នំពេញ ដើម្បីទាមទារសំណងចំនួន ១២.៤៤ លានដុល្លាអាមេរិក។ សាលក្រមនេះ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ប្រកាសនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ មុននឹងប្រកាសសាលក្រមក្រុមហ៊ុន **Parkson Cambodia** បានដាក់បណ្តឹងសាទុក្ខទៅសាលាឧទ្ធរណ៍ ដើម្បីផ្ទេរយុត្តាធិការរបស់សាលាដំបូងរាជធានីភ្នំពេញលើសំណុំរឿងលេខ២៥៧៧ ទៅកាន់យុត្តាធិការអាជ្ញាកណ្តាលមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបុរី **(SIAC)** ដោយសំណើបណ្តឹងឧទ្ធរណ៍នេះកំពុងរង់ចាំការសម្រេចពីសាលាឧទ្ធរណ៍កម្ពុជា។[77]

[77] Arjuna Chandran Shankar, "Parkson's Cambodian unit ordered to pay RM630 mil in damages to its landlord", 2020. https://www.theedgemarkets.com/article/parksons-cambodian-unit-ordered-pay-rm630-mil-damages-its-landlord

# ជំពូកទី៣
# ការប្រៀបធៀបពីដំណើរការនៃការដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការ

# ជំពូកទី៣

## ការប្រៀបធៀបពីដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

នៅក្នុងជំពូកនេះ នឹងធ្វើការប្រៀបធៀបយន្តការទាំងបួនដែលមានក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហើយតាមរយៈការប្រៀបធៀបនេះ ក៏នឹងបង្ហាញផងដែរនូវលក្ខណៈដូចគ្នា និងខុសៗគ្នានៃយន្តការទាំងនោះផងដែរ។ តាមការបកស្រាយខាងលើនេះ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានដូចជា ការចរចា សន្ធានកម្ម ការផ្សះផ្សា និងមជ្ឈត្តការ។

ខាងក្រោមនេះជាដំណើរការនៃការប្រៀបធៀបលក្ខណៈដូចគ្នា និងលក្ខណៈខុសៗគ្នា របស់ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងបួន។

៣១. ការប្រៀបធៀបការចរចា និងសន្ធានកម្ម

នៅក្នុងការប្រៀបធៀបអំពីការចរចា និងសន្ធានកម្មបានផ្តល់ឱ្យភាគីវិវាទនូវការសម្របសម្រួលមួយមុននឹងឈានទៅវិធីក្រោយៗទៀត។ ទោះបីការចរចា ជំហានដំបូងបង្អស់ក្នុងការដោះស្រាយបញ្ហារវាងភាគីវិវាទ ហើយសន្ធានកម្មជាជំហានបន្ទាប់ ដែលនឹងមានលក្ខណៈខុសគ្នាជាច្រើន ប៉ុន្តែដំណើរការរបស់វិធីទាំងពីរក៏នៅតែមានលក្ខណៈដូចគ្នានៅចំណុចខ្លះៗផងដែរ។ លក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នារបស់ដំណើរការទាំងពីរនេះមានដូចជា៖

**លក្ខណៈដូចគ្នា**

- **ការរក្សាទំនាក់ទំនងរបស់ភាគី** ការចរចា និងសន្ធានកម្ម មានគោលបំណងក្នុងការរក្សាទំនាក់ទំនងរបស់ឱ្យមានភាពល្អប្រសើរទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយភាគីនៃវិវាទ ឬភាគីទីបីសុទ្ធតែជួយភាគីវិវាទដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក ។
- **ការអនុវត្តដំណោះស្រាយ** ការចរចា និងសន្ធានកម្មមានលក្ខណៈដូចគ្នាទាំងស្រុង ដោយភាគីវិវាទការស្រុះស្រួលតាមរយៈការចរចាលើរឿងក្តីណាមួយ ហើយការស្រុះស្រួលនោះក៏អាចត្រូវបានកត់បញ្ចូលក្នុងនីតិវិធីតុលាការនៅចំពោះមុខចៅក្រម ហើយនឹងអាចអនុវត្តបាន ដូចសាលក្រមដែរ។ ហើយកិច្ចព្រមព្រៀងដែលកើតពីសន្ធានកម្មដែលចំណុះឱ្យស្ថាប័នតុលាការអាចយកមកអនុវត្តដូចសាលក្រម។

**លក្ខណៈខុសគ្នា**

**ក. ភាពឯកជន**

- **<u>ការចរចា</u>** ការចរចាមិនមានការចូលរួមពីសំណាក់ភាគីទីបីឡើយ ដោយវាជាដំណើរការឯកជនសុទ្ធសាធ ដោយមានការចូលរួមតែពីសំណាក់ភាគីដែលពាក់ព័ន្ធប៉ុណ្ណោះ លើកលែងតែមានករណីចាំបាច់តែប៉ុណ្ណោះ ដែលករណីនោះអាចនឹងប៉ះពាល់ដល់មនុស្ស ឬអាជីវកម្ម។[78]
- **<u>សន្ធានកម្ម</u>** សន្ធានកម្ម អនុញ្ញាតឱ្យភាគីទីបីដែលអព្យាក្រឹតតែងតែចូលរួមក្នុងដំណោះស្រាយនេះ និងធ្វើជាប្រធានកិច្ចប្រជុំជានិច្ច។

**ខ. ភាពបត់បែន**

- **<u>ការចរចា</u>** ភាគីវិវាទធ្វើការជាមួយគ្នាដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន។ គូវិវាទនៃជម្លោះតែងចូលរួមដោយប្រយោលតាមរយៈមេធាវីរបស់ពួកគេ ឬអ្នកតំណាងផ្សេងទៀត ហើយមានវត្តមានដោយផ្ទាល់តែពេលចុងបញ្ចប់ប៉ុណ្ណោះដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង។ [79] ការចូលរួមដោយប្រយោលនៅក្នុងការចរចាអាចអនុវត្តបានជាពិសេសនៅពេលដែលវិវាទនោះមានពាក់ព័ន្ធនឹងក្រុមហ៊ុនធំៗ ឬភាគីអន្តរជាតិ។[80] ការចរចាអាចកើតឡើងតាមរយៈទូរស័ព្ទ ទូរសារ លិខិត ឬការពិភាក្សាទល់មុខដោយផ្ទាល់។[81]
- **<u>សន្ធានកម្ម</u>** ភាគីទីបីធ្វើការជាមួយភាគីវិវាទដើម្បីរកដំណោះស្រាយដែលអាចទទួលយកបានទៅវិទៅមក។ គូវិវាទនៃជម្លោះត្រូវចូលរួមដោយផ្ទាល់ និងស្ទើតែគ្រប់ពេលទាំងអស់ក្នុងដំណើរការសម្រុះសម្រួល។ សន្ធានកម្ម អនុញ្ញាតឱ្យភាគីទីបីដែលអព្យាក្រឹតតែងតែធ្វើជាប្រធានកិច្ចប្រជុំជានិច្ច។[82]

**គ. ល្បឿន**

[78] ដូចលេខ១៧ ទំ.៩១

[79] ដូចលេខ៥៨

[80] ដូចលេខ៥៨

[81] ដូចលេខ៥៨

[82] ដូចលេខ៥៨

- **<u>ការចរចា</u>** អាចកើតឡើងក្នុងរយៈពេលជាច្រើនខែ ឬឆ្នាំ។ វាអាចចាប់ផ្តើម និងបញ្ចប់ដោយគ្មានការជូនដំណឹង ឬការត្រៀមខ្លួន។[83] ការចរចាអាចធ្វើឡើងពេលណាក៏បាន សូម្បីក្រោយពេលដែលវិវាទត្រូវបានវិនិច្ឆ័យរួច គ្មានកិច្ចប្រជុំឡើងវិញឡើយ ប្រសិនភាគីមិនអាចទទួលយកដំណោះស្រាយនោះក៏ដោយ។[84]
- **<u>សន្ធានកម្ម</u>** ជាព្រឹត្តការណ៍តែមួយ និងផ្លូវការដែលមានរយៈពេលមួយ ឬច្រើនថ្ងៃ។ វាមានដំណើរការចាប់ផ្តើម ពាក់កណ្តាល និងបញ្ចប់យ៉ាងច្បាស់លាស់។ ភាគីត្រូវតែយល់ព្រមចូលរួមនៅក្នុងសន្ធានកម្ម ហើយជាទូទៅត្រូវធ្វើផែនការសម្រាប់កិច្ចការនេះ ដោយកំណត់ពីសន្ធានការី ដំណើរការសន្ធានកម្ម កាលវិភាគ ថ្លៃឈ្នួល ក្នុងចំណោមអ្វីៗជាច្រើនទៀត។ (ប្រសិនបើមាន) មានកិច្ចប្រជុំដែលជាការហួសបន្លាយរយៈពេលនៃការដោះស្រាយកាន់តែយូរ ប្រសិនបើគូភាគីមិនឯកភាពគ្នា

**ឃ. ការចំណាយ**

- **<u>ការចរចា</u>** ជាទូទៅការចំណាយនៅក្នុងដំណើរការនៃការចរចាមានការចំណាយតិចជាងការដោះស្រាយវិវាទផ្សេងៗទៀត។
- **<u>សន្ធានកម្ម</u>** ការចំណាយច្រើនជាងការចរចា ព្រោះត្រូវចំណាយទៅលើថ្លៃឈ្នួលសម្រាប់ភាគីទីបីក្នុងការជួយក្នុងការដោះស្រាយនេះ។

**ង. គោលបំណងនៃការដោះស្រាយ**

- **<u>ការចរចា</u>** ភាគីវិវាទធ្វើការរកដំណោះស្រាយដើម្បីឱ្យមានការល្អប្រសើរនៅក្នុងវិវាទ និងឈានទៅការបញ្ចប់វិវាទដោយសន្តិវិធី និងភាគីវិវាទនៅតែមានទំនាក់ទំនងល្អប្រសើរ ហើយការដោះស្រាយនេះត្រូវធ្វើឡើងជាឯកជន។
- **<u>សន្ធានកម្ម</u>** ភាគីទីបីជួយភាគីឱ្យទទួលបានដំណោះស្រាយ និងការដោះស្រាយជាឯកជន។

៣២ ការប្រៀបធៀបការចរចា និងការផ្សះ.ផ្សា

[83] ដូចលេខ ៥៨

[84] ដូចលេខ ៥៨

នៅក្នុងការចរចា និងការផ្សះផ្សាបានបង្ហាញពីដំណើរការនៃការដោះស្រាយដែលមានលក្ខណៈខុសគ្នាច្រើន ដោយហេតុថា ការចរចាជាដំណាក់កាលដំបូងគេបង្អស់ក្នុងការស្រាយបញ្ហាដែលមានលក្ខណៈស្រាលនៅឡើយ រីឯការផ្សះផ្សាជាដំណាក់កាលមួយដែលភាគីវិវាទអាចនឹងឈានដល់ភាពចម្រូងចម្រាស់កាន់តែខ្លាំងជាងមុន ហើយមិនអាចដោះស្រាយដោយភាគីវិវាទនៃវិវាទបានឡើយ ដោយត្រូវការភាគីទីបីដើម្បីជាជំនួយក្នុងការដោះស្រាយបញ្ហាភាគីវិវាទ។ ការចរចា និងការផ្សះផ្សា ក៏មានលក្ខណៈដូច និងខុសគ្នាដូចគ្នាដូចតទៅៈ

លក្ខណៈដូចគ្នា

- **ការរក្សាទំនាក់ទំនងរបស់ភាគី** ស្ទើរតែគ្រប់ចំណុចនៃដំណើរនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សុទ្ធតែមានគោលបំណងក្នុងការជួយរក្សាទំនាក់ទំនងរបស់ភាគីឱ្យនៅតែមានភាពល្អប្រសើរ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ទោះបីការចរចា មានការធ្វើឡើងតែភាគីវិវាទ ហើយការផ្សះផ្សាធ្វើឡើងដោយមានភាគីទីមកសម្រួលក្តី។

លក្ខណៈខុសគ្នា

ក. ភាពឯកជន

- **ការចរចា** មានភាពជាឯកជនទាំងស្រុងដោយការធ្វើឡើងដោយភាគី និងភាគី ឬអ្នកតំណាងរបស់ពួកគេតែប៉ុណ្ណោះ។ គ្មានការចូលរួមពីតុលាការ គ្មានអ្នកសារពត៌មាន ឬអ្នកដទៃឡើយ ឬមេធាវីឡើយ លើកលែងតែភាគីនៃជម្លោះត្រូវការ ប៉ុន្តែការដោះស្រាយក៏ស្ថិតនៅក្នុងលក្ខណៈឯកជន ហើយវត្តមានមេធាវីនេះ លុះត្រាតែមានការចាំបាច់សម្រាប់មនុស្ស ឬអាជីវកម្មរបស់ពួកគេតែប៉ុណ្ណោះ។
- **ការផ្សះផ្សា** ភាពឯកជនមិនសូវពេញលេញដូចការចរចាឡើយ ពីព្រោះមានការចូលរួមពីភាគីទីបីជាអព្យាក្រឹត្យ និងពិចារណាទៅលើហេតុផលដែលជាសំអាងរបស់ភាគីទាំងពីរ រួចចេញសេចក្តីសម្រេចលើវិវាទនោះ។

ខ. ភាពបត់បែន

- **ការចរចា**នៅក្នុងដំណើរកា រនៃការចរចា ភាពបត់បែនទាំងក្នុងដំណើរការ និងលទ្ធផល។ ដោយដំណើរការមានលក្ខណៈបត់បែនយ៉ាងខ្លាំងដោយដំណើរការអាចធ្វើឡើងក្រៅផ្លូវការ ឬជាផ្លូវការ។ ការចរចា អាចធ្វើឡើងក្រៅផ្លូវការដោយមនុស្សពីរនាក់នៅតាមផ្លូវក៏អាចធ្វើបាន ហើយការចរចាដែលធ្វើឡើងជាផ្លូវការ ដោយភាគីវិវាទ និងមេធាវីរបស់ពួកគេផ្ញើរសំបុត្រជាលាយលក្ខណ៍អក្សរឱ្យគ្នាទៅវិញទៅមក។ ភាគីវិវាទ ជាអ្នកកំណត់លើដំណើរការចរចា

ដោយរបៀបណា ហើយលទ្ធផលមានការស្រុះស្រួលដែរ ឬទេ។ នៅក្នុងការចរចា ត្រូវតែមានការព្រមព្រៀងពីភាគីទាំងសងខាងដើម្បីដំណើរការក្នុងការចរចានោះ។

- <u>**ការផ្សះផ្សា**</u> នៅក្នុងដំណើរការនេះ អ្នកផ្សះផ្សារជាអ្នកជួយទៅភាគីទំនាស់ដើម្បីជ្រើសរើសដំណោះស្រាយទំកាន់តែល្អប្រសើរឡើង ហេតុនេះហើយទើប ភាពបត់បែនផ្អែកទៅតាមកាលៈទេសៈសមគួរ ដោយដំណោះស្រាយអាចធ្វើឱ្យភាគីទំនាស់ទទួលបាន។

**គ. ល្បឿន**

- <u>**ការចរចា**</u> ការចរចាមានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធិភាព។ មិនចាំបាច់ត្រូវរង់ចាំចៅក្រម មជ្ឈត្តករ ឬសន្ធានការី ដើម្បីធ្វើសវនការ និងសម្រេចលើរឿងក្តីនោះឡើយ។ បញ្ហាត្រូវបានដោះស្រាយភ្លាមៗ ឱ្យភាគីឈានដល់ការស្រុះស្រួលគ្នា។
- <u>**ការផ្សះផ្សារ**</u> ល្បឿននៃការផ្សះផ្សាអាចមិន លឿនដូចការចរចាឡើយ ដោយសារតែក្នុងដំណើរការនៃការផ្សះផ្សាធ្វើឡើងដោយមានការចូលរួមពីភាគីទីបីឡើយ ។

**ឃ. ការចំណាយ**

- <u>**ការចរចា**</u> ជានីតិវិធីដែលមានការចំណាយតិចជាងការដោះស្រាយវិវាទផ្សេងៗ ដោយនៅក្នុងដំណើរការនៃការរចរចាមិនត្រូវការចំណាយទៅលើប្រាក់ប្រដាប់ក្តី ឬការចំណាយផ្សេងៗឡើយ។
- <u>**ការផ្សះផ្សា**</u> មានការចំណាយច្រើនដោយថ្លៃចំណាយជាបន្ទុករបស់ភាគីទាំងសងខាងស្មើៗគ្នា ហើយប្រាក់ចំណាយទៅលើប្រាក់តម្កល់ និងថ្លៃឈ្នួលទៅលើដំណើរការផ្សះផ្សា ការធ្វើដំណើររបស់អ្នកផ្សះផ្សារ ថ្លៃពិគ្រោះជាមួយអ្នកផ្សះផ្សារ។

**ង. គោលបំណងនៃការដោះស្រាយ**

- <u>**ការចរចា**</u> ភាគីវិវាទធ្វើការរកដំណោះស្រាយដើម្បីឱ្យមានការល្អប្រសើរនៅក្នុងវិវាទនឹងឈានទៅការបញ្ចប់វិវាទដោយសន្តិវិធី និងភាគីវិវាទនៅតែមានទំនាក់ទំនងល្អប្រសើរ ហើយការដោះស្រាយនេះត្រូវធ្វើឡើងជាឯកជន។
- <u>**ការផ្សះផ្សា**</u> ផ្តល់ឱ្យភាគីនូវលទ្ធភាពក្នុងការសម្រេចមុន ថាគួរកំណត់យកយោបល់របស់អ្នកផ្សះផ្សា ឬលក្ខណៈកាត្វកិច្ចដែរឬទេ។

៣៣ ការប្រៀបធៀប ការចរចា និងមជ្ឈត្តការ.

ការចរចា និងមជ្ឈត្តការជាដំណើរការដែលមានការខុសគ្នាច្រើនដោយសារតែការចរចា ជានីតិវិធីនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការដំបូងគេបង្អស់ រីឯមជ្ឈត្តការជាដំណាក់កាលចុងក្រោយ ដែលធ្វើឡើងនៅពេលដែលភាគីវិវាទពុំអាចស្វែងរកដំណោះស្រាយនៅដំណាក់កាលដំបូង (ការចរចា) ទើបឈានដល់ការដោះស្រាយនៅមជ្ឈត្តការនេះ ប៉ុន្តែក៏នៅមានលក្ខណៈដូចគ្នាខ្លះៗផងដែរ។ លក្ខណៈដូចគ្នា និងខុសគ្នាមានដូចតទៅ៖

លក្ខណៈដូចគ្នា

- **ការរក្សាទំនាក់ទំនងរបស់ភាគី៖** ការចរចា និងមជ្ឈត្តការតែងតែចង់ឱ្យភាគីវិវាទវិវាទទួលបាននូវដំណោះស្រាយដែលល្អបំផុត ព្រមទាំងអាចឱ្យភាគីវិវាទទាំងពីរនៅតែរក្សាទំនាក់ទំនងបានល្អប្រសើររវាងគ្នា និងគ្នា។

លក្ខណៈខុសគ្នា

ក. ភាពឯកជន

- <u>ការចរចា</u> មិនមានការចូលរួមពីសំណាក់ភាគីទីបីឡើយ ដោយវាជាដំណើរការឯកជនសុទ្ធសាធ ដោយមានការចូលរួមតែពីសំណាក់ភាគីដែលពាក់ព័ន្ធប៉ុណ្ណោះ លើកលែងតែមានករណីចាំបាច់តែប៉ុណ្ណោះ ដែលករណីនោះអាចនឹងប៉ះពាល់ដល់មនុស្ស ឬអាជីវកម្ម។[85]
- <u>មជ្ឈត្តកម្ម</u> មានការចូលរួមពីសំណាក់ភាគីអព្យាក្រឹត្យ ឬមជ្ឈត្តករដែលជាអ្នកសម្របសម្រួលនៅក្នុងនីតិវិធីមជ្ឈត្តកម្ម ដោយមជ្ឈត្តករអាចមានពីលើសពីមួយ ឬច្រើនក្នុងដំណើរការ ដែលជាហេតុធ្វើឱ្យភាពឯកជននៅក្នុងមជ្ឈត្តការមានតិចជាងការចរចា។

ខ. ភាពបត់បែន

- <u>ការចរចា</u> ភាគីអាចដោះស្រាយនៅកន្លែងណាក៏បាន គ្រប់ទីកន្លែង មិនថានៅតាមដងផ្លូវ។
- <u>មជ្ឈត្តការ</u> ភាពបត់បែនមានលក្ខណៈល្អប្រសើរ ប៉ុន្តែមជ្ឈត្តការមានលក្ខណៈស្មុគស្មាញជាងការចរចាបន្តិច ដោយហេតុថាភាគីត្រូវសម្រេចជ្រើសរើសទីកន្លែងដែលពួកគេចង់ធ្វើមជ្ឈត្តការ ដោយទីកន្លែងត្រូវតែសមរម្យសម្រាប់ដំណើរការ តើពួកគេចង់បាននីតិវិធីស្មុគស្មាញ ដែលមើលទៅមានលក្ខណៈដូចជាបណ្ដឹងនៅតុលាការ ឬមានលក្ខណៈសាមញ្ញជាងនេះ។

គ. ល្បឿន

[85] ដូចលេខ៥៨

- **<u>ការចរចា</u>** ដំណោះស្រាយនៅក្នុងការចរចា មានល្បឿនលឿនជាងមជ្ឈត្តការ ដោយហេតុថាការចរចាមិនមាននីតិវិធីស្មុគស្មាញ ឬមានការសម្របសម្រួលពីភាគីទីបីឡើយក្នុងករណីមិន) ។(ចាំបាច់
- **<u>មជ្ឈត្តការ</u>** ជាទូទៅ ទោះបីជាមជ្ឈត្តការផ្តល់នូវដំណោះស្រាយវិវាទដាច់រហ័សក៏ដោយ ប៉ុន្តែនៅតែមានល្បឿនយឺត ដោយសារមាននីតិវិធី និងដំណាក់កាលនៃការដោះស្រាយច្រើន ព្រមទាំងមានលក្ខណៈស្មុគស្មាញដោយអាចចំណាយពេលជាច្រើនខែ ឬច្រើនឆ្នាំទម្រាំអាចដោះស្រាយបាន ប៉ុន្តែប្រសិនបើភាគីនៅតែមិនព្រមព្រៀងទៅលើសេចក្តីសម្រេច អាចនៅបន្តការប្តឹងទៅតុលាការបន្តដែលនឹងប្រើរយៈពេលកាន់តែយូរជាងនេះ។

### ឃ. ការចំណាយ

- **<u>ការចរចា</u>** ជានីតិវិធីដែលមានការចំណាយតិចជាងការដោះស្រាយដោយមជ្ឈត្តការ ដោយនៅក្នុងដំណើរការនៃការរចរចាមិនត្រូវការចំណាយទៅលើប្រាក់ប្រដាប់ក្តីឡើយ។
- **<u>មជ្ឈត្តការ</u>** នៅក្នុងដំណើរការមួយនេះមានការចំណាយច្រើនទៅលើនីតិវិធី ដោយការចំណាយជាបន្ទុករបស់ភាគីវិវាទ ដែលក្នុងនោះមានដូចជា៖ ការចំណាយទៅលើថ្លៃឈ្នួលនៃវេទិកាមជ្ឈត្តកម្ម ថ្លៃធ្វើដំណើរ និងចំណាយដទៃទៀតរបស់មជ្ឈត្តករទាំងអស់ ថ្លៃដំបូន្មានជំនាញការ និងជំនួយការដទៃទៀតដែលតម្រូវដោយវេទិកាមជ្ឈត្តកម្ម ថ្លៃធ្វើដំណើររបស់សាក្សី ថ្លៃចំណាយលើតំណាង និងជំនួយផ្នែច្បាប់របស់ភាគីឈ្នះករណីមានការ) ថ្លៃឈ្ន (ទាមទារ ូល និងចំណាយផ្សេងៗរបស់អាជ្ញាធរតែងតាំង។

### ង. លទ្ធភាពគ្រប់គ្រងរបស់ភាគីវិវាទ

- **<u>ការចរចា</u>** ការចរចាផ្តល់ឱ្យភាគីវិវាទមានលទ្ធភាពគ្រប់គ្រាន់ទៅលើដំណើរការ មិនការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់លើដំណើរការចរចាដោយរបៀបណា ហើយលទ្ធផលមានការស្រុះស្រួលដែរ ឬទេ។ នៅក្នុងការចរចា ត្រូវតែមានការព្រមព្រៀងពីភាគីទាំងសងខាងដើម្បីដំណើរការក្នុងការចរចានោះ។
- **<u>មជ្ឈត្តការ</u>** រាល់ការមានភាពចម្រូងចម្រាស់កើតឡើង ដំណោះស្រាយត្រូវធ្វើឡើងដោយមជ្ឈត្តករ ផ្អែកលើវិធានមជ្ឈមណ្ឌលមជ្ឈត្តការ ដោយខុសពីការចរចា ដែលមានការព្រមព្រៀងពីភាគីវិវាទ។

### ច. គោលបំណងនៃការដោះស្រាយ

- <u>**ការចរចា**</u> នៅពេលភាគីនៃវិវាទមានការស្រុះស្រួលគ្នាតាមរយៈការចរចាលើរឿងក្តីណាមួយ អាចត្រូវបានកំណត់បញ្ចូលក្នុងនីតិវិធីតុលាការ នៅចំពោះមុខចៅក្រម ហើយនឹងអាចអនុវត្តបាន ដូចសាលក្រមដែរ។
- <u>**មជ្ឈត្តការ**</u> សេចក្តីសម្រេចរបស់មជ្ឈត្តកម្ម ត្រូវអនុវត្តទៅតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយភាគីវិវាទអាចជ្រើសរើសច្បាប់ណាមួយនៃយុត្តាធិការមកអនុវត្តក៏បាន។ ប៉ុន្តែរាល់សេចក្តីសម្រេចរបស់មជ្ឈត្តករ ឬមជ្ឈត្តវិនិច្ឆ័យ ភាគីឈ្នះក្តីត្រូវអនុវត្តត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីវិវាទចាញ់ក្តីខនខានមិនបានគោរពវិមជ្ឈត្តវិនិច្ឆ័យនេះ។ បើសិនគូវិវាទមិនសុខចិត្តអាចប្តឹងឧបាស្រ័យទៅតុលាការបាន។

៣៤ ការប្រៀបធៀបការសន្ទានកម្ម និងការផ្សះផ្សា.

នៅក្នុងដំណើរការទាំងពីរមិនសូវជាមានលក្ខណៈខុសគ្នាឡើយ ដោយហេតុថាការដោះស្រាយមានលក្ខណៈដូចគ្នាច្រើនស្ទើរតែគ្រប់ដំណាក់កាលនៃនីតិវិធី ហើយលក្ខណៈដូចគ្នាក៏មានច្រើនជាដំណើរការផ្សេងៗផងដែរ។ លក្ខណៈដូច និងលក្ខណៈខុសគ្នានៃសន្ទានកម្ម និងការផ្សះផ្សាមានដូចតទៅៈ

**លក្ខណៈដូចគ្នា**

**ក. ភាពបត់បែន** សន្ទានកម្ម និងការផ្សះផ្សា តែងតែមានភាគីទីបីជួយភាគីឱ្យទទួលបានដំណោះស្រាយ និងការដោះស្រាយជាឯកជន។

**ខ.ការរក្សាទំនាក់ទំនង** សន្ទានកម្ម និងការផ្សះផ្សាក៏មិនខុសគ្នាពីដំណោះស្រាយផ្សេងៗឡើយ ដោយការបញ្ចប់នៃដំណើរការបាន ការដោះស្រាយទំនាស់របស់ភាគីវិវាទប្រកបដោយប្រសិទ្ធិភាព និងអាចទទួលយកដំណោះស្រាយដោយសុទ្ធចិត្ត។ ដូចនេះហើយ ភាគីវិវាទជាអ្នកសម្រេចចិត្តក្នុងការទទួលយក និងអនុវត្តទៅលើសេចក្តីសម្រេចរបស់ភាគីទីបី ឬអត់។

**គ.ការចំណាយ** សន្ទានកម្ម និងការផ្សះផ្សាតម្រូវឱ្យភាគីវិវាទបង់ទៅការចំណាយនៅក្នុងនីតិវិធី ដោយការចំណាយចំពោះការផ្សះផ្សា អាចនឹងតិចជាសន្ទានកម្មតែប៉ុណ្ណោះ។

**ឃ.គោលបំណងនៃការដោះស្រាយ** សន្ទានកម្ម និងការផ្សះផ្សា សុទ្ធតែត្រូវការភាគីទីបីដែលជាអ្នកសម្របសម្រួល ឬអ្នកផ្សះផ្សាសុទ្ធតែមានគោលបំណងដូចគ្នា គឺដើម្បីស្វែងរកដំណោះស្រាយមួយដែលល្អប្រសើរបំផុតសម្រាប់ភាគីវិវាទ ព្រមទាំងអាចរក្សាបាននូវទំនាក់ទំនងដែលល្អបំផុត នៅពេលចុងបញ្ចប់នៃសេចក្តីសម្រេច។

**លក្ខណៈខុសគ្នា**

- **ល្បឿន៖** ដំណើរការនៃការធ្វើសន្ធានកម្ម មានរយៈពេលមួយថ្ងៃ ឬតិចជាងនេះ។ ចំណែកឯការផ្សះផ្សា ចំណាយពេលវេលានៃការផ្សះផ្សាដោយភាគច្រើននៅក្នុងរយៈពេលពីរ ទៅបីថ្ងៃ ហើយបត់បែនសម្រាប់វិវាទច្រើនប្រភេទទាំងតូច និងធំ។

៣៥ ការប្រៀបធៀប សន្ធានកម្ម. និងមជ្ឈត្តការ

ដំណើរការក្នុងដោះស្រាយវិវាទតាមរយៈសន្ធានកម្ម មានលក្ខណៈស្រដៀងមួយចំនួននឹងមជ្ឈត្តការដោយវិធីសាស្ត្រទាំងពីរជារបៀបដោះស្រាយជាឯកជន ដែលជាចម្លាស់ទៅនឹងបណ្ដឹងតុលាការដែលត្រូវធ្វើឡើងជាសាធារណៈ។ វិធីសាស្ត្រទាំងពីរនេះ អាចធ្វើឡើងនៅក្នុងបន្ទប់ប្រជុំឯកជន ឬនៅទីកន្លែងផ្សេងទៀតខាងក្រៅតុលាការ។[86] លក្ខណៈដូចគ្នា និងខុសគ្នាមានដូចតទៅ៖

**លក្ខណៈដូចគ្នា**

- **ភាពបត់បែន**: មជ្ឈត្តការ និងសន្ធានកម្ម សុទ្ធតែត្រូវចំណាយទៅលើភាគីទីបី និងការចំណាយផ្សេងៗទៀត ចំណែកឯដំណាក់កាលនៅក្នុងនីតិវិធីក៏មានច្រើនដំណាក់កាល ហើយមានលក្ខណៈស្មុគស្មាញប្រហាក់ប្រហែលគ្នាផងដែរ។

**លក្ខណៈខុសគ្នា**

**ក. ភាពឯកជន**

- **<u>មជ្ឈត្តការ</u>** មជ្ឈត្តករមានអំណាចក្នុងការធ្វើសេចក្ដីសម្រេចក្នុងការបង្គាប់ឱ្យសងសំណងការខូចខាតដល់ភាគីណាមួយឡើង។ ចំណែក អំណាចក្នុងការធ្វើការសម្រេចចិត្តស្ថិតក្នុងកណ្ដាប់ដៃមជ្ឈត្តករ
- **<u>សន្ធានកម្ម</u>** សន្ធានការីពុំមានអំណាចក្នុងការដូចមជ្ឈត្តការឡើយ ដោយសន្ធានការីមានសិទ្ធិតែក្នុងការស្នើឡើងនូវដំណោះស្រាយដែលអាចកើតមានប៉ុណ្ណោះ។ ចំណែក អំណាចក្នុងការធ្វើការសម្រេចចិត្តស្ថិតនៅលើភាគីវិវាទ។

**ខ. ការអនុវត្តដំណោះស្រាយ**

- **<u>មជ្ឈត្តការ</u>** នៅក្នុងដំណើរការមជ្ឈត្តការ មជ្ឈត្តករត្រូវពិនិត្យមើលឡើងវិញនូវអង្គហេតុ និងអង្គច្បាប់ដូចចៅក្រមដែរហើយត្រូវប្រើការពិចារណាលើតក្កសាស្ត្រ និងហេតុផលផ្លូវច្បាប់ដើម្បី

[86] ដូចលេខ៥៨ ទំ.១៤៧

ឈានដល់ការធ្វើសេចក្តីសម្រេច ដោយផ្តោតការយកចិត្តទុកដាក់លើការស្វែងរកលទ្ធផលដែលផ្អែកទៅតាមច្បាប់ ។

- <u>**សន្ធានកម្ម**</u> នៅក្នុងដំណើរនៃនេះ សន្ធានការីប្រហែលជាត្រូវប្រើជំនាញផ្នែកសង្គម និងការវិភាគតាមបែបប្រធានវិស័យដើម្បីឈានដល់ដំណោះស្រាយ ។ អាស្រ័យហេតុនេះ នៅក្នុងសន្ធានកម្ម ត្រូវផ្តោតការយកចិត្តទុកដាក់លើការស្វែងរកលទ្ធផល ដែលឆ្លើយតបយ៉ាងប្រសើរបំផុតទៅនឹងផលប្រយោជន៍របស់ភាគីវិវាទ ។

**គ.គោលបំណងនៃការដោះស្រាយ**

- <u>**មជ្ឈត្តការ**</u> នៅក្នុងមជ្ឈត្តការ ចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់គឺជាមជ្ឈត្តករ ភាគីវិវាទត្រូវព្យាយាមបញ្ចុះបញ្ចូលឱ្យមជ្ឈត្តករជឿថា ពួកគេគួរតែឈ្នះក្តី។
- <u>**សន្ធានកម្ម**</u> ចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់គឺជាភាគីនៃវិវាទ។ សន្ធានការីត្រូវស្តាប់អំណះអំណាងរបស់ភាគីវិវាទ ហើយព្យាយាមស្វែករកនូវមធ្យោបាយដែលអាចឆ្លើយតបនឹងផលប្រយោជន៍របស់ពួកគេបាន ។

៣៦ ការប្រៀបធៀប ការផ្សះផ្សា និងមជ្ឈត្តការ

**លក្ខណៈដូច**

- **ភាពឯកជនៈ** ដំណើរនៅក្នុងការផ្សះផ្សា មានការចូលរួមពីភាគីទីបីជាអព្យាក្រឹត្យដូចគ្នាដើម្បីធ្វើការពិចារណាទៅលើហេតុផលដែលជាសំអាងរបស់ភាគីទាំងពីរ រួចចេញសេចក្តីសម្រេចដែលមានប្រសិទ្ធិភាពទៅលើភាគីទាំងឡាយក្នុងវិវាទនោះ។ ចំណែកឯមជ្ឈត្តការ ក៏មានការចូលរួមពីសំណាក់ភាគីទីបីដែលជាមជ្ឈត្តករ ក្នុងការចូលរួមដោះស្រាយវិវាទដោយផ្អែកលើវិធានច្បាប់ផងដែរ។ ជាហេតុនេះហើយ ភាពឯកជននៅក្នុងនីតិវិធីទាំងពីរនេះមិនសូវពេលលេញឡើយ។

**លក្ខណៈខុសគ្នា**

**ក. ភាពបត់បែន**

- <u>**ការផ្សះផ្សា**</u> ដំណើរការនៃការផ្សះផ្សាមិនបានកំណត់ពីវិធាននៃការជ្រើសរើសទីតាំង ឬភាសាឡើយ ដោយគ្រាន់មានយល់ព្រមពីទាំងសងខាងជាការស្រេច។
- <u>**មជ្ឈត្តការ**</u> រីឯនៅក្នុងដំណើរការនៃការដោះស្រាយដោយមជ្ឈត្តការវិញ មានទាមទារឱ្យភាគីវិវាទធ្វើកិច្ចព្រមព្រៀងដោយសម្រេចជ្រើសរើស ភាសា ទីកន្លែង ដោយភាគីទីបីដែលបានជ្រើសរើសរួមគ្នានោះដោះស្រាយវិវាទដោយផ្អែកលើវិធានដែលបានព្រមព្រៀងគ្នា ដែលពួកគេចង់ធ្វើមជ្ឈត្តការដោយទីកន្លែងត្រូវតែសមរម្យសម្រាប់ដំណើរការ តើពួកគេចង់បាននីតិវិធី

ស្មុគស្មាញ ដែលមើលទៅមានលក្ខណៈដូចជាបណ្តឹងនៅតុលាការ ឬមានលក្ខណៈសាមញ្ញជាងនេះ។

ខ.ល្បឿន

- <u>**ការផ្សះផ្សា**</u> ដំណើរនៃនីតិវិធីនៃការផ្សះផ្សា មិនចំណាយពេលយូរឡើយ ដោយផ្អែកលើភាពជាក់ស្តែងទៅតាមទំហំនៃនៃបញ្ហារបស់ភាគីវិវាទ ថាជាប្រភេទបញ្ហាតូច ឬធំ។
- <u>**មជ្ឈត្តការ**</u> ត្រូវការចំណាយពេលយូរ រហូតទៅដល់ច្រើនខែ ឬច្រើនឆ្នាំ ដោយសារតែនីតិវិធីមានលក្ខណៈស្មុគស្មាញ ព្រមទាំងដំណាក់កាលនៃដោះស្រាយក៏មានច្រើនផងដែរ។

គ.ការចំណាយ

- <u>**ការផ្សះផ្សា**</u> ថ្វីត្បិតការផ្សះផ្សាមានភាគីទីក្នុងការចូលរួមក្នុងការដោះស្រាយជម្លោះក៏ដោយ ប៉ុន្តែ ការចំណាយមិនមានតម្លៃថ្លៃ ឬច្រើនឡើយ ដូចមជ្ឈត្តការឡើយ ព្រោះការផ្សះផ្សាមិនមានដំណាក់កាលនៃនីតិវិធីច្រើន។
- <u>**មជ្ឈត្តការ**</u> ការចំណាយអាចនឹងថ្លៃជាងការដោះស្រាយវិវាទផ្សេងៗ ពីព្រោះមជ្ឈត្តការមានដំណាក់កាលនៃដំណើរការនៃនីតិវិធីច្រើន ព្រមទាំងការចំណាយទៅលើមជ្ឈត្តករក៏មានតម្លៃថ្លៃផងដែរ។

ឃ.លទ្ធភាពគ្រប់គ្រងរបស់ភាគី

- <u>**ការផ្សះផ្សា**</u> ផ្តល់ឱ្យភាគីនូវលទ្ធភាពក្នុងការសម្រេចមុន ថាគួរកំណត់យកយោបល់របស់អ្នកផ្សះផ្សា ឬលក្ខណៈកាតូកិច្ចដែរឬទេ។
- <u>**មជ្ឈត្តការ**</u> រាល់ការមានភាពចម្រូងចម្រាស់កើតឡើង ដំណោះស្រាយត្រូវធ្វើឡើងដោយមជ្ឈត្តករ ផ្អែកលើវិធានមជ្ឈមណ្ឌលមជ្ឈត្តការ ដែលខុសពីការចរចា មានការព្រមព្រៀងពីភាគីវិវាទ។

ង. គោលបំណងនៃការដោះស្រាយ

- <u>**ការផ្សះផ្សា**</u> ការបញ្ចប់សេចក្តីនៃការផ្សះផ្សា ធ្វើឡើងដោយអ្នកផ្សះផ្សាជាអ្នកលើកសំណើសម្រាប់ភាគីវិវាទទាំងសងខាងធ្វើការដោះស្រាយទំនាស់របស់ភាគីវិវាទប្រកបដោយប្រសិទ្ធិភាព និងអាចទទួលយកដំណោះស្រាយដោយសុទ្ធចិត្ត។
- <u>**មជ្ឈត្តការ**</u> ស្វែងរកភាគីឈ្នះ និងភាគីចាញ់ ដោយមានការចេញសេចក្តីសម្រេចរបស់មជ្ឈត្តកម្ម និងត្រូវអនុវត្តទៅតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយភាគីវិវាទអាចជ្រើសរើសច្បាប់ណាមួយនៃយុត្តាធិការមកអនុវត្តក៏បាន។ ប៉ុន្តែរាល់សេចក្តីសម្រេចរបស់មជ្ឈត្តករ ឬមជ្ឈត្តវិនិច្ឆ័យ ភាគីឈ្នះក្តីត្រូវអនុវត្តត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ ប្រសិនបើភាគី

វិវាទចាញ់ក្ដីខកខានមិនបានគោរពវិមជ្ឈត្តវិនិច្ឆ័យនេះ។ បើសិនគូវិវាទមិនសុខចិត្តអាចប្ដឹងឧបាស្រ័យទៅតុលាការបាន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការស្រាវជ្រាវ និងបកស្រាយខាងលើបានបញ្ជាក់ឱ្យឃើញថាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កើតមានជាប្រពៃណីជាយូរមកហើយនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានចាប់ផ្តើមមានឡើងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និងឆ្នាំ១៩៨០ ព្រមទាំងទទួលបាននូវប្រជាប្រិយចាប់ពីពេលនោះមក។ នៅសហរដ្ឋអាមេរិក ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានកើតមានឡើងតាំងពីដើមសម័យអាណានិគមរបស់ហូឡង់ និងអង់គ្លេសនៅក្រុងទីក្រុងញូយ៉ក ហើយកាន់តែមានភាពល្បីល្បាញកាន់តែខ្លាំងនៅដើមសតវត្សទី២០នេះ ដោយរដ្ឋនានាបានចាប់ផ្តើមទទួលយកការចាប់អារម្មណ៍រួមគ្នានៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយចាត់ទុកថាជាជម្រើសប្រព័ន្ធទីមួយនៃការដោះស្រាយវិវាទឱ្យកាន់តែឆាប់រហ័ស និងមានប្រសិទ្ធិភាពខ្ពស់។ ចំណែកឯការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅដែនដីហុងកុងកើតមានឡើងនៅដើមសតវត្សរ៍ទី១៩ ដោយហុងកុងមានរបបផ្លូវច្បាប់ដែលរីកចម្រើនបំផុតមួយ ទើបមានការបង្កើតឡើងនូវមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិហុងកុងតាំងពីឆ្នាំ១៩៨៥ ដែលមានទាំងបទពិសោធន៍ ព្រមទាំងមានទីតាំងយ៉ាងសំខាន់នៅផ្លូវបំបែកនៃពាណិជ្ជកម្ម និងពាណិជ្ជកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ រីឯការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងប្រទេសសិង្ហបុរីបានចាប់ផ្តើមជាបណ្តោះអាសន្ននៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ នៅពេលដែលរដ្ឋាភិបាលបានចាត់ទុកប្រទេសសិង្ហបុរីជាមជ្ឈមណ្ឌលដោះស្រាយវិវាទដ៏សំខាន់ ដោយបានដាក់ទុនលើទីតាំងភូមិសាស្ត្ររបស់ខ្លួន ក៏ដូចជាគោលដៅរបស់ខ្លួនក្នុងការអភិវឌ្ឍប្រទេសសិង្ហបុរីទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្មតែមួយគត់ ជាពិសេសគោលដៅច្បាស់លាស់មួយទៀតគឺការពារប្រទេសសិង្ហបុរីពីការក្លាយជាសង្គមដែលមានវិវាទឆ្ពោះទៅជាប្រទេសដែលធ្វើឱ្យកាន់តែប្រសើរនូវការចូលទៅកាន់ជម្រើសការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយជម្លោះដោយភាពងាយស្រួល ដោយភាគីអាចដាក់ជម្រើសសម្រាប់វិវាទតុលាការ ឬមជ្ឈត្តកម្ម ហើយរដ្ឋាភិបាលក៏បានលើកទឹកចិត្តយ៉ាងសកម្មឱ្យគូវិវាទជ្រើសយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះដែរ។

ដោយសារតែមើលឃើញពីសារៈសំខាន់នៃដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ទើបរាជរដ្ឋាភិបាលកម្ពុជាបានធ្វើការឱ្យកាន់តែប្រសើរឡើងនូវការទទួលបាននូវយុត្តិធម៌ ជាមួយការអនុវត្តសារជាថ្មីនូវទ្រឹស្តីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយបានដាក់ទ្រឹស្តីនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌ក្នុងប្រព័ន្ធតុលាការ ដោយទាក់ទងនឹងការចំណាយ ថវិការខ្ពស់ និងពេលវេលាច្រើនសម្រាប់រឿងក្តីនៅក្នុងប្រព័ន្ធតុលាការ មានន័យថា ពេលដែលសំណុំរឿងនៅក្នុងតុលាការត្រូវចំណាយពេលយូរ ជាមួយការចំណាយសម្រាប់

មេធាវីកាន់តែច្រើន ទើបជំរុញឱ្យប្រជាពលរដ្ឋងាកមកប្រើប្រាស់នូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការវិញ។ ផលប្រយោជន៍ចម្បងនោះ គឺជាវិធីសាស្ត្រមួយដែលមានការពេញនិយមជាងការប្រើប្រាស់ប្រព័ន្ធតុលាការ ដោយសារតែការចំណាយពេលវេលា ការចំណាយថវិការមានលក្ខណៈសមស្រប និងមានប្រសិទ្ធិភាពជាង។ ដោយហេតុថា ការដោះស្រាយវិវាទនៅក្នុងប្រព័ន្ធតុលាការត្រូវចំណាយខ្ពស់ ឯការចំណាយចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយការប្រើប្រាស់យន្តសាស្ត្រទាំងបួន មានការចំណាយតិចតួចជាង ការចំណាយនៅប្រព័ន្ធតុលាការតែប៉ុណ្ណោះ ហើយការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនតម្រូវឱ្យមានការធ្វើឯកសារច្រើននោះទេ ហេតុនេះការចំណាយក៏ទាប បន្ថែមពីនេះទម្រង់នៃការដោះស្រាយវិវាទទាំងបួននេះ ក៏បានផ្តល់នូវភាពបត់បែនដល់ភាគីក្នុងការជ្រើសរើសនូវពេលវេលាដែលសមស្រប ដោយមិនតម្រូវឱ្យភាគីគោរពតាមពេលវេលាកំណត់ដូចតុលាការនោះទេ ជាពិសេសអត្ថប្រយោជន៍មួយទៀតគឺថាការដោះស្រាយវិវាទរឿងក្តីនៅប្រព័ន្ធតុលាការហាក់បីដូចជាមានការយឺតយ៉ាវ ប្រសិនបើប្រៀបធៀបទៅនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទនេះ ត្រូវបានគេស្គាល់ថា ជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅប្រទេសកម្ពុជាដែលត្រូវបង្កើតឡើងដើម្បីដោះស្រាយវិវាទជាច្រើននៅក្នុងបរិបទគ្រួសារ ដីធ្លី ការងារ និងពាណិជ្ជកម្ម ជាពិសេសការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ក៏ជាយន្តការមួយដ៏ល្អសម្រាប់ពាណិជ្ជករ ដែលមានដូចជាការចរចា ការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តកម្ម។ មុននឹងឈានដល់ការដោះស្រាយតាមរយៈមជ្ឈត្តការ ភាគីវិវាទគួរតែព្យាយាមធ្វើការដោះស្រាយវិវាទរបស់ពួកគេតាមការចរចា ការផ្សះផ្សា ឬសន្ធានកម្ម ទៅតាមលទ្ធភាពដែលអាចធ្វើបាន ជាពិសេសនៅពេលបញ្ហាវិវាទមានលក្ខណៈតូចតាច ឬមិនមានភាពស្មុគស្មាញ ដើម្បីរក្សាទំនាក់ទំនងរវាងភាគីទាំងពីរ ព្រោះថាយន្តការទាំងនេះជាការដោះស្រាយដែលកើតចេញពីការព្រមព្រៀងគ្នាដោយភាគីទាំងពីរ។ ដូច្នេះពុំមានភាគីណាមួយត្រូវបានចាត់ទុកថាចាញ់ ឬភាគីណាមួយត្រូវបានចាត់ទុកថាឈ្នះឡើយ ដែលខុសពីមជ្ឈត្តការដែលចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យកំណត់ពីភាគីចាញ់ និងភាគីឈ្នះហើយអាចនាំឲ្យបាត់បង់នូវទំនាក់ទំនងរវាងភាគីនៅក្នុងដំណើរការមជ្ឈត្តកម្មផងដែរដោយការដោះស្រាយវិវាទអាចធ្វើបាន តែកម្មវត្ថុនៃវិវាទនោះជាកម្មវត្ថុនៃពាណិជ្ជកម្មតែប៉ុណ្ណោះ។ ការចាប់ផ្តើមនូវដំណើរការមជ្ឈត្តកម្ម គឺនៅពេលដែលភាគីឆ្លើយតបបានផ្តល់ការជូនដំណឹងពីភាគីវិវាទដែលបានដាក់បញ្ហាវិវាទឱ្យធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការដោយភាគីទទួលទាមទារ ក្រោយដំណើរការមជ្ឈត្តការត្រូវបានចាប់ផ្តើម ជំហានបន្ទាប់គឺភាគីវិវាទត្រូវធ្វើការតែងតាំងមជ្ឈត្តករជ្រើសរើសទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការ វិធានច្បាប់ដែលត្រូវយកមកអនុវត្ត ភាសា និងនីតិវិធីសម្រាប់ដំណើរការមជ្ឈត្តការដើម្បីបង្កើតនូវវេទិកាមជ្ឈត្តការ ហើយរាល់ជ្រើសរើសទាំងនេះ គឺជាសេរី

ភាពកំណត់របស់ភាគី។ អ្វីដែលពិសេសនោះគឺការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការជាទូទៅមានរយៈពេលខ្លីជាងឆាប់រហ័ស រក្សានូវការសម្ងាត់ និងចំណាយតិចជាងនីតិវិធីតាមប្រព័ន្ធតុលាការ។ ហេតុនេះហើយ ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការភាគីវិវាទគួរតែធ្វើការជ្រើសរើសយកដំណើរមជ្ឈត្តកម្មមកធ្វើការដោះស្រាយវិវាទរបស់ខ្លួន ហើយនៅក្រោយពេលដែលចេញនូវសេចក្ដីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទអាចយកសេចក្ដីសម្រេចនេះទៅអនុវត្តនៅបណ្ដាប្រទេសផ្សេងៗដែលជាសមាជិកនៃអនុសញ្ញាទីក្រុងញូវយ៉ក។ លើសពីនេះ ការចំណាយតិចជាងការដាក់ពាក្យបណ្ដឹងទៅតុលាការនៅប្រទេសកម្ពុជា ដោយសារតែវាមានភាពរលូន ហើយពុំមានការប្ដឹងឧបាស្រ័យឡើយលើមជ្ឈត្តវិនិច្ឆ័យ ភាពឆាប់រហ័សនៃមជ្ឈត្តការ និងលក្ខណៈស្ថាពរនៃមជ្ឈត្តវិនិច្ឆ័យជាគុណសម្បត្តិមួយដ៏សំខាន់របស់មជ្ឈត្តការ ដោយសារដំណើរនៃមជ្ឈត្តការមានភាពងាយស្រួល ដែលអាចបត់បែនបានតាមភាគី ហើយមជ្ឈត្តវិនិច្ឆ័យគឺជាសេចក្ដីសម្រេចចុងក្រោយ។

បន្ថែមពីនេះ ក្នុងការបកស្រាយក្នុងជំពូកទី៣ បានបកស្រាយពីការប្រៀបធៀបនូវដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងអស់ដោយការប្រៀបធៀបនោះមានដូចជា ការប្រៀបធៀបពីការចរចា និងសន្ធានកម្ម, ការចរចា និងការផ្សះផ្សា, ការចរចា និងមជ្ឈត្តការ, សន្ធានកម្ម និងការផ្សះផ្សា, សន្ធានកម្ម និងមជ្ឈត្តកម្ម, ការផ្សះផ្សា និងមជ្ឈត្តការ។ ដោយការប្រៀបធៀបបានបង្ហាញពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នារបស់ដំណើរការនីមួយៗ។ ដោយក្នុងនោះ លក្ខណៈដូចគ្នារបស់ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ គឺការរក្សាទំនាក់ទំនងរបស់ភាគី ដែលជាទូទៅភាគីទីបីជាអ្នកសម្របសម្រួលដោយធ្វើយ៉ាងណាឱ្យដោយការដោះស្រាយរបស់គូភាគីឱ្យមានភាពកាន់តែល្អប្រសើរទាំងក្នុងអំឡុងពេលធ្វើការដោះស្រាយ និងក្រោយពេលដោះស្រាយរួចរាល់។ បន្ទាប់ពីនេះជាការប្រៀបធៀបលក្ខណៈខុសគ្នារបស់ដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលការប្រៀបធៀបនោះមានការលើកបង្ហាញពី លក្ខណៈខុសគ្នានៃភាពឯកជន ភាពបត់បែនល្បឿន ការចំណាយ លទ្ធភាពគ្រប់គ្រងរបស់ភាគី និងគោលបំណងនៃការដោះស្រាយ។ ការប្រៀបធៀបលក្ខណៈខុសគ្នាបានឱ្យយើងដឹងថា តើដំណើរណាមួយដែលលក្ខណៈងាយស្រួលជាងគេ មានភាពបត់បែនប្រសើរជាងគេ ការចំណាយតិចជាងគេ ដែលក្នុងការបកស្រាយនោះបានបង្ហាញថា ការចរចាមានលក្ខណៈដូចការរៀបរាប់ខាងលើនេះ ចំណែកឯមជ្ឈត្តការវិញមានភាពឯកជនតិចជាងគេ ប្រសិនបើប្រៀបទៅនឹងវិធីសាស្ត្រដទៃ ព្រមទាំងការចំណាយច្រើនព្រោះនីតិវិធីមានច្រើនដំណាក់កាល រីឯគោលបំណងនៃការដោះស្រាយក៏ដើម្បីរកភាគីឈ្នះ និងភាគីចាញ់ ហើយគូភាគីក៏ត្រូវគោរពតាមមជ្ឈត្តវិនិច្ឆ័យផងដែរ ដែលខុសពីការចរចា សន្ធានកម្ម និងការផ្សះផ្សា ដោយគូភាគីមានសិទ្ធិក្នុងការសម្រេចចិត្តក្នុងការទទួលយកការដំណោះស្រាយរបស់ភាគីទីបី ឬអត់។

ក្នុងនោះដែរ ការប្រៀបធៀបខាងលើក៏បានឱ្យពួកយើងជានិស្សិតដែលធ្វើការស្រាវជ្រាវបានយល់ច្បាស់ដំណើរការនៃដំណោះស្រាយទាំងបួន និងដឹងកាន់តែច្បាស់ថាគួររើសយកវិធីសាស្ត្រមួយណាដើម្បីយកមកដោះស្រាយនៅពេលដែលមានវិវាទកើតឡើង។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាពីប្រធានបទខាងលើយើងខ្ញុំចង់ឃើញការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាមានការរីកចម្រើន និងដើម្បីឱ្យដំណើរការដោះស្រាយវិវាទទទួលបានការជឿជាក់ និងទុកចិត្តកាន់ច្រើនពីសំណាក់សាធារណជន យើងខ្ញុំសូមលើកឡើងនូវអនុសាសន៍មួយចំនួនស្នើចំពោះរដ្ឋាភិបាល មជ្ឈត្តករ អ្នកតាក់តែងច្បាប់ ព្រមទាំងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកម្ម គួរពិចារណាទៅលើសកម្មភាពដូចខាងក្រោមៈ

- បង្កើតនូវវគ្គបណ្តុះបណ្តាលបន្ថែមលើដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជារួមមាន ការចរចា ការផ្សះផ្សា សន្ទានកម្ម មជ្ឈត្តកម្ម។
- ផ្សព្វផ្សាយវីដេអូអប់រំពីការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជាដើម្បីឱ្យប្រជាពលរដ្ឋមានចំណេះដឹងអំពីវិស័យមួយនេះ។
- រក្សាឱ្យបាននូវយុត្តិធម៌ ភាពមិនលម្អៀង និងឯករាជ្យភាពរបស់មជ្ឈមណ្ឌលក៏ដូចជាមជ្ឈត្តករ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេសមកធ្វើការវិនិយោគ និងជឿជាក់ព្រមជ្រើសយកការដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្មនៅក្នុងប្រទេសកម្ពុជា។
- មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវធ្វើការគ្រប់គ្រងតម្លៃនៅក្នុងដំណើរការមជ្ឈត្តកម្មឱ្យមានតម្លៃសមរម្យ ដែលអាចធានាថាពាណិជ្ជករទូទៅអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយវិវាទរបស់ពួកគេបានតាមរយៈយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- រដ្ឋាភិបាលក៏ត្រូវធានាថាការដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្មមានភាពឆាប់រហ័ស និងមានប្រសិទ្ធិភាពដល់ភាគីវិវាទទាំងពីរក្នុងការយកទៅអនុវត្តន៍ទាំងក្នុងប្រទេស និងទៅអន្តរជាតិ។
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាគួរតែលើកទឹកចិត្ត និងដាក់ចេញនូវគោលនយោបាយដើម្បីជំរុញឱ្យសាធារណជនយល់ និងកាន់តែស្គាល់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាឱ្យបានកាន់តែច្រើន តាមរយៈការផ្សព្វផ្សាយអំពីដំណើរការដោះស្រាយទាំងបួនដល់ប្រជាពលរដ្ឋឱ្យមានការស្គាល់ និងយល់ដឹងកាន់តែច្បាស់ពីសារៈសំខាន់របស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជាដើម្បីទទួលបានការគាំទ្រ និងជឿទុកចិត្តកាន់តែខ្លាំងពីសំណាក់សាធារណជនទាំងក្នុងស្រុក និងក្រៅស្រុក។

# តារាងអក្សរកាត់

| | |
|---|---|
| ADR (Alternative Dispute Resolution) | ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ |
| UNICITRAL (United Nations Commission on International Trade Law) | ច្បាប់ពាណិជ្ជកម្មអន្តរជាតិ |
| FMCS (Federal Mediation and Conciliation Service) | សេវាសម្របសម្រួល និងការផ្សះផ្សាជាសហព័ន្ធ |
| NYCREFAA (New York Convention on the Recognition and Enforcement of Foreign Arbitral Awards) | អនុសញ្ញាក្រុងញូវយ៉កស្ដីពីការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស |
| ICSID (Convention on the Settlement of Investment Disputes) | អនុសញ្ញាស្ដីពីការដោះស្រាយវិវាទទាក់ទងនឹងការ វិនិយោគ |
| Civil Law | ច្បាប់ស៊ីវិល |
| Common Law | ប្រព័ន្ធច្បាប់អង់គ្លេស |

## ច្បាប់ និងលិខិតបទដ្ឋានជាតិ

១.ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ២០០៦

២.ច្បាប់ស្តីពីការមជ្ឈត្តការផ្នែកពាណិជពាកម្ម ឆ្នាំ២០០៦

៣.ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

៤.ច្បាប់គំរូ UNCITRAL ស្តីពីការផ្សះផ្សាផ្នែកពាណិជ្ជកម្មអន្តរជាតិ, សម័យប្រជុំលើកទី ៥៧ ឯ.បន្ថែម លេខ ១៧ឯ.អសប លេខ A/57/17 ឧបសម្ព័ន្ធទី១ មាត្រា៩ (ឆ្នាំ២០០២)

៥.ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៥

៦.វិធានស្តីពីមជ្ឈការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ ថ្ងៃទី១១ កក្កដា ឆ្នាំ២០១៤

៧.វិធានផ្សះផ្សានៃគណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ មាត្រា ២(៤) ឆ្នាំ ១៩៨០

៨. អនុក្រឹត្យស្តីពីវិមជ្ឈការនៃតួនាទី មុខងារ និងអំណាចដល់ក្រុមប្រឹក្សាឃុំ (២០០២)

៩. អនុក្រឹត្យលេខ ៤៧ អនក្រ.បក (ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២) 'ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

១០.ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងឆ្នាំ (១៩៩៩) និង ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ក្នុងឆ្នាំ (២០០២)។

១១. ក្រមសីលធម៌សម្រាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៥

១២.បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី

## សេចក្តីសម្រេច សេចក្តីណែនាំ និងលិខិតនានា

១. សេចក្តីសម្រេចលេខ ៣៥/៥២ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីវិធានផ្សះផ្សារបស់គណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ(UNCITRAL) ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨០

២. សេចក្តីសម្រេចលេខ ៣១/៩៨ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីវិធានមជ្ឈត្តករបស់គណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ(UNCITRAL) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦

៣. សេចក្តីសម្រេចលេខ ០៧៥/០០២/2២០០៦ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦

## ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ

១. ឯកសារកម្មវិធីមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្ម ម៉ូឌុលទី២ ស្តីពីការចាប់ផ្តើមដំណើរការមជ្ឈត្តការ និងវេទិកាមជ្ឈត្តកម្ម

២. ការដោះស្រាយក្រៅប្រព័ន្ធតុលាការ រៀបរាងដោយៈ បេក្ខអនុបណ្ឌិតច្បាប់ កៅ សីហា ឆ្នាំ២០១០

៣. ឯកសារស្រាវជ្រាវ គណៈកម្មការទី៦ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ" ស្រាវជ្រាវដោយវិទ្យាស្ថានសភាកម្ពុជា ខែមិថុនា ឆ្នាំ២០១៥

៤. Betty southard Murphy, "ផលប៉ះពាល់នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទៅលើពាណិជ្ជកម្មអន្តរជាតិ" ឆ្នាំ១៩៩៣

៥. Austermiller, "សន្ធានការីដែលពុករលួយនៅតែអាចព្យាយាមបង្ខំឱ្យភាគីព្រមព្រៀង តាមរយៈឧបាយកលដោះខ្លួន ឬការបង្ខិតបង្ខំ"

៦. មេធាវី ស្ទីវីន អ៊ែម អូស្ទើរមីឡឺរ៍ សៀវភៅសិក្សាស្តីពីទស្សនានសំខាន់ៗ៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា

៧. Douglas Henderson, "ភាពជោគជ័យនៃការសម្រុះសម្រួល ការវិភាគដែលសំអាងលើការពិសោធន៍" ឆ្នាំ១៩៩៦

៨. Keith G. Allred, "ភាពសកម្មនៃទំនាក់ទំនងក្នុងវិវាទសៀវភៅណែនាំអំពីដំណោះស្រាយវិវាទ" ឆ្នាំ២០០៥

៩. Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform"

១០. Luco, Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices,

១១. Hughes, "An investigation of Conflict Management in Cambodian Villages: A review of the literature with Suggestions for Future Research",

១២. YRIGOYEN FAJARDO, Kong, and Phan, Pathways to Justice: "Access to Justice with a focus on the poor, women and indigenous peoples.", p.1.

១៣. Arbitration and its development in Malaysia.", (2008),

១៤. Phallack kong, "overview of the Cambodia legal and judicial system and recent efforts at legal and judicial reform", in the introduction to Cambodia law, (Konrad-Adenauer-stiftung, 2012

១៥. Thomas B. Ginsburg "International Commercial Arbitration in Asia" (2006),

១៦. Philip J. McConnaughay, "Arbitration in Hong Kong" (2012),

១៧. Chan, Gary Kok Yew, "The Alternative Resolution Depute in Singapore" (2020),

១៨. Rajoo, Sundra "The article traces the development arbitraiton in Singapore including legislative changes." (2020),

១៩. MICHAEL MCMANUS "Brief History of Alternative Dispute Resolution in the United States Cadmus Journal."

២០. Goldberg, Jordan, Alternative Dispute Resolution" Peperdine Dispute Resolution Law Journal, 2014

២១. Christine Cervenak, "alternative dispute resolution practitioners Journal", 1987,

២២. Lewis, Melissa, and McCrimmon, Les, "The Role of ADR Process in the Criminal Justice System: A view from Australia" (Paper presented at At ALRAESA Conference, Entebbe, Uganda 4-8 September, 2005)

## បញ្ជីឧបសម្ព័ន្ធ



**ឧបសម្ព័ន្ធ១**. សេចក្តីសម្រេចលេខ ៣៥/៥២ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីវិធានផ្សះផ្សារបស់គណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨០

**ឧបសម្ព័ន្ធ២**. សេចក្តីសម្រេចលេខ ៣១/៩៨ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីវិធានមជ្ឈត្តករបស់គណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦

**ឧបសម្ព័ន្ធ៣**. សេចក្តីសម្រេចលេខ ០៧៥/០០២/2២០០៦ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦

**ឧបសម្ព័ន្ធ១.**

## មាតិកា


**សេចក្តីសម្រេចរបស់សន្និបាតអង្គការសហប្រជាជាតិ ៣៥/៥២**

**វិធានផ្សះផ្សារបស់** UNCITRAL

មាត្រា ១: ការអនុវត្តន៍វិធាន

មាត្រា ២: ការចាប់ផ្តើមដំណើរការផ្សះផ្សា

មាត្រា ៣: ចំនួនអ្នកផ្សះផ្សា

មាត្រា ៤: ការតែងតាំងអ្នកផ្សះផ្សា

មាត្រា ៥: ការដាក់បណ្តឹងទៅអ្នកផ្សះផ្សា

មាត្រា ៦: តំណាង និងជំនួយ

មាត្រា ៧: តួនាទីរបស់អ្នកផ្សះផ្សា

មាត្រា ៨: ជំនួយផ្នែករដ្ឋបាល

មាត្រា ៩: ការឆ្លើយឆ្លងរវាងអ្នកផ្សះផ្សា និងភាគីវិវាទ

មាត្រា ១០: ការបង្ហាញព័ត៌មាន

មាត្រា ១១: ការសហការរបស់ភាគីវិវាទជាមួយអ្នកផ្សះផ្សា

មាត្រា ១២: សំណូមពររបស់ភាគីដើម្បីបញ្ចប់វិវាទ

មាត្រា ១៣: កិច្ចព្រមព្រៀងបញ្ចប់វិវាទ

មាត្រា ១៤: ការរក្សាការសម្ងាត់

មាត្រា ១៥: ការបញ្ចប់ដំណើរការផ្សះផ្សា

មាត្រា ១៦: ឧបាស្រ័យតាមនីតិវិធីមជ្ឈត្តការ ឬតុលាការ

មាត្រា ១៧: ថ្លៃចំណាយផ្សេងៗ

មាត្រា ១៨: ប្រាក់តម្កល់

មាត្រា ១៩: តួនាទីអ្នកផ្សះផ្សានៅក្នុងនីតិវិធីដទៃទៀត

មាត្រា ២០: ការទទួលភស្តុតាងនៅក្នុងនីតិវិធីដទៃទៀត

**ខគត្រូស្តីពីការផ្សះផ្សា**

# សេចក្តីសម្រេចលេខ៣៥/៥២អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ
# នៅថ្ងៃ ទី៤ ធ្នូ ១៩៨០

**៣៥/៥២**

## វិធានផ្សះផ្សានៃគណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ

មហាសន្និបាតអង្គការសហប្រជាជាតិ

**ដោយទទួលស្គាល់**តំលៃនៃការផ្សះផ្សាថា ជាវិធីសាស្ត្រដោះស្រាយដោយសន្តិវិធីលើវិវាទនានា ដែលកើតមានឡើងក្នុងបរិបទទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។

**ដោយយល់ស្រប**ថា ការបង្កើតវិធានផ្សះផ្សាដែលអាចទទួលយកបាននៅក្នុងប្រទេសនានា ដែលមានប្រព័ន្ធច្បាប់សង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា នឹងចូលរួមចំណែកយ៉ាងសំខាន់ចំពោះការអភិវឌ្ឍន៍ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិដោយសុខដុមរមនា។

**ដោយកត់សំគាល់**ថា វិធានផ្សះផ្សារបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីច្បាប់ ពាណិជ្ជកម្មអន្តរជាតិ ត្រូវបានអនុម័តដោយគណៈកម្មការនៅឯកិច្ចប្រជុំលើកទីដប់បី[៣០៦] បន្ទាប់ពីបានពិចារណា លើសេចក្តីសង្កេតរបស់រដ្ឋាភិបាល និងអង្គការដែលមានចំណាប់អារម្មណ៍នានា។

១. **ដាក់ជាអនុសាសន៍** ឱ្យប្រើប្រាស់វិធានផ្សះផ្សារបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិក្នុងករណីទាំងឡាយដែលវិវាទកើតឡើង ក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ហើយឱ្យភាគីវិវាទស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះវិវាទនោះដោយអាស្រ័យលើ ការផ្សះផ្សា។

២. **ស្នើរ**អគ្គលេខាធិការរៀបចំឱ្យមានការចែកចាយវិធានផ្សះផ្សារនេះ ឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើបាន។

# វិធានផ្សះផ្សា UNCITRAL

**ការអនុវត្តវិធាន**

**មាត្រា ១**

(១) វិធានទាំងនេះអនុវត្តចំពោះការផ្សះផ្សាវិវាទកើតចេញពី ឬពាក់ព័ន្ធទៅនឹងទំនាក់ទំនងកិច្ចសន្យា ឬទំនាក់ទំនងផ្លូវច្បាប់ដទៃទៀត ដោយក្នុងនោះ ភាគីវិវាទដែលស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះវិវាទរបស់ខ្លួន បានព្រមព្រៀងយកការប្រើប្រាស់វិធានផ្សះផ្សា UNCITRAL ។

(២) ភាគីវិវាទអាចព្រមព្រៀងគ្នាដោយមិនរាប់បញ្ចូល ឬផ្លាស់ប្តូរវិធានណាមួយបានគ្រប់ពេល ។

(៣) នៅពេលដែលមានវិធានណាមួយ មានទំនាស់នឹងបទប្បញ្ញត្តិនៃច្បាប់ ដែលភាគីវិវាទមិនអាចធ្វើបដិប្បញ្ញត្តិ បាននោះ បទប្បញ្ញត្តិនៃច្បាប់នោះនឹងត្រូវយកមកអនុវត្ត ។

**ការចាប់ផ្តើមដំណើរការផ្សះផ្សា**

**មាត្រា ២**

(១) ភាគីដែលផ្តួចផ្តើមការផ្សះផ្សា ត្រូវផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងទៀត ដើម្បីផ្សះផ្សាតាមវិធាននេះ ដោយធ្វើការបង្ហាញកម្មវត្ថុនៃវិវាទនោះដោយសង្ខេបផង ។

(២) ដំណើរការផ្សះផ្សា ចាប់ផ្តើមនៅពេលភាគីម្ខាងទៀតទទួលយកការអញ្ជើញដើម្បីផ្សះផ្សា ។ ក្នុងករណីដែលការទទួលយកនោះធ្វើឡើងដោយផ្ទាល់មាត់ ជាការល្អគួរតែធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរដែរ ។

(៣) ប្រសិនបើភាគីម្ខាងទៀតបដិសេធការអញ្ជើញនោះ ដំណើរការផ្សះផ្សានឹងមិនកើតឡើងឡើយ ។

(៤) ប្រសិនបើភាគីដែលផ្តួចផ្តើមការផ្សះផ្សា មិនបានទទួលចម្លើយតបក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃផ្ញើរលិខិតអញ្ជើញមក ឬក្នុងរយៈពេលផ្សេងទៀតដូចមានបញ្ជាក់នៅក្នុងលិខិតអញ្ជើញ ភាគីនោះអាចសម្រេចចិត្តដោយចាត់ទុកថានេះជាការបដិសេធការអញ្ជើញដើម្បីផ្សះផ្សា ។ ប្រសិនបើមានការសម្រេចយ៉ាងដូច្នេះ ភាគីផ្តួចផ្តើមត្រូវជូនដំណឹងនេះទៅភាគីម្ខាងទៀត ។

**ចំនួនអ្នកផ្សះផ្សា**

**មាត្រា ៣**

អ្នកផ្សះផ្សាមានតែមួយរូប លើកលែងតែភាគីវិវាទព្រមព្រៀងឱ្យមានអ្នកផ្សះផ្សាពីរ ឬបីរូប ។ ជាវិធានទូទៅនៅពេលដែលមានអ្នកផ្សះផ្សាលើសពីមួយរូប ពួកគេគួរតែធ្វើការរួមគ្នា ។

**ការតែងតាំងអ្នកផ្សះផ្សា**

**មាត្រា ៤**

(១) (ក) នៅក្នុងដំណើរការផ្សះផ្សាដែលមានអ្នកផ្សះផ្សាម្នាក់ ភាគីវិវាទគួរតែខិតខំខ្នែងឱ្យឈានទៅដល់ការឯកភាពគ្នាលើឈ្មោះអ្នកផ្សះផ្សាតែម្នាក់គត់ ។

(ខ) នៅក្នុងដំណើរការផ្សះផ្សាដែលមានអ្នកផ្សះផ្សាពីររូប ភាគីនិមួយៗត្រូវតែងតាំងអ្នកផ្សះផ្សាម្នាក់រៀងខ្លួន ។

(គ) នៅក្នុងដំណើរការផ្សះផ្សាដែលមានអ្នកផ្សះផ្សាបីរូប ភាគីនិមួយៗតែងតាំងអ្នកផ្សះផ្សាម្ខាងម្នាក់ ។ ភាគីវិវាទគួរតែខិតខំខ្នែងឱ្យឈានទៅដល់ការឯកភាពគ្នាលើឈ្មោះអ្នកផ្សះផ្សាទីបី ។

(២) ភាគីវិវាទអាចរកជំនួយពីស្ថាប័ន ឬបុគ្គលណាមួយដែលសមស្រប ក្នុងទំនាក់ទំនងនៃការតែងតាំងអ្នកផ្សះផ្សា ។ ជាពិសេសៈ

(ក) ភាគីម្ខាងអាចស្នើស្ថាប័ន ឬបុគ្គលនោះឱ្យឧទ្ទេសនាមបុគ្គលសមស្របដើម្បីធ្វើជាអ្នកផ្សះផ្សា ឬ

(ខ) ភាគីវិវាទអាចព្រមព្រៀងឱ្យមានការតែងតាំងអ្នកផ្សះផ្សាម្នាក់ ឬច្រើនដោយស្ថាប័ន ឬបុគ្គលនោះផ្ទាល់ ។

នៅក្នុងការឧទ្ទេសនាម ឬតែងតាំងបុគ្គលណាមួយឱ្យធ្វើជាអ្នកផ្សះផ្សា ស្ថាប័ន ឬបុគ្គលនោះត្រូវធ្វើការពិចារណានានាដែលអាចធានាបាននូវការតែងតាំងអ្នកផ្សះផ្សាដែលឯករាជ្យ និងមិនលម្អៀង ហើយនៅពេលជ្រើសរើសអ្នកផ្សះផ្សាតែម្នាក់ ឬអ្នកផ្សះផ្សាទីបី ត្រូវពិចារណាពីលទ្ធភាពនៃការតែងតាំងអ្នក ផ្សះផ្សាមួយរូបណាដែលមានសញ្ជាតិក្រៅពីសញ្ជាតិរបស់ភាគីវិវាទ ។

**ការចាក់ចណ្តឹងទៅអ្នកផ្សះផ្សា**

**មាត្រា ៥**

(១) អ្នកផ្សះផ្សា* បន្ទាប់ពីការតែងតាំងរួច ត្រូវស្នើរភាគីនិមួយៗឱ្យផ្ញើរបណ្តឹងលាយលក្ខណ៍អក្សរជា សង្ខេបដែលពិព័ណ៌នាពីចរិតទូទៅនៃវិវាទនិងចំនុចដែលចោទជាបញ្ហា ។ ភាគីនិមួយៗក៏ត្រូវផ្ញើរច្បាប់ចំលង នៃបណ្តឹងរបស់ខ្លួនទៅភាគីម្ខាងទៀតដែរ ។

(២) អ្នកផ្សះផ្សាអាចស្នើភាគីនិមួយៗឱ្យផ្ញើរសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរបន្ថែមទៀត ស្តីពីគោលជំហររបស់ខ្លួន ព្រមទាំងអង្គហេតុនិងមូលដ្ឋានគាំទ្រផ្សេងៗភ្ជាប់ទៅដោយឯកសារ និងភស្តុតាងទាំងឡាយណាដែលភាគីនោះយល់ថាសមស្រប ។ ភាគីត្រូវផ្ញើរឯកសារចំលងមួយច្បាប់ទៅភាគីម្ខាង ទៀតផងដែរ ។

(៣) នៅក្នុងដំណាក់កាលណាក៏ដោយនៃដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចស្នើភាគីណាមួយឱ្យផ្ញើរព័ត៌មានបន្ថែមទាំងនោះ តាមការដែលខ្លួនយល់ឃើញថាសមស្រប ។

**តំណាង និងជំនួយ**

**មាត្រា ៦**

ភាគីវិវាទអាចមានអ្នកតំណាង ឬអ្នកផ្តល់ជំនួយជាបុគ្គលដែលខ្លួនជ្រើសរើស។ ឈ្មោះ និង អាសយដ្ឋានរបស់បុគ្គលទាំងនោះ ត្រូវតែបានផ្តល់ព័ត៌មានជាលាយលក្ខ័អក្សរទៅកាន់ភាគីម្ខាងទៀត និងអ្នកផ្សះផ្សាផងដែរ ដោយត្រូវបញ្ជាក់ថាការតែងតាំងនោះធ្វើឡើងក្នុងគោលបំណងសម្រាប់ធ្វើជាអ្នកតំណាង ឬធ្វើជាអ្នកផ្តល់ជំនួយ។

**តួនាទីរបស់អ្នកផ្សះផ្សា**

**មាត្រា ៧**

(១) អ្នកផ្សះផ្សាជួយភាគីវិវាទក្នុងរបៀបមួយដែលឯករាជ្យ និងមិនលម្អៀង ក្នុងការដែលខ្លួនខិតខំខ្នែងដើម្បីបានឈានទៅដល់ដំណោះស្រាយមួយប្រកបដោយសន្តិវិធីចំពោះវិវាទរបស់ពួកគេ ។

(២) អ្នកផ្សះផ្សាត្រូវប្រើប្រាស់គោលការណ៍អញ្ញាថាភាពត្រឹមត្រូវ និងយុត្តិធម៌ជាត្រីមុខ ដោយត្រូវពិចារណាលើកត្តាផ្សេងៗដូចជាសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីវិវាទ ទម្លាប់ប្រើប្រាស់នៃជំនួញដែលពាក់ព័ន្ធ និងកាលៈ-ទេសៈនានានៅជុំវិញវិវាទ រួមទាំងបែបបទអាជីវកម្មដែលភាគីវិវាទបានអនុវត្តន៍ពីមុនមក។

(៣) អ្នកផ្សះផ្សាអាចដឹកនាំដំណើរការផ្សះផ្សា ក្នុងបែបបទមួយដែលខ្លួនយល់ថាសមស្រប ដោយលើកមកពិចារណានូវកាលៈទេសៈផ្សេងៗនៃរឿងក្តី បំណងប្រាថ្នាដែលភាគីវិវាទអាចបង្ហាញ រួមទាំងសម្នើរបស់ភាគីម្ខាងឱ្យអ្នកផ្សះផ្សាស្តាប់បំនកស្រាយផ្ទាល់មាត់ ព្រមទាំងតម្រូវការនូវដំណោះស្រាយដ៏ឆាប់រហ័សមួយនៃវិវាទជាដើម។

(៤) នៅគ្រប់ដំណាក់កាលនៃដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចធ្វើសម្នើនានាក្នុងការបញ្ចប់វិវាទ។ សម្នើទាំងនោះមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរ និងមិនចាំបាច់អមដោយសេចក្តីអធិប្បាយអំពីហេតុផល នៃសម្នើនោះឡើយ។

**ជំនួយផ្នែករដ្ឋបាល**

**មាត្រា ៨**

(១) ដើម្បីជួលសម្រួលដល់ការដឹកនាំដំណើរការផ្សះផ្សា ភាគីវិវាទ ឬអ្នកផ្សះផ្សា ដោយមានការឯកភាពពីភាគីវិវាទ អាចចាត់ឱ្យមានជំនួយរដ្ឋបាលពីសំណាក់ស្ថាប័ន ឬដោយបុគ្គលណាមួយដែលសមស្រប ។

**ការឆ្លើយឆ្លងរវាងអ្នកផ្សះផ្សានិងភាគីវិវាទ**

**មាត្រា ៩**

(១) អ្នកផ្សះផ្សាអាចអញ្ជើញភាគីវិវាទឱ្យមកជួបខ្លួន ឬអាចឆ្លើយឆ្លងជាមួយពួកគេដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ អ្នកផ្សះផ្សាអាចជួប ឬឆ្លើយឆ្លងជាមួយភាគីវិវាទរួមគ្នា ឬជាមួយភាគីនិមួយៗ ដោយឡែកពីគ្នា ។

(២) លើកលែងតែភាគីវិវាទបានព្រមព្រៀងលើទីកន្លែងសម្រាប់ធ្វើការប្រជុំជាមួយអ្នកផ្សះផ្សា ទីកន្លែងប្រជុំនឹងត្រូវសម្រេចដោយអ្នកផ្សះផ្សា បន្ទាប់ពីបានប្រឹក្សាយោបល់ជាមួយភាគីវិវាទ ដោយមើលតាមកាលៈទេសៈផ្សេងៗនៃដំណើរការផ្សះផ្សា។

**ការបង្ហាញព័ត៌មាន**

**មាត្រា ១០**

នៅពេលដែលអ្នកផ្សះផ្សាទទួលព័ត៌មានស្តីពីអង្គហេតុទាក់ទងនឹងវិវាទពីភាគីម្ខាង អ្នកផ្សះផ្សាបង្ហាញខ្លឹមសារនៃព័ត៌មាននោះដល់ភាគីម្ខាងទៀត ដើម្បីឱ្យភាគីម្ខាងទៀតអាចមានឱកាសក្នុងការបង្ហាញបំនកស្រាយណាមួយដែលខ្លួនគិតថាសមស្រប។ ក៏ប៉ុន្តែ នៅពេលដែលភាគីម្ខាងផ្តល់ព័ត៌មានទៅកាន់អ្នកផ្សះផ្សា ដោយភ្ជាប់នូវលក្ខខ័ណ្ឌជាក់លាក់ថាត្រូវរក្សាការសម្ងាត់ អ្នកផ្សះផ្សាមិនបង្ហាញព័ត៌មាន ទៅភាគីម្ខាងទៀតឡើយ។

**ការសហការរបស់ភាគីវិវាទជាមួយអ្នកផ្សះផ្សា**

**មាត្រា ១១**

ភាគីវិវាទត្រូវសហការដោយស្មោះត្រង់ជាមួយអ្នកផ្សះផ្សា ហើយជាពិសេសត្រូវខិតខំខ្នែងធ្វើតាមសម្នើ របស់អ្នកផ្សះផ្សា ក្នុងការផ្ញើឯកសារលាយលក្ខណ៍អក្សរនានា ការផ្តល់ភស្តុតាង និងការចូលរួមប្រជុំ ។

**សំណូមពររបស់ភាគីដើម្បីបញ្ចប់វិវាទ**

**មាត្រា ១២**

ភាគីនិមួយៗ អាចផ្ញើរទៅកាន់អ្នកផ្សះផ្សានូវសំណូមពររបស់ខ្លួនដើម្បីបញ្ចប់វិវាទ តាមការផ្តួចផ្តើមផ្ទាល់ ខ្លួន ឬតាមការអញ្ជើញរបស់អ្នកផ្សះផ្សា។

**កិច្ចព្រមព្រៀងបញ្ចប់វិវាទ**

**មាត្រា ១៣**

(១) នៅពេលដែលអ្នកផ្សះផ្សាមើលឃើញថាមានធាតុផ្សំផ្សេងៗសម្រាប់បញ្ចប់វិវាទ ដែលភាគីវិវាទ អាចទទួលយកបាន អ្នកផ្សះផ្សាតាក់តែងលក្ខខណ្ឌផ្សេងៗនៃលទ្ធភាពបញ្ចប់វិវាទ ហើយផ្ញើរទៅកាន់ភាគីវិវាទ ដើម្បីធ្វើការសង្កេត។ បន្ទាប់ពីទទួលបានសេចក្តីសង្កេតពីភាគីវិវាទរួច អ្នកផ្សះផ្សាអាចតាក់តែង ឡើងវិញនូវលក្ខខណ្ឌផ្សេងៗនៃលទ្ធភាពបញ្ចប់វិវាទ ដោយផ្អែកទៅលើសេចក្តីសង្កេតទាំងនោះ ។

(២) ប្រសិនបើភាគីវិវាទឈានដល់ការព្រមព្រៀងបញ្ចប់វិវាទ ពួកគេត្រូវរៀបរៀង និងចុះហត្ថលេខាលើលិខិតព្រមព្រៀងបញ្ចប់វិវាទនោះ។** ប្រសិនបើមានសំណើពីភាគីវិវាទ អ្នកផ្សះផ្សាក៏ត្រូវធ្វើពង្រាង ឬជួយភាគីវិវាទនៅក្នុងការធ្វើពង្រាងកិច្ចព្រមព្រៀងបញ្ចប់វិវាទនោះ។

(៣) ដោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់វិវាទ ភាគីវិវាទដាក់វិវាទរបស់ខ្លួនជាអាវសាន ហើយត្រូវជាប់កាតព្វកិច្ចតាមកិច្ចព្រមព្រៀងនោះ។

**ការរក្សាការសម្ងាត់**

**មាត្រា ១៤**

អ្នកផ្សះផ្សា និងភាគីវិវាទត្រូវរក្សាការសម្ងាត់ចំពោះរាល់បញ្ហាដែលទាក់ទងនឹងដំណើរការផ្សះផ្សា។ ការសម្ងាត់ក៏ត្រូវរក្សាឱ្យបានផងដែរនៅក្នុងកិច្ចព្រមព្រៀងបញ្ចប់វិវាទ លើកលែងតែ ការបញ្ចេញការសម្ងាត់នោះមានភាពចាំបាច់នៅក្នុងគោលបំណងអនុវត្ត និងជំរុញការអនុវត្ត។

**ការបញ្ចប់ដំណើរការផ្សះផ្សា**

**មាត្រា ១៥**

ដំណើរការផ្សះផ្សាត្រូវបញ្ចប់តាមកាលវេលាដូចក្នុងករណីខាងក្រោមៈ

(ក) បើមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់វិវាទដោយភាគីវិវាទ គឺត្រឹមកាលបរិច្ឆេទនៃកិច្ច-ព្រមព្រៀងនោះ ឬ

(ខ) បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់អ្នកផ្សះផ្សា បន្ទាប់ពីមានការប្រឹក្សាយោបល់ជាមួយភាគីវិវាទ ចំពោះលទ្ធផលដែលថាកិច្ចខិតខំប្រឹងប្រែងផ្សះផ្សាបន្តទៀតនោះលែងជាការត្រឹមត្រូវ គឺត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាសនោះ ឬ

(គ) បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ធ្វើឡើងដោយភាគីវិវាទទៅកាន់អ្នកផ្សះផ្សា ចំពោះលទ្ធផលដែលថា ដំណើរការផ្សះផ្សានឹងត្រូវបញ្ឈប់ គឺត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាសនោះ ឬ

(ឃ) បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ភាគីម្ខាងទៅភាគីម្ខាងទៀត ព្រមទាំងអ្នក ផ្សះផ្សា ប្រសិនបើមានការតែងតាំងរួចហើយ ចំពោះលទ្ធផលដែលថា ដំណើរការផ្សះផ្សានឹងត្រូវបញ្ឈប់ គឺត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាសនោះ។

**ការស្រ័យទាក់ទីតិវិធីមជ្ឈត្តការ ឬតុលាការ**

**មាត្រា ១៦**

ក្នុងពេលមានដំណើរការផ្សះផ្សា ភាគីវិវាទត្រូវឯកភាពថាមិនផ្តួចផ្តើមដំណើរការមជ្ឈត្តការ ឬនីតិវិធី តុលាការ ចំពោះវិវាទដែលជាកម្មវត្ថុនៃដំណើរការនេះឡើយ លើកលែងតែថាមានភាគីណាមួយយល់ ឃើញថា នីតិវិធីទាំងនេះមានភាពចាំបាច់ក្នុងការការពារសិទ្ធិរបស់ខ្លួន ទើបភាគីនោះអាចផ្តួចផ្តើម ដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការបាន។

**ថ្លៃចំណាយផ្សេងៗ**

**មាត្រា ១៧**

(១) នៅពេលដែលដំណើរការផ្សះផ្សាត្រូវបានបញ្ចប់ អ្នកផ្សះផ្សាត្រូវកំនត់ថ្លៃចំណាយលើការផ្សះផ្សា និងផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីវិវាទ។ ពាក្យថា "ថ្លៃចំណាយ" រួមមានត្រឹមតែ:

(ក) ថ្លៃឈ្នួលសម្រាប់អ្នកផ្សះផ្សាដែលត្រូវមានចំនួនសមរម្យ

(ខ) ថ្លៃធ្វើដំណើរ និងការចំណាយដទៃទៀតរបស់អ្នកផ្សះផ្សា

(គ) ថ្លៃធ្វើដំណើរ និងការចំណាយដទៃទៀតរបស់សាក្សីដែលបានស្នើឡើងដោយអ្នកផ្សះផ្សា និងដោយមានការយល់ព្រមពីភាគីវិវាទ

(ឃ) ថ្លៃពិគ្រោះជាមួយអ្នកជំនាញការដែលបានស្នើឡើងដោយអ្នកផ្សះផ្សា និងដោយមានការ យល់ព្រមពីភាគីវិវាទ

(ង) ថ្លៃចំណាយលើជំនួយដែលបានផ្តល់ឱ្យ ដូចមានចែងក្នុងមាត្រា៤ កថាខ័ណ្ឌ(២)(ខ) និង មាត្រា៨ នៃវិធាននេះ។

(២) ថ្លៃចំណាយ ដូចក្នុងនិយមន័យខាងលើ គឺជាបន្ទុកស្មើគ្នារបស់ភាគីវិវាទលើកលែងតែកិច្ចព្រមព្រៀង បញ្ចប់វិវាទមានចែងពីការបែងចែកផ្សេងពីនេះ។ រាល់សោហ៊ុយផ្សេងទៀតដែលភាគីម្ខាងបានចំណាយ គឺជាបន្ទុករបស់ភាគីនោះ។

**ប្រាក់តម្កល់**

**មាត្រា ១៨**

(១) នៅពេលត្រូវបានតែងតាំង អ្នកផ្សះផ្សាអាចស្នើភាគីនិមួយៗឱ្យតម្កល់ប្រាក់ចំណាយស្មើៗគ្នាដែលជាប្រាក់កក់សម្រាប់ថ្លៃចំណាយផ្សេងៗដូចមានរៀបរាប់នៅក្នុងមាត្រា១៧ កថាខ័ណ្ឌ(១) តាមការដែលខ្លួនរំពឹងថានឹងត្រូវការដើម្បីទូទាត់ ។

(២) នៅក្នុងពេលដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចស្នើសុំប្រាក់តម្កល់បន្ថែមនៅក្នុងចំនួនស្មើគ្នាពីភាគីនិមួយៗ។

(៣) ប្រសិនបើភាគីវិវាទទាំងសងខាងមិនបានបង់ប្រាក់តម្កល់ដែលបានតម្រូវក្នុងកថាខ័ណ្ឌ(១) និង(២) នៃមាត្រានេះ ឱ្យបានគ្រប់ក្នុងរយៈពេលសាមសិបថ្ងៃនោះទេ អ្នកផ្សះផ្សាអាចពន្យាដំណើរការ ឬអាចធ្វើសេចក្ដីប្រកាសជាលាយលក្ខណ៍អក្សរអំពីការបញ្ឈប់ដំណើរការនោះ ជូនទៅភាគីវិវាទ ដែលមានប្រសិទ្ធិភាពចាប់ពីថ្ងៃប្រកាសនោះតទៅ ។

(៤) នៅពេលបញ្ឈប់ដំណើរការផ្សះផ្សា អ្នកផ្សះផ្សាត្រូវប្រគល់ជូនរបាយការណ៍គណនេយ្យដល់ភាគីវិវាទដែលបានបង់ប្រាក់តម្កល់ និងត្រូវប្រគល់សមតុល្យដែលមិនបានចំណាយជូនភាគីទាំងនោះវិញ ។

**តួនាទីអ្នកផ្សះផ្សានៅក្នុងនីតិវិធីដទៃទៀត**

**មាត្រា ១៩**

ភាគីវិវាទ និងអ្នកផ្សះផ្សាត្រូវទទួលយល់ព្រមថា អ្នកផ្សះផ្សានឹងមិនដើរតួជាមជ្ឈត្តករ ឬជាតំណាង ឬជាអ្នកពិគ្រោះយោបល់របស់ភាគីម្ខាងនៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការ ពាក់ព័ន្ធនឹងវិវាទដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សានោះឡើយ ។ ភាគីវិវាទក៏ត្រូវទទួលយល់ព្រមផងដែរថា ខ្លួននឹងមិនយកអ្នកផ្សះផ្សាធ្វើជាសាក្សីនៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការនោះឡើយ ។

**ការប្រើប្រាស់ភស្តុតាងនៅក្នុងដំណើរការដទៃទៀត**

**មាត្រា ២០**

នៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការ ទោះជានីតិវិធីទាំងនោះពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងវិវាទដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សានេះក៏ដោយ ភាគីវិវាទត្រូវទទួលយល់ព្រមថាមិននឹងពឹងផ្អែក ឬប្រើប្រាស់ជាភស្តុតាងនូវៈ

(ក) ទស្សនៈដែលបានសំដែងចេញ ឬសំណូមពររបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងលទ្ធភាពនៃការបញ្ចប់វិវាទ

(ខ) ការព្រមទទួលយករបស់ភាគីម្ខាងទៀតក្នុងអំឡុងពេលនៃដំណើរការផ្សះផ្សា

(គ) សម្ទើដែលធ្វើឡើងដោយអ្នកផ្សះផ្សា

(ឃ) ហេតុដែលថាភាគីម្ខាងទៀតបានសំដែងឆន្ទៈរបស់ខ្លួនក្នុងការទទួលសម្ទើបញ្ហាវិវាទ ដែលធ្វើឡើងដោយអ្នកផ្សះផ្សា។

**ខផ្សះផ្សាគម្រូ**

នៅពេលមានវិវាទណាមួយកើតចេញពី ឬជាប់ពាក់ព័ន្ធនឹងកិច្ចសន្យានេះ ហើយភាគីវិវាទចង់ស្វែងរកដំណោះស្រាយមួយដោយសន្តិវិធីលើវិវាទនោះតាមរយៈការផ្សះផ្សា ការផ្សះផ្សានោះត្រូវធ្វើឡើងដោយអនុលោមតាមវិធានផ្សះផ្សា UNCIT RAL ដែលមានជាធរមាន។

(ភាគីវិវាទអាចព្រមព្រៀងលើខផ្សះផ្សាដទៃទៀត។)

---

ពត៌មានបន្ថែមអាចទទួលពីៈ
អគ្គលេខាធិការដ្ឋាន UNCITRAL
មជ្ឈមណ្ឌលអន្តរជាតិនៅក្រុងវៀន
ប្រអប់សំបុត្រ P.O Box 500
A- 1400 ទីក្រុងវៀន ប្រទេសអូទ្រីស
ទូរស័ព្ទ: (+៤៣ ១) ២៦០៦០-៤០៦០
ហ្វាក់: (+៤៣ ១) ២៦០៦០- ៥៨១៣
អ៊ិនធឺណែត: http://www.uncitral.org
អ៊ីមែល: uncitral@uncitral.org

**ឧបសម្ព័ន្ធ២.**

## ផ្នែកទី I : បទបញ្ញត្តិទូទៅ


ដែនកំណត់នៃការអនុវត្តន៍ (មាត្រា ១) និងឧតម្រូស្តីពីមជ្ឈត្តការ

ការជូនដំណឹង ការគណនាពេលវេលា (មាត្រា ២)

ការជូនដំណឹងអំពីមជ្ឈត្តការ (មាត្រា ៣)

តំណាង និងជំនួយ (មាត្រា ៤)


## ផ្នែកទី II : សមាសភាពនៃវេទិកាមជ្ឈត្តកម្ម


ចំនួនមជ្ឈត្តករ ( មាត្រា ៥)

ការតែងតាំងមជ្ឈត្តករ ( មាត្រា ៦ ដល់ ៨)

ការជំទាស់ទៅនឹងមជ្ឈត្តករ ( មាត្រា ៩ ដល់ ១២)

ការផ្លាស់ប្តូរមជ្ឈត្តករ ( មាត្រា ១៣ )

ការធ្វើសវនាការឡើងវិញក្នុងករណីមានការផ្លាស់ប្តូរមជ្ឈត្តករ ( មាត្រា ១៤ )


## ផ្នែកទីIII : នីតិវិធីមជ្ឈត្តការ


បទប្បញ្ញត្តិទូទៅ ( មាត្រា ១៥)

ទីកន្លែងធ្វើមជ្ឈត្តការ ( មាត្រា ១៦ )

ភាសា ( មាត្រា ១៧ )

បណ្តឹងទាមទារ ( មាត្រា ១៨ )

បណ្តឹងដោះសា ( មាត្រា ១៩ )

ការកែប្រែលើបណ្តឹងទាមទារ ឬ ដោះសា ( មាត្រា ២០)

ការជំទាស់ចំពោះសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម ( មាត្រា ២១)

បណ្តឹងលាយលក្ខណ៍អក្សរបន្ថែមដទៃទៀត ( មាត្រា ២២ )

ថេរៈវេលាផ្សេងៗ ( មាត្រា ២៣ )

ភស្តុតាង និងសវនាការ ( មាត្រា ២៤ និង ២៥ )

វិធានការណ៍បណ្តោះអាសន្នដើម្បីការពារ ( មាត្រា ២៦ )

ជំនាញការ ( មាត្រា ២៧ )

ការខកខាន ( មាត្រា ២៨ )

ការបិទសវនាការ ( មាត្រា ២៩ )

ការលើកលែងចំពោះវិធានផ្សេងៗ ( មាត្រា ៣០ )

**ផ្នែកទី IV : មជ្ឈត្តវិនិច្ឆ័យ**

ការសម្រេចផ្សេងៗ ( មាត្រា ៣១ )

ទម្រង់ និងអានុភាពនៃមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣២ )

ប្រព័ន្ធច្បាប់សម្រាប់អនុវត្ត ការស្រុះស្រួល *(umiable compositer)* ( មាត្រា ៣៣ )

ការស្រុះស្រួល ឬមូលដ្ឋានដទៃទៀតដើម្បីបញ្ចប់វិវាទ ( មាត្រា ៣៤ )

ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣៥)

កំណែតម្រូវលើមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣៦ )

មជ្ឈត្តវិនិច្ឆ័យបន្ថែម ( មាត្រា ៣៧)

ថ្លៃចំណាយផ្សេងៗ ( មាត្រា ៣៨ ទៅ ៤០)

ការតម្កល់ប្រាក់ចំណាយ ( មាត្រា៤១)

## សេចក្តីសម្រេច លេខ ៣១/៩៨ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៥ ធ្នូ ១៩៧៦

៣១/៩៨ វិធានមជ្ឈត្តការរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ

**មហាសន្និបាត**

**ដោយទទួលស្គាល់**នូវតម្លៃនៃមជ្ឈត្តការ ជាវិធីដោះស្រាយវិវាទមួយដែលកើតមានឡើងនៅក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ។

**ដោយជឿជាក់**ថា ការបង្កើតវិធានសម្រាប់ការធ្វើមជ្ឈត្តការពិសេស ដែលអាចទទួលយកបាននៅក្នុងប្រទេសនានាដែលមានប្រព័ន្ធច្បាប់ សង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការងារអភិវឌ្ឍន៍ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិដោយសុខដុមរមនា ។

**ដោយគូសចំណាំថា** វិធានមជ្ឈត្តការនៃគណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានរៀបចំឡើងបន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័ន និងមជ្ឈមណ្ឌលមជ្ឈត្តការនានា ក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ ។

**ដោយកត់សម្គាល់ថា** វិធានមជ្ឈត្តការត្រូវបានអនុម័តដោយគណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ នៅឯកិច្ចប្រជុំទី៩[៣០៧] បន្ទាប់ពីការពិភាក្សាយ៉ាងហ្មត់ចត់រួច ។

១. **ដាក់ជាអនុសាសន៍** ឱ្យប្រើប្រាស់វិធានមជ្ឈត្តការរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៅក្នុងការដោះស្រាយវិវាទ ដែលកើតមាននៅក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ជាពិសេសដោយអនុលោមតាមវិធានមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម ។

២. **ស្នើ**អគ្គលេខាធិការអង្គការសហប្រជាជាតិ រៀបចំឱ្យមានការចែកចាយវិធានមជ្ឈត្តការនេះឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ។

---

[៣០៧] កំណត់ត្រាផ្លូវការរបស់មហាសន្និបាត កិច្ចប្រជុំលើកទី៣១ អត្ថបទបន្ថែមលេខ ១៧ (A/៣១/១៧) ជំពូក V ផ្នែក C ។

# វិធានមជ្ឈត្តការ UNCITRAL

## ផ្នែកទី I: វិធានផ្ដើម

**វិសាលភាពនៃការអនុវត្ត**

**មាត្រា ១**

១. នៅពេលដែលគូរភាគីនៃកិច្ចសន្យាណាមួយបានយល់ស្របជាលាយលក្ខណ៍អក្សរ* ថាវិវាទទាំងឡាយណាដែលកើតចេញពីកិច្ចសន្យានោះ នឹងត្រូវយកមកធ្វើមជ្ឈត្តការក្រោមវិធានមជ្ឈត្តការ UNCITRAL វិវាទទាំងនោះនឹងត្រូវបានដោះស្រាយឱ្យស្របទៅនឹងវិធានទាំងនេះ វាវលែងតែមានកំណែប្រែណាដែលភាគីវិវាទអាចព្រមព្រៀងជាលាយលក្ខណ៍អក្សរ។

២. វិធានទាំងនេះត្រូវគ្រប់គ្រងលើការធ្វើមជ្ឈត្តការនោះ លើកលែងតែមានវិធានណាផ្ទុយទៅនឹងបទប្បញ្ញត្តិនៃច្បាប់សម្រាប់អនុវត្តចំពោះមជ្ឈត្តការនោះ ដែលភាគីវិវាទមិនអាចធ្វើបដិប្បញ្ញត្តិបាន ទើបត្រូវយកបទប្បញ្ញត្តិនោះមកអនុវត្ត។

---

*ខគម្រូស្ដីពីមជ្ឈត្តការ

វិវាទ វាទប្បដិវាទ ឬការទាមទារណាមួយ ដែលកើតចេញពីឬមានទំនាក់ទំនងនឹងកិច្ចសន្យានេះ ឬក៏ការរំលោភ ការបញ្ចប់ ឬមោឃភាពនៃកិច្ចសន្យានេះ នឹងត្រូវដោះស្រាយតាមបែបមជ្ឈត្តការ ដោយអនុលោមតាមវិធានមជ្ឈត្តការនៃ UNCITRAL ដែលមានជាធរមាន។

កំណត់សម្គាល់- ភាគីទាំងអស់អាចពិចារណាបន្ថែមនូវព័ត៌មានដូចខាងក្រោម:

(ក) អង្គាធរដែលត្រូវបានជ្រើសតាំងឡើងគឺជា....... (ឈ្មោះនីតិបុគ្គល ឬរូបវន្តបុគ្គល)

(ខ) ចំនួនមជ្ឈត្តករគឺ................ (មួយ ឬបី)

(គ) ទីកន្លែងធ្វើមជ្ឈត្តការគឺ... (ឈ្មោះក្រុង ឬប្រទេស)

(ឃ) ភាសា (មួយ ឬច្រើន) ប្រើនៅក្នុងដំណើរការនីតិវិធីមជ្ឈត្តការគឺ................

---

**ការជូនដំណឹង ការគណនាពេលវេលា**

**មាត្រា ២**

១. នៅក្នុងវិធានទាំងនេះ ការជូនដំណឹងតាមរូបភាពណាមួយ រួមទាំងការផ្ដល់ដំណឹង លិខិតឆ្លើយឆ្លង ឬសម្មើ នឹងត្រូវចាត់ទុកថាបានទទួល ប្រសិនបើការជូនដំណឹងនោះ ត្រូវបានបញ្ជូនទៅដល់អសយដ្ឋាន

អ្នកទទួលនោះផ្ទាល់ ឬត្រូវបានផ្ញើទៅលំនៅស្ថានអចិន្ត្រៃយ៍ ទីកន្លែងអាជីវកម្ម ឬអាសយដ្ឋានទទួលសំបុត្ររបស់អ្នកទទួល ឬក្នុងករណីដែល បន្ទាប់ពីបានស៊ើបសួររួចមក គេមិនអាចរកឃើញអាសយដ្ឋានទាំងនោះទេ ការជូនដំណឹងនេះត្រូវផ្ញើទៅនិវាសដ្ឋាន ឬកន្លែងអាជីវកម្មដែលគេស្គាល់ចុងក្រោយបង្អស់។ ការជូន ដំណឹង ត្រូវសន្មតថាបានទទួលនៅថ្ងៃដែលបានផ្ញើទៅដល់។

២. ក្នុងការគណនាពេលវេលាក្រោមវិធានទាំងនេះ គេត្រូវគិតពេលវេលានោះចាប់ពីថ្ងៃ បន្ទាប់ពីថ្ងៃដែលការប្រកាស សេចក្តីជូនដំណឹង លិខិតឆ្លើយឆ្លង ឬសម្តីណាមួយត្រូវបានទទួល។ ប្រសិនបើថ្ងៃចុងក្រោយនៃថេរៈវេលានោះជាថ្ងៃវិសម្មកាលផ្លូវការ ឬថ្ងៃឈប់សម្រាកពីការងារនៅឯលំនៅស្ថាន ឬកន្លែងអាជីវកម្មរបស់អ្នកទទួល ថេរៈវេលានោះនឹងត្រូវពន្យារហូតដល់ថ្ងៃធ្វើការដំបូងបន្ទាប់ពីនោះមក។ វិសម្មកាលផ្លូវការ ឬថ្ងៃឈប់សម្រាកដែលមានក្នុងចន្លោះពេលនោះ នឹងត្រូវរាប់បញ្ចូលក្នុងពេលវេលាដែលត្រូវគណនាជាធម្មតា។

**ការជូនដំណឹងអំពីមជ្ឈត្តការ**

**មាត្រា ៣**

១. ភាគីដែលផ្តើមបណ្តឹងមជ្ឈត្តការ (អំណើះតទៅហៅថា "ភាគីប្តឹង") ត្រូវផ្តល់ដល់ភាគីម្ខាងទៀត (អំណើះតទៅហៅថា "ភាគីឆ្លើយតប") នូវការជូនដំណឹងអំពីមជ្ឈត្តការ។

២. នីតិវិធីមជ្ឈត្តការត្រូវបានសន្មតថាចាប់ផ្តើមនៅថ្ងៃដែលភាគីឆ្លើយតបទទួលបានការជូនដំណឹង អំពីមជ្ឈត្តការនោះ។

៣. ការជូនដំណឹងអំពីមជ្ឈត្តការត្រូវរួមបញ្ចូលនូវៈ

(ក) ការទាមទារឱ្យមានការដោះស្រាយវិវាទដោយវិធានមជ្ឈត្តការ

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់ភាគីទាំងអស់

(គ) សំណៅយោងលើខសន្យាមជ្ឈត្តការ ឬលើកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែកណាមួយដែលត្រូវយកមកអនុវត្ត។

(ឃ) សំណៅយោងលើកិច្ចសន្យាដែលបង្ករ ឬទាក់ទងនឹងវិវាទនោះ ។

(ង) ចរិតទូទៅនៃការទាមទារ និងការលើកឡើងអំពីចំនួនទឹកប្រាក់ដែលពាក់ព័ន្ធ ប្រសិនបើមាន

(ច) ការអនុគ្រោះ ឬដំណោះស្រាយដែលចង់បាន

(ឆ) សម្តីអំពីចំនួនអាជ្ញាកណ្តាល ( មួយ ឬ បី) ប្រសិនបើភាគីទាំងអស់មិនបានព្រមព្រៀងពីមុនមកទេ។

៤. ការជូនដំណឹងអំពីមជ្ឈត្តការអាចរួមបញ្ចូលផងដែរនូវៈ

(ក) សម្ចើដើម្បីឱ្យមានការតែងតាំងមជ្ឈត្តករតែមួយរូបណាមួយ និងអាជ្ញាធរតែងតាំងមួយ ដូចមានរៀបរាប់ក្នុងមាត្រា ៦ កថាខ័ណ្ឌ ១។

(ខ) ការជូនដំណឹងអំពីការតែងតាំងមជ្ឈត្តករដូចមានចែងក្នុងមាត្រា ៧។

(គ) បណ្តឹងទាមទារដូចមានចែងក្នុងមាត្រា ១៨។

**តំណាង និងជំនួយ**

**មាត្រា ៤**

ភាគីទាំងអស់អាចជ្រើសរើសអ្នកតំណាង ឬអ្នកផ្តល់ជំនួយដោយខ្លួនឯង។ ឈ្មោះ និង អសយដ្ឋានរបស់បុគ្គលទាំងនោះ ត្រូវតែបានឆ្លើយឆ្លងជាលាយលក្ខអក្សរទៅកាន់ភាគីម្ខាងទៀត ដោយត្រូវបញ្ជាក់ថាការតែងតាំងនោះធ្វើឡើងក្នុងគោលបំណងសម្រាប់ធ្វើជាតំណាង ឬក៏សម្រាប់ផ្តល់ជំនួយ។

## ផ្នែកទី II: សមាសភាពនៃគណៈមជ្ឈត្តកម្ម

**ចំនួនមជ្ឈត្តករ**

**មាត្រា ៥**

ប្រសិនបើភាគីទាំងអស់មិនទាន់បានព្រមព្រៀងពីមុនមកអំពីចំនួនមជ្ឈត្តករ (មួយរូប ឬបីរូប) ហើយប្រសិនបើក្នុងរយៈពេលដប់ប្រាំថ្ងៃបន្ទាប់ពីភាគីឆ្លើយតប បានទទួលការជូនដំណឹងអំពីមជ្ឈត្តការរួច ភាគីវិវាទនៅតែមិនទាន់ព្រមព្រៀងថាត្រូវមានមជ្ឈត្តករតែមួយរូបទេនោះ គេត្រូវតែងតាំងមជ្ឈត្តករចំនួនបីរូប។

**ការតែងតាំងមជ្ឈត្តករ ( មាត្រា៦ ដល់៨)**

**មាត្រា ៦**

១. ប្រសិនបើត្រូវតែងតាំងមជ្ឈត្តករតែមួយរូប ភាគីម្ខាងអាចស្នើទៅភាគីម្ខាងទៀតនូវៈ

(ក) ឈ្មោះរូបវ័ន្តបុគ្គលមួយ ឬច្រើន ដែលម្នាក់ក្នុងចំណោមនោះនឹងត្រូវធ្វើការជាមជ្ឈត្តករតែមួយរូប ព្រមទាំង

(ខ) ឈ្មោះរូបវ័ន្តបុគ្គល ឬនីតិបុគ្គលមួយឬច្រើន ដែលមួយក្នុងចំណោមនោះនឹងត្រូវធ្វើជាអាជ្ញាធរតែងតាំង បើភាគីវិវាទមិនទាន់បានឯកភាពគ្នាលើអាជ្ញាធរតែងតាំងណាមួយនោះទេ។

២. ប្រសិនបើក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីភាគីម្ខាងបានទទួលសម្ចើណាមួយ ដែលបានធ្វើឡើងដូចក្នុងកថាខ័ណ្ឌ១ ភាគីវិវាទមិនទាន់បានព្រមព្រៀងគ្នាលើការជ្រើសរើសមជ្ឈត្តករតែមួយរូបណាមួយនោះទេ មជ្ឈត្តករមួយរូបនោះត្រូវតែងតាំងឡើងដោយអាជ្ញាធរតែងតាំង ដែលមានការព្រមព្រៀងពីភាគីវិវាទ។ ប្រសិនបើ ពុំមានអាជ្ញាធរតែងតាំងណាមួយត្រូវបានព្រមព្រៀងដោយភាគីវិវាទ ឬប្រសិនបើ

អាជ្ញាធរតែងតាំងដែលមានការព្រមព្រៀងរបស់ភាគីវិវាទ បដិសេធ ឬខកខានមិនបានតែងតាំងមជ្ឈត្តករ ក្នុងរយៈពេលហុកសិបថ្ងៃ បន្ទាប់ពីទទួលបានសម្នើរបស់ភាគីវិវាទរួច ភាគីវិវាទណាមួយក៏បានអាចស្នើ ទៅអគ្គលេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តការនាទីក្រុងឡាអេ ឱ្យជ្រើសតាំងអាជ្ញាធរតែង តាំងមួយឡើង។

៣. នៅពេលមានសម្នើរបស់ភាគីវិវាទ អាជ្ញាធរតែងតាំងត្រូវតែងតាំងមជ្ឈត្តករតែមួយរូបណាមួយ យ៉ាងរហ័សបំផុតតាមដែលអាចធ្វើបាន។ ដើម្បីធ្វើការតែងតាំង អាជ្ញាធរតែងតាំងត្រូវប្រើនីតិវិធីតាម បញ្ជីឈ្មោះ ដូចរៀបរាប់ខាងក្រោម លើកលែងតែថាភាគីវិវាទឯកភាពថានីតិវិធីតាមបញ្ជីឈ្មោះនេះ មិនគួរលើកយកមកប្រើ ឬក៏ថាអាជ្ញាធរតែងតាំងសម្រេចដោយឆន្ទានុសិទ្ធិរបស់ខ្លួនថា ការប្រើប្រាស់ នីតិវិធីតាមបញ្ជីឈ្មោះនេះមិនមានលក្ខណៈសមស្របចំពោះរឿងក្តីនោះ

(ក) យោងតាមសម្នើសុំរបស់ភាគីណាមួយ អាជ្ញាធរតែងតាំងនឹងបញ្ជូនទៅភាគីវិវាទនូវបញ្ជី ឈ្មោះដូចគ្នា ដែលក្នុងនោះមានឈ្មោះយ៉ាងតិចចំនួនបី

(ខ) ក្នុងកំឡុងពេលដប់ប្រាំថ្ងៃបន្ទាប់ពីទទួលបាននូវបញ្ជីឈ្មោះរួច ភាគីនិមួយៗអាចបញ្ជូនបញ្ជី នោះត្រលប់មកអជ្ញាធរតែងតាំងវិញ បន្ទាប់ពីលុបឈ្មោះមួយ ឬច្រើនដែលខ្លួនជំទាស់ ហើយ រៀបឈ្មោះដែលនៅសេសសល់ក្នុងបញ្ជីតាមលំដាប់នៃការពេញចិត្តរបស់ខ្លួន

(គ) ក្រោយពេលដែលផុតរវេលាខាងលើផុតកំណត់ អាជ្ញាធរតែងតាំងនឹងតែងតាំងមជ្ឈត្តករមួយ រូបចេញពីឈ្មោះទាំងអស់ដែលគូរភាគីបានសម្រេចនៅក្នុងបញ្ជីដែលបានបញ្ជូនត្រលប់មកវិញ និង ស្របតាមលំដាប់នៃជំរើសរបស់ភាគីវិវាទ។

(ឃ) បើសិនដោយហេតុផលណាមួយ ការជ្រើសតាំងមិនអាចធ្វើឡើងទៅបានស្របនឹង នីតិវិធី នេះទេ អាជ្ញាធរតែងតាំងអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីតែងតាំងមជ្ឈត្តករតែមួយរូបនោះបាន។

៤. នៅក្នុងកិច្ចការតែងតាំង អាជ្ញាធរតែងតាំងត្រូវផ្អែកលើការពិចារណាជាច្រើនដើម្បីធានាឱ្យបាននូវ ការតែងតាំងមជ្ឈត្តករមួយរូបដែលឯករាជ្យ និងមិនលម្អៀង ហើយត្រូវពិចារណាផងដែរអំពីលទ្ធភាព ក្នុងការតែងតាំងមជ្ឈត្តករមួយរូបដែលមានសញ្ជាតិមួយផ្សេងពីសញ្ជាតិរបស់ភាគីវិវាទតាមការគួរ។

**មាត្រា ៧**

១. ប្រសិនបើត្រូវតែងតាំងមជ្ឈត្តករបីរូប ភាគីវិវាទទាំងសង្ខាងត្រូវតែងតាំងមជ្ឈត្តករមួយរូបរៀងខ្លួន។ មជ្ឈត្តករទាំងពីររូបត្រូវជ្រើសរើសមជ្ឈត្តករទីបីដែលនឹងក្លាយជាមជ្ឈត្តករអធិបតីនៃវេទិកា។

២. ប្រសិនបើក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងរបស់ភាគីម្ខាងអំពីការតែងតាំងមជ្ឈត្តករមួយរូបរួចមក ភាគីម្ខាងទៀតនៅមិនទាន់បានជូនដំណឹងដល់ភាគីទីមួយអំពីមជ្ឈត្តករដែលខ្លួនបានតែងតាំងទេនោះ:

(ក) ភាគីទីមួយអាចស្នើទៅអាជ្ញាធរតែងតាំងដែលភាគីទាំងពីរបានជ្រើសតាំងពីមុនមក ឱ្យតែងតាំង មជ្ឈត្តករទី២ ឬ

(ខ) ប្រសិនបើពុំមានអាជ្ញាធរតែងតាំងដែលភាគីវិវាទបានជ្រើសតាំងពីមុនទេ ឬបើសិនអាជ្ញាធរតែងតាំងដែលត្រូវបានជ្រើសតាំងនោះជំទាស់ ឬខកខានមិនបានតែងតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីទទួលបានសម្នើរបស់ភាគីណាមួយនោះ ភាគីទីមួយអាចស្នើអគ្គលេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តការនាទីក្រុងឡាអេ ឱ្យជ្រើសតាំងអាជ្ញាធរតែងតាំងមួយ។ បន្ទាប់មកភាគីទីមួយអាចស្នើអាជ្ញាធរតែងតាំងដែលបានជ្រើសតាំងឡើងនោះ ឱ្យតែងតាំងមជ្ឈត្តករទីពីរ។ ក្នុងករណីទាំងពីរអាជ្ញាធរតែងតាំងអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការតែងតាំងមជ្ឈត្តករនោះ។

៣. ប្រសិនបើក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីមានការតែងតាំងមជ្ឈត្តករទីពីររួចមក មជ្ឈត្តករទាំងពីរមិនទាន់បានព្រមព្រៀងលើការជ្រើសរើសមជ្ឈត្តករមួយរូបទៀតជាអធិបតីនោះ អាជ្ញាធរតែងតាំងនឹងតែងតាំងមជ្ឈត្តករអធិបតីតាមវិធានដូចគ្នានឹងការតែងតាំងមជ្ឈត្តករតែមួយរូបក្នុងមាត្រា៦ ដែរ។

**មាត្រា ៨**

១. នៅពេលដែលអាជ្ញាធរតែងតាំងត្រូវបានស្នើឱ្យតែងតាំងមជ្ឈត្តករ ដូចដែលមានចែងក្នុងមាត្រា៦ ឬ៧ ភាគីដែលធ្វើសម្នើត្រូវធ្វើច្បាប់ចម្លងនៃការជូនដំណឹងអំពីមជ្ឈត្តការមួយច្បាប់ កិច្ចសន្យាដែលបង្ករ ឬជាប់ពាក់ព័ន្ធនឹងវិវាទមួយច្បាប់ ព្រមទាំងកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការមួយច្បាប់ ប្រសិនបើមិនមានចែងនៅក្នុងកិច្ចសន្យានោះទេ។ អាជ្ញាធរតែងតាំងអាចតម្រូវឱ្យភាគីមួយផ្តល់ព័ត៌មានទាំងនេះ នៅពេលដែលយល់ឃើញថា វាជាការចាំបាច់ក្នុងការបំពេញតួនាទីរបស់ខ្លួន។

២. ការស្នើឈ្មោះរូបវ័ន្តបុគ្គលម្នាក់ ឬច្រើននាក់ដើម្បីតែងតាំងជាមជ្ឈត្តករត្រូវធ្វើឡើងដោយមានបញ្ជាក់នូវឈ្មោះពេញ អសយដ្ឋាន និងសញ្ជាតិ ព្រមជាមួយនឹងការពណ៌នាអំពីគុណសម្បត្តិនៃបុគ្គលទាំងនោះ។

**ការជំទាស់នឹងមជ្ឈត្តករ ( មាត្រា៩ ដល់១២)**

**មាត្រា ៩**

១. មជ្ឈត្តករដែលគេរំពឹងទុក ត្រូវបង្ហាញដល់អ្នកដែលពឹងពាក់ទាំងអស់នូវកាលៈទេសៈទាំងឡាយណាដែលពាក់ព័ន្ធនឹងលទ្ធភាពតែងតាំងខ្លួន និងដែលអាចនាំឱ្យកើតមានសេចក្តីមន្ទិលសង្ស័យនានា ចំពោះ

អនាគតិ ឬឯករាជ្យភាពរបស់ខ្លួន។ បន្ទាប់ពីត្រូវបានតែងតាំង ឬជ្រើសរើសរួចមក មជ្ឈត្តករត្រូវបង្ហាញពីកាលៈទេសៈទាំងនេះទៅកាន់ភាគីវិវាទ វារលែងតែភាគីវិវាទបានទទួលនូវព័ត៌មានទាំងនេះរួចហើយ។

**មាត្រា ១០**

១. គេអាចជំទាស់មជ្ឈត្តករណាមួយ ប្រសិនបើមានកាលៈទេសៈទាំងឡាយណាដែលនាំឱ្យកើតមានមន្ទិលសមស្របផ្សេងៗចំពោះអនាគតិ ឬឯករាជ្យភាពនៃមជ្ឈត្តករនោះ។

២. ភាគីម្ខាងអាចជំទាស់ចំពោះមជ្ឈត្តករដែលខ្លួនបានតែងតាំងបាន ក្នុងករណីដែលខ្លួនទើបតែបានដឹងអំពីមូលហេតុ បន្ទាប់ពីធ្វើការតែងតាំងរួចប៉ុណ្ណោះ។

**មាត្រា ១១**

១. ភាគីដែលមានបំណងជំទាស់នឹងមជ្ឈត្តករណាម្នាក់ ត្រូវធ្វើលិខិតជូនដំណឹងអំពីការជំទាស់របស់ខ្លួនក្នុងអំឡុងពេលដប់ប្រាំថ្ងៃ ក្រោយពេលដែលភាគីនោះទទួលបានដំណឹងអំពីការតែងតាំងមជ្ឈត្តករដែលត្រូវជំទាស់នោះ ឬក្នុងរយៈពេលដប់ប្រាំថ្ងៃបន្ទាប់ពីភាគីនោះដឹងពីកាលៈទេសៈផ្សេងៗដូចមានចែងក្នុងមាត្រា៩ និង មាត្រា១០។

២. ការជំទាស់ត្រូវតែមានជូនជាដំណឹងដល់ភាគីម្ខាងទៀត ដល់មជ្ឈត្តករដែលត្រូវជំទាស់ និងដល់សមាជិកដទៃទៀតនៃវេទិកាមជ្ឈត្តកម្ម។ ការជូនដំណឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានបញ្ជាក់ពីហេតុផលនៃការជំទាស់នោះផង ។

៣. នៅពេលដែលមជ្ឈត្តករមួយរូបត្រូវបានជំទាស់ដោយភាគីម្ខាង ភាគីម្ខាងទៀតអាចយល់ស្របនឹងការជំទាស់នោះបាន។ រីឯមជ្ឈត្តករនោះផ្ទាល់ក៏អាចធ្វើការដកខ្លួនបានដែរ បន្ទាប់ពីមានការជំទាស់។ ករណីខាងលើ ពុំត្រូវបញ្ជាក់ពីសុពលភាពនៃកត្តាសម្អាងសម្រាប់ការជំទាស់នោះឡើយ។ បើមានករណីទាំងពីរនេះ គេអាចលើកយកមកប្រើប្រាស់បានយ៉ាងពេញលេញនូវនីតិវិធីដូចមានចែងក្នុង មាត្រា៦ ឬមាត្រា៧ ក្នុងការតែងតាំងមជ្ឈត្តករជំនួស ទោះបីក្នុងដំណើរការតែងតាំងមជ្ឈត្តករដែលត្រូវបានជំទាស់នោះ ភាគីម្ខាងមិនបានប្រើសិទ្ធិរបស់ខ្លួនក្នុងការតែងតាំង ឬចូលរួមតែងតាំងក៏ដោយ។

**មាត្រា ១២**

១. ប្រសិនបើភាគីម្ខាងទៀតមិនយល់ស្របនឹងការជំទាស់ ហើយមជ្ឈត្តករដែលត្រូវបានជំទាស់នោះមិនបានដកខ្លួនទេនោះ សេចក្តីសម្រេចលើការជំទាស់នោះនឹងត្រូវធ្វើឡើងដោយ:

(ក) ក្នុងករណីដែលការតែងតាំងដំបូងធ្វើឡើងដោយអាជ្ញាធរតែងតាំងមួយ អាជ្ញាធរនោះជាអ្នកសម្រេច។

(ខ) ក្នុងករណីដែលការតែងតាំងដំបូងមិនបានធ្វើឡើងដោយអាជ្ញាធរតែងតាំងមួយទេ ប៉ុន្តែមានអជ្ញាធរតែងតាំងមួយត្រូវបានជ្រើសតាំងពីមុនមក អាជ្ញាធរនោះជាអ្នកសម្រេច។

(គ) នៅរាល់ករណីដទៃទៀត ត្រូវសម្រេចដោយអាជ្ញាធរតែងតាំង ដែលគេត្រូវជ្រើសតាំងឡើងស្របតាមនីតិវិធីក្នុងការជ្រើសតាំងអាជ្ញាធរតែងតាំងដូចមានចែងក្នុងមាត្រា ៦។

២. ប្រសិនបើអាជ្ញាធរតែងតាំងរក្សាការជំទាស់នោះ មជ្ឈត្តករជំនួសមួយរូបនឹងត្រូវបានតែងតាំង ឬជ្រើសរើស ឱ្យស្របតាមនីតិវិធីសម្រាប់អនុវត្តក្នុងតំណែងតាំង ឬជម្រើសមជ្ឈត្តករ ដូចមានចែងពីមាត្រា ៦ ដល់មាត្រា៩ លើកលែងតែពេលដែលនីតិវិធីនេះតម្រូវឱ្យមានការជ្រើសតាំងនូវអាជ្ញាធរតែងតាំងណាមួយ ការតែងតាំងមជ្ឈត្តករត្រូវធ្វើឡើងដោយអាជ្ញាធរតែងតាំងដែលបានសម្រេចលើការជំទាស់នោះ។

**ការផ្លាស់ប្តូរមជ្ឈត្តករ**

**មាត្រា ១៣**

១. នៅក្នុងករណីដែលមជ្ឈត្តករបាត់បង់ជីវិត ឬលាលែងពីការងាររបស់ខ្លួន ក្នុងកំឡុងពេលដំណើរការនីតិវិធីមជ្ឈតការ មជ្ឈត្តករជំនួសមួយរូបនឹងត្រូវបានតែងតាំង ឬជ្រើសរើសស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា៦ ដល់៩ ដូចដែលបានអនុវត្តចំពោះការតែងតាំង ឬជ្រើសរើសមជ្ឈត្តករដែលគេជំនួសនោះ។

២. ក្នុងករណីដែលមជ្ឈត្តករខកខានមិនបានធ្វើកិច្ចការ ឬពុំមានលទ្ធភាពក្នុងការបំពេញមុខងាររបស់ខ្លួនដោយ*ហេតុផលច្បាប់* ឬ*ហេតុផលជាក់ស្តែង*ណាមួយ នីតិវិធីទាក់ទងនឹងការជំទាស់ និងការផ្លាស់ប្តូរមជ្ឈត្តករដូចមាន ចែងនៅក្នុងមាត្រាទាំងឡាយស្តីពីដំណើរការនេះនឹងត្រូវលើកយកមកប្រើប្រាស់។

**ការធ្វើសវនាការឡើងវិញក្នុងករណីមានការផ្លាស់ប្តូរមជ្ឈត្តករ**

**មាត្រា ១៤**

ប្រសិនបើមជ្ឈត្តករតែមួយរូប ឬមជ្ឈត្តករអធិបតីណាមួយត្រូវបានផ្លាស់ប្តូរ តាមមាត្រា១១ ដល់មាត្រា ១៣ សវនាការទាំងឡាយណាដែលធ្វើឡើងពីមុនមកនឹងត្រូវធ្វើឡើងសារជាថ្មី ហើយប្រសិនបើមានមជ្ឈត្តករផ្សេងទៀត ត្រូវបានប្តូរដែរនោះ សវនាការពីមុនដទៃទៀតអាចធ្វើឡើងជាថ្មីបានក្រោមឆន្ទានុសិទ្ធិ នៃវេទិកាមជ្ឈត្តកម្មទាំងមូល។

## ផ្នែកទី III - នីតិវិធីមជ្ឈត្តការ

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១៥**

១. ដោយអនុលោមតាមបទប្បញ្ញត្តិនេះ វេទិកាមជ្ឈត្តកម្មអាចធ្វើមជ្ឈត្តការតាមរបៀបដែលខ្លួនយល់ឃើញថាសមស្រប ដោយត្រូវមានការប្រព្រឹត្តចំពោះភាគីវិវាទប្រកបដោយសមភាព ហើយទោះជាស្ថិត

ក្នុងដំណាក់កាលណាមួយនៃដំណើរការក៏ដោយ ត្រូវផ្ដល់ឱកាសយ៉ាងពេញលេញដល់ភាគីនីមួយៗ ក្នុងការបង្ហាញរឿងហេតុរបស់ខ្លួន។

២. ប្រសិនបើមានការស្នើសុំដូច្នោះពីភាគីណាមួយ នៅក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មត្រូវផ្អាកសវនាការរបស់ខ្លួន ដើម្បីផ្ដល់លទ្ធភាពឱ្យសាក្សីទាំងអស់ រួមទាំងសាក្សីជំនាញផង ធ្វើការបង្ហាញភស្តុតាង ឬទឡ្ហីករណ៍ផ្ទាល់មាត់។ ប្រសិនបើគ្មានសំណើបែបនោះទេ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថាតើត្រូវផ្អាកដំណើរការមជ្ឈត្តការ ឬគួរបន្តដំណើរការនោះឬទេ ដោយផ្អែកលើមូលដ្ឋានឯកសារ និងសំណៅដទៃទៀត។

៣. ឯកសារ ឬព័ត៌មានទាំងអស់ដែលភាគីម្ខាងផ្ដល់ដល់វេទិកាមជ្ឈត្តកម្ម ត្រូវតែបញ្ជូនព្រមគ្នាទៅកាន់ភាគីម្ខាងទៀតផងដែរ ដោយភាគីនោះ។

**ទីកន្លែងធ្វើមជ្ឈត្តការ**

**មាត្រា ១៦**

១. លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាអំពីទីកន្លែងដែលមជ្ឈត្តការនឹងប្រព្រឹត្តទៅ ទីកន្លែងធ្វើមជ្ឈត្តការត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម ដោយផ្អែកទៅលើកាលៈទេសៈផ្សេងៗនៃមជ្ឈត្តការនោះ។

២. វេទិកាមជ្ឈត្តកម្មអាចកំណត់កន្លែងប្រព្រឹត្តទៅនៃមជ្ឈត្តការ នៅក្នុងប្រទេសដែលភាគីវិវាទបានព្រមព្រៀង។ វេទិកាមជ្ឈត្តកម្មក៏អាចសវនៈសាក្សី និងរៀបចំកិច្ចប្រជុំនានាដើម្បីឱ្យសមាជិករបស់ខ្លួនបានប្រឹក្សាយោបល់គ្នានៅទីកន្លែងណាក៏ដោយដែលខ្លួនយល់ថាសមស្រប យោងតាមកាលៈទេសៈផ្សេងៗនៃមជ្ឈត្តការនោះ។

៣. វេទិកាមជ្ឈត្តកម្មអាចជួបប្រជុំនៅទីកន្លែងណាក៏ដោយដែលខ្លួនយល់ថាសមស្រប ដើម្បីត្រួតពិនិត្យលើទំនិញ ទ្រព្យសម្បត្តិ ឬឯកសារដទៃទៀត។ ភាគីវិវាទត្រូវទទួលបានការជូនដំណឹងគ្រប់គ្រាន់ដើម្បីជួយសំរួលឱ្យពួកគេអាចមានវត្តមាននៅពេលធ្វើការត្រួតពិនិត្យនោះ។

៤. ការផ្ដល់មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើនៅទីកន្លែងធ្វើមជ្ឈត្តការ។

**ភាសា**

**មាត្រា ១៧**

១. បន្ទាប់ពីត្រូវបានតែងតាំងភ្លាម វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកភាសាណាមួយ ឬភាសាណាខ្លះសម្រាប់ប្រើប្រាស់នៅក្នុងដំណើរការមជ្ឈត្តការ ដោយមានការព្រមព្រៀងពីភាគីវិវាទផង។ ការកំណត់នេះនឹងត្រូវលើកយកមកអនុវត្តនៅក្នុងបណ្ដឹងទាមទារ បណ្ដឹងដោះសារ និងបណ្ដឹងបន្ថែមជាលាយ

លក្ខណ៍អក្សរដទៃទៀត ព្រមទាំងភាសាមួយ ឬច្រើន ដែលត្រូវយកមកប្រើក្នុងសវនាការផ្ទាល់មាត់នានា ប្រសិនបើសវនាការទាំងនោះត្រូវប្រព្រឹត្តឡើង។

២. វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែជាភាសាមួយ ឬច្រើន ដែលបានព្រមព្រៀងដោយភាគីវិវាទ ឬដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្មនោះ អមជាមួយឯកសារជាភាសាដើមទាំងឡាយណាដែលភ្ជាប់នឹងបណ្តឹងទាមទារ ឬបណ្តឹងដោះសារ ព្រមទាំងឯកសារ ឬសំណៅតាំងបង្ហាញផ្សេងៗដែលបានដាក់ឱ្យត្រួតពិនិត្យក្នុងកំឡុងពេលដំណើរការមជ្ឈត្តការ។

**បណ្តឹងទាមទារ**

**មាត្រា ១៨**

១. ក្នុងថេរៈវេលាមួយដែលត្រូវបានកំណត់ដោយវេទិការពាណិជ្ជកម្ម ភាគីប្តឹងត្រូវផ្ញើបណ្តឹងទាមទាររបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅកាន់ភាគីឆ្លើយតប និងទៅកាន់មជ្ឈត្តករនីមួយៗ លើកលែងតែបណ្តឹងទាមទារនោះមានបញ្ចូលនៅក្នុងការជូនដំណឹងអំពីមជ្ឈត្តការរួចទៅហើយ។ ភាគីត្រូវភ្ជាប់មកជាមួយផងដែរ នូវខ្លឹមសារចម្លងនៃកិច្ចសន្យា ព្រមទាំងកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ ប្រសិនបើមិនមានចែងនៅក្នុងកិច្ចសន្យានោះទេ។

២. បណ្តឹងទាមទារត្រូវរួមបញ្ចូលចំណុចលម្អិតដូចខាងក្រោមៈ

(ក) ឈ្មោះ និងអសយដ្ឋាននៃភាគីវិវាទទាំងអស់

(ខ) សេចក្តីថ្លែងអង្គហេតុដែលគាំទ្រដល់ការទាមទារនោះ

(គ) ចំណុចទាំងឡាយដែលចោទជាបញ្ហា

(ឃ) ការអនុគ្រោះ ឬសំនងដែលចង់បាន

ភាគីប្តឹងអាចភ្ជាប់ជាមួយបណ្តឹងទាមទាររបស់ខ្លួន នូវឯកសារទាំងអស់ដែលខ្លួនយល់ថាមានជាប់ពាក់ព័ន្ធ ឬ បន្ថែមឯកសារយោងលើឯកសារ ឬភស្តុតាងដទៃទៀតដែលខ្លួននឹងដាក់ឱ្យត្រួតពិនិត្យ។

**បណ្តឹងដោះសារ**

**មាត្រា ១៩**

១. ក្នុងថេរៈវេលាមួយដែលត្រូវបានកំណត់ឡើងដោយវេទិកាមជ្ឈត្តកម្ម ភាគីឆ្លើយតបត្រូវផ្ញើបណ្តឹងដោះសាររបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅភាគីប្តឹង និងមជ្ឈត្តករគ្រប់រូប។

២. បណ្តឹងដោះសារត្រូវឆ្លើយតបទៅនឹងចំនុចលម្អិត (ខ)(គ) និង (ឃ) នៃបណ្តឹងទាមទារ (មាត្រា ១៨ កថាខ័ណ្ឌ ២)។ ភាគីឆ្លើយតបអាចភ្ជាប់ជាមួយបណ្តឹងរបស់ខ្លួន នូវឯកសារដែលខ្លួនប្រើជាបង្អែកដើម្បីដោះសារ ឬអាចបន្ថែមសំណៅយោងលើឯកសារ ឬភស្តុតាងដទៃទៀតដែលខ្លួនដាក់ឱ្យពិនិត្យ។

៣. ភាគីឆ្លើយតបអាចធ្វើបណ្ដឹងទាស់ចេញពីកិច្ចសន្យាដដែល ឬផ្អែកលើបណ្ដឹងថ្មីមួយចេញពីកិច្ចសន្យាដដែលនោះដើម្បីទាមទារការទូទាត់ នៅក្នុងបណ្ដឹងដោះសាររបស់ខ្លួន ឬនៅដំណាក់កាលក្រោយមកទៀត នៃដំណើរការមជ្ឍត្តការ ប្រសិនបើវេទិកាមជ្ឍត្តកម្មសម្រេចថាការពន្យារនោះមានលក្ខណៈសមស្របតាមកាលៈទេសៈ ។

៤. ប្បញ្ញត្តិក្នុងមាត្រា១៨ កថាខ័ណ្ឌ២ នឹងត្រូវយកមកប្រើលើបណ្ដឹងទាស់ និងបណ្ដឹងដែលគេធ្វើជាបង្អែកដើម្បីទាមទារការទូទាត់ ។

**ការកែប្រែបណ្ដឹងទាមទារ ឬបណ្ដឹងដោះសារ**

**មាត្រា ២០**

ក្នុងពេលដំណើរការមជ្ឍត្តការ ភាគីណាក៏អាចកែប្រែ ឬបំពេញលើបណ្ដឹងទាមទារ ឬដោះសាររបស់ខ្លួនបានដែរ លើកលែងតែថាវេទិកាមជ្ឍត្តកម្មចាត់ទុកថាការអនុញ្ញាតិឱ្យមានកំណែរប្រែនោះ ជាការមិនគប្បីដោយពិចារណាទៅលើការអូសបន្លាយពេលដើម្បីធ្វើកំណែរប្រែនោះ ឬការលម្អៀងចំពោះភាគីម្ខាងទៀត ឬដោយសារកាលៈទេសៈដទៃទៀត ។ យ៉ាងណាមិញគេមិនអាចកែប្រែបណ្ដឹងមួយបានឡើយ បើសិនជាបណ្ដឹងដែលបានកែប្រែនោះ ហួសពីដែនកំណត់នៃឃ្លាមជ្ឍត្តការ ឬកិច្ចព្រមព្រៀងដោយឡែកស្ដីពីមជ្ឍត្តការដែលមាន ។

**ការជំទាស់ទាក់ទ័ងនឹងសមត្ថកិច្ចរបស់វេទិកាមជ្ឍត្តកម្ម**

**មាត្រា ២១**

១.វេទិកាមជ្ឍត្តកម្មត្រូវមានអំណាចសម្រេចលើការជំទាស់ផ្សេងៗដែលថា ខ្លួនមិនមានសមត្ថកិច្ចដោះ-ស្រាយ រួមទាំងការជំទាស់ពាក់ព័ន្ធនឹងអត្ថិភាព ឬសុពលភាពនៃឃ្លាមជ្ឍត្តការ ឬកិច្ចព្រមព្រៀងដោយឡែកស្ដីពីមជ្ឍត្តការ ផងដែរ ។

២. វេទិកាមជ្ឍត្តកម្មត្រូវមានសិទ្ធិសម្រេចលើអត្ថិភាព ឬសុពលភាពនៃកិច្ចសន្យាដែលក្នុងនោះមានឃ្លាមជ្ឍត្តការជាផ្នែកមួយផងដែរ ។ សម្រាប់មាត្រា២១នេះ ឃ្លាមជ្ឍត្តការដែលជាផ្នែកនៃកិច្ចសន្យាណាមួយ ហើយដែលកំណត់ពីមជ្ឍត្តការស្របតាមវិធាននេះ ត្រូវចាត់ទុកជាកិច្ចព្រមព្រៀងឯករាជ្យពីលក្ខខ័ណ្ឌដទៃ ទៀតនៃកិច្ចសន្យានោះ ។ សេចក្ដីសម្រេចរបស់វេទិកាមជ្ឍត្តកម្មដែលចាត់ទុកកិច្ចសន្យានោះជាមោឃៈ នឹងមិនបណ្ដាលឱ្យឃ្លាមជ្ឍត្តការនោះមានមោឃភាពតាមវិធានច្បាប់ឡើយ ។

៣. ទឡ្ហីករណ៍ណាមួយដែលថាវេទិកាមជ្ឍត្តកម្មពុំមានសមត្ថកិច្ចដោះស្រាយនោះ មិនត្រូវធ្វើក្រោយពេលធ្វើបណ្ដឹងដោះសារ ឬបណ្ដឹងតបទៅនឹងបណ្ដឹងទាស់ណាមួយ ក្នុងករណីដែលមានបណ្ដឹងទាស់នោះឡើយ ។

៤. ជាទូទៅ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួនជាមុនសិន។ យ៉ាងណាមិញ វេទិកាមជ្ឈត្តកម្មក៏អាចបន្តដំណើរការកិច្ចការមជ្ឈត្តការ ហើយសឹមសម្រេចលើការជំទាស់នោះ នៅក្នុងមជ្ឈត្តវិនិច្ឆ័យស្ថាពររបស់ខ្លួន ក៏បានដែរ។

**បណ្ដឹងលាយលក្ខណ៍អក្សរបន្ថែមដទៃទៀត**

**មាត្រា ២២**

វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា ក្រៅពីបណ្ដឹងទាមទារ និងបណ្ដឹងដោះសារ មានបណ្ដឹងលាយលក្ខណ៍អក្សរបន្ថែមណាខ្លះទៀត ដែលខ្លួនត្រូវការ ឬដែលភាគីវិវាទអាចយកមកបង្ហាញបាន ហើយត្រូវកំណត់ថេរៈវេលាដើម្បីបញ្ជូនបណ្ដឹងទាំងនោះមកផង។

**ថេរៈវេលាផ្សេងៗ**

**មាត្រា ២៣**

ពេលវេលាដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម សម្រាប់ការបញ្ជូនបណ្ដឹងលាយលក្ខណ៍អក្សរផ្សេងៗ (រួមទាំងបណ្ដឹងទាមទារ និងបណ្ដឹងដោះសារ) មិនត្រូវលើសពីសែសិបប្រាំថ្ងៃឡើយ។ យ៉ាងណាមិញ វេទិកាមជ្ឈត្តកម្ម អាចពន្យាពេលកំណត់នេះប្រសិនបើខ្លួនសន្និដ្ឋានថា ការពន្យានោះមានភាពសមស្រប។

**ភស្តុតាង និងសវនាការ ( មាត្រា២៤ និង២៥)**

**មាត្រា ២៤**

១. ភាគីនិមួយៗត្រូវទទួលបន្ទុកបង្ហាញអង្គហេតុដែលប្រើដើម្បីគាំទ្រការទាមទារ ឬដោះសាររបស់ខ្លួន។

២. ប្រសិនបើខ្លួនយល់ថាសមស្រប វេទិកាមជ្ឈត្តកម្មអាចទាមទារឱ្យភាគីណាមួយផ្ដល់មកឱ្យខ្លួន និងភាគីម្ខាងទៀត នូវខ្លឹមសារសង្ខេបនៃឯកសារ និងភស្តុតាង ដទៃទៀតដែលភាគីនោះត្រៀមនឹងបង្ហាញជាការគាំទ្រដល់អង្គហេតុដែលចោទជាបញ្ហា ដូចមានរៀបរាប់នៅក្នុងបណ្ដឹងទាមទារ ឬបណ្ដឹងដោះសារនៅក្នុងរយៈពេលមួយដែលវេទិការមជ្ឈត្តកម្មនោះបានកំណត់។

៣. នៅខណៈពេលណាក៏ដោយក្នុងដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីទាំងអស់រៀបចំឯកសារ សំណៅតាំងបង្ហាញ ឬភស្តុតាងដទៃទៀតតាមថេរៈវេលាដែលខ្លួនកំណត់។

**មាត្រា ២៥**

១. ក្នុងករណីមានសវនាការផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្មត្រូវផ្ដល់ការជូនដំណឹងជាមុន ដល់ភាគីវិវាទអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងឱ្យបានសមល្មម។

២. បើមានសាក្សីនានាត្រូវចូលរួមសវនាការ ភាគីនិមួយៗត្រូវបញ្ជូនព័ត៌មានមកកាន់វេទិកាមជ្ឈត្តកម្ម និងភាគីម្ខាងទៀត យ៉ាងតិចដប់ប្រាំថ្ងៃមុនពេលសវនាការ ក្នុងនោះរួមមានឈ្មោះ និងអសយដ្ឋានរបស់

សាក្សីដែលខ្លួនត្រៀមយកមកបង្ហាញ កម្មវត្ថុ និងភាសាទាំងអស់ដែលសាក្សីទាំងនោះនឹងប្រើនៅក្នុងកសិណរបស់ខ្លួន ។

៣. វេទិកាមជ្ឈត្តកម្មត្រូវរៀបចំឱ្យមានការបកប្រែពាំនោលផ្ទាល់មាត់ដែលធ្វើឡើងក្នុងសវនាការ និងត្រូវឱ្យមានកំណត់ហេតុនៃសវនាការ ប្រសិនបើខ្លួនចាត់ថាទាំងពីរយ៉ាងនេះគឺជាការចាំបាច់ ផ្អែកលើកាលៈទេសៈនៃរឿងក្ដីនោះ ឬប្រសិនបើភាគីទាំងអស់បានព្រមព្រៀងលើចំនុចនេះ ហើយបានផ្ញើការព្រមព្រៀងនោះមកកាន់វេទិកាយ៉ាងតិចដប់ប្រាំថ្ងៃមុនពេលសវនាការ ។

៤. លើកលែងតែភាគីវិវាទព្រមព្រៀងផ្សេងពីនេះ សវនាការត្រូវធ្វើឡើងជាអសាធារណៈ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យសាក្សីម្នាក់ ឬច្រើននាក់ចាកចេញ ខណៈពេលសាក្សីដទៃទៀតផ្ដល់កសិណរបស់ខ្លួន ។ វេទិកាមជ្ឈត្តកម្មអាចកំណត់របៀបសាកសួរសាក្សីទាំងអស់ដោយសេរី ។

៥. គេក៏អាចយកមកបង្ហាញផងដែរនូវភស្តុតាងនៃកសិណសាក្សី ក្នុងទម្រង់ជាសេចក្ដីថ្លែងការណ៍លាយលក្ខណ៍អក្សរ ដែលមានហត្ថលេខារបស់សាក្សីទាំងនោះ ។

៦. វេទិកាមជ្ឈត្តកម្មត្រូវកំណត់លើ ភាពយកជាការបាន ភាពជាប់ពាក់ព័ន្ធ សម្ភារភាព ក៏ដូចជាទម្ងន់របស់ភស្តុតាងដែលបានផ្ដល់ឱ្យ ។

**វិធានការបណ្ដោះអាសន្នបើឡើការងារ**

**មាត្រា ២៦**

១. តាមការស្នើសុំពីភាគីវិវាទណាមួយ វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការបណ្ដោះអាសន្នផ្សេងៗដែលខ្លួនចាត់ថាការចាំបាច់យោងតាមកម្មវត្ថុនៃវិវាទ រួមទាំងវិធានការដើម្បីថែរក្សាទំនិញដែលបង្កើតបានជាកម្មវត្ថុនៃវិវាទ ដូចជាការបញ្ជាឱ្យតម្កល់ទំនិញទាំងនោះជាមួយតតិយជនណាម្នាក់ ឬឱ្យលក់ចេញនូវទំនិញដែលឆាប់ខូចជាដើម ។

២. វិធានការបណ្ដោះអាសន្នទាំងនេះ អាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យបណ្ដោះអាសន្ន ។ វេទិកាមជ្ឈត្តកម្មមានសិទ្ធិតម្រូវឱ្យមានប្រាតិភោគ សម្រាប់ធានាលើការចំណាយនៃវិធានការទាំងនេះ ។

៣. សម្ដីដែលភាគីណាមួយធ្វើទៅកាន់អាជ្ញាធរតុលាការ ដើម្បីសុំវិធានការបណ្ដោះអាសន្ន មិនត្រូវបានចាត់ទុកថាវិសមិតជាមួយកិច្ចព្រមព្រៀងមជ្ឈត្តការ ឬជាការបដិសេធចោលកិច្ចព្រមព្រៀងនោះទេ ។

**ជំនាញការ**

**មាត្រា ២៧**

១. វេទិកាមជ្ឈត្តកម្មអាចតែងតាំងជំនាញការមួយឬច្រើនរូប ដើម្បីរាយការណ៍មកខ្លួន ជាលាយលក្ខណ៍អក្សរ លើបញ្ហាលម្អិតមួយចំនួនដែលកំណត់ដោយវេទិកានោះ។ ច្បាប់ចម្លងនៃលក្ខខ័ណ្ឌការងាររបស់ជំនាញការដែលវេទិកាបានរៀបចំឡើង នឹងត្រូវផ្ញើទៅកាន់ភាគីវិវាទទាំងអស់។

២. ភាគីទាំងអស់ត្រូវផ្តល់ដល់ជំនាញការនូវព័ត៌មានពាក់ព័ន្ធ ឬរៀបចំ សម្រាប់ការត្រួតពិនិត្យរបស់ជំនាញការ នូវឯកសារ ឬទំនិញតាមការតម្រូវរបស់ជំនាញការនោះ។ វាលវិវាទរវាងភាគីណាមួយជាមួយជំនាញការ លើភាពជាប់ពាក់ព័ន្ធនៃព័ត៌មាន ឬផលិតកម្មដែលបានតម្រូវនោះ ត្រូវបញ្ជូនមកវេទិកាមជ្ឈត្តកម្មធ្វើការសម្រេច ។

៣. នៅពេលទទួលបានរបាយការណ៍របស់ជំនាញការ វេទិកាមជ្ឈត្តកម្មត្រូវផ្ញើច្បាប់ចម្លងនៃរបាយការណ៍នោះទៅកាន់ភាគីវិវាទ ដែលនឹងត្រូវបានផ្តល់ឱកាសឱ្យបង្ហាញពីទស្សនៈរបស់ខ្លួនជាលាយលក្ខណ៍អក្សរតបនឹងរបាយការណ៍នោះ។ ភាគីវិវាទមានសិទ្ធិត្រួតពិនិត្យមើលឯកសារទាំងឡាយណាដែលជំនាញការប្រើប្រាស់សំរាប់សរសេររបាយការណ៍របស់ខ្លួន ។

៤. តាមការស្នើសុំពីភាគីណាមួយ បន្ទាប់ពីបានបញ្ជូនរបាយការណ៍របស់ខ្លួនរួច អ្នកជំនាញការអាចចូលបំភ្លឺក្នុងសវនាការ ដែលក្នុងនោះភាគីវិវាទនឹងមានឱកាសចូលរួម និងចោទសួរអ្នកជំនាញការនោះ។ ក្នុងសវនាការនេះ ភាគីនិមួយៗអាចបង្ហាញសាក្សីជំនាញដើម្បីធ្វើកសិណលើចំនុចដែលជាបញ្ហាឡើង។ បទប្បញ្ញត្តិនៃមាត្រា ២៥ អាចយកមកអនុវត្តបានក្នុងនីតិវិធីនេះ។

**ការខកខាន**

**មាត្រា ២៨**

១. ប្រសិនបើ ក្នុងថេរៈវេលាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ភាគីប្តឹងមិនបានដាក់បណ្តឹងទាមទាររបស់ខ្លួន ដោយមិនបានបង្ហាញមូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មត្រូវចេញដីកាបង្គាប់ឱ្យបញ្ឈប់ដំណើរការមជ្ឈត្តការនោះ។ ប្រសិនបើ ក្នុងថេរៈវេលាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ភាគីឆ្លើយតបមិនបានធ្វើបណ្តឹងដោះសាររបស់ខ្លួន ដោយមិនបានបង្ហាញមូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មត្រូវចេញដីកាបង្គាប់ឱ្យបន្តដំណើរការមជ្ឈត្តការនោះតទៅទៀត។

២. ប្រសិនបើភាគីវិវាទមិនបានបង្ហាញខ្លួននៅសវនាការ ដោយមិនបានបង្ហាញ មូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការនោះបាន ។

៣. បន្ទាប់ពីបានទទួលការជូនដំណឹងតាមវិធាននេះរួច ប្រសិនបើ ក្រោយពីត្រូវបានកោះហៅឱ្យរៀបចំឯកសារជាភស្តុតាង ក្នុងថេរៈវេលាមួយដែលបានកំណត់ មានភាគីណាមួយមិនបានធ្វើតាម ដោយមិនបាន

បង្ហាញមូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មអាចធ្វើមជ្ឈត្តវិនិច្ឆ័យផ្អែកលើភស្តុតាងដែលមានចំពោះមុខនៅពេលនោះ ។

**ការបិទសវនាការ**

**មាត្រា ២៩**

១. វេទិកាមជ្ឈត្តកម្មអាចសួរទៅភាគីវិវាទ ប្រសិនបើពួកគេមានភស្តុតាងដទៃទៀតដែលត្រូវបង្ហាញ ឬសាក្សីដទៃទៀតដែលត្រូវសវនៈ ឬឯកសារដទៃទៀតដែលត្រូវដាក់ឱ្យត្រួតពិនិត្យ ប្រសិនបើពុំមានទេ វេទិការមជ្ឈត្តកម្មអាចប្រកាសបិទសវនាការបាន ។

២. ក្នុងកាលៈទេសៈពិសេសដែលខ្លួនយល់ឃើញថាមានការចាំបាច់ វេទិកាមជ្ឈត្តកម្មអាចសម្រេចដោយមតិរបស់ខ្លួន ឬនៅពេលមានភាគីណាមួយស្នើឡើង ដើម្បីបើកសវនាការជាថ្មីទៀតនាពេលណាមួយមុនពេលធ្វើមជ្ឈត្តវិនិច្ឆ័យ ។

**ការលើកលែងចំពោះវិធានផ្សេងៗ**

**មាត្រា ៣០**

បើមានភាគីណាមួយដឹងថាមានប្បញ្ញត្តិ ឬតម្រូវការណាមួយនៃវិធានទាំងនេះមិនត្រូវបានគេអនុវត្តតាម ប៉ុន្តែនៅតែបន្តធ្វើមជ្ឈត្តការ ដោយពុំបានសំដែងការជំទាស់របស់ខ្លួនភ្លាមៗចំពោះការមិនអនុវត្តតាមនោះ នឹងត្រូវចាត់ទុកថាបានបាត់បង់សិទ្ធិជំទាស់របស់ខ្លួន ។

**ផ្នែកទី IV: មជ្ឈត្តវិនិច្ឆ័យ**

**ការសម្រេចផ្សេងៗ**

**មាត្រា ៣១**

១. នៅពេលពេលមានមជ្ឈត្តករ៣រូប មជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីសម្រេចដទៃទៀតរបស់វេទិកាមជ្ឈត្តកម្មនឹងធ្វើត្រូវឡើងដោយមតិភាគច្រើននៃមជ្ឈត្តករ ។

២. នៅពេលដែលគ្មានមតិភាគច្រើន ឬពេលដែលវេទិកាមជ្ឈត្តកម្មសម្រេចយ៉ាងដូច្នេះ មជ្ឈត្តករអធិបតីអាចធ្វើការសម្រេចដោយឯកច្ឆ័ន្ទក្នុងករណីមានបញ្ហាផ្នែកនីតិវិធី លើកលែងតែមានការសើរើឡើងវិញដោយវេទិកាមជ្ឈត្តកម្មនោះ ។

**ទម្រង់ និងអានុភាពនៃមជ្ឈត្តវិនិច្ឆ័យ**

**មាត្រា ៣២**

១. ក្រៅពីមជ្ឈត្តវិនិច្ឆ័យស្ថាពរ វេទិកាមជ្ឈត្តកម្មមានសិទ្ធិធ្វើមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ឬមជ្ឈត្ត-វិនិច្ឆ័យរបៀប ឬមជ្ឈត្តវិនិច្ឆ័យមិនពេញលេញ ។

២. មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានលក្ខណៈស្ថាពរ និងភ្ជាប់កាតព្វកិច្ច ចំពោះភាគីវិវាទ ។ ភាគីវិវាទមានតួនាទីត្រូវអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះដោយឥតបង្អង់ឡើយ ។

៣. វេទិកាមជ្ឈត្តកម្មនឹងបញ្ជាក់ហេតុផលនានាដែលមជ្ឈត្តវិនិច្ឆ័យនោះសម្អាងលើ លើកលែងតែភាគីវិវាទឯកភាពថាមិនបាច់បញ្ជាក់ហេតុផលទាំងនោះ ។

៤. មជ្ឈត្តវិនិច្ឆ័យត្រូវតែបានចុះហត្ថលេខាដោយមជ្ឈត្តករ ហើយត្រូវមានចុះកាលបរិច្ឆេទ និងទីកន្លែងដែលធ្វើមជ្ឈត្តវិនិច្ឆ័យនោះផង ។ នៅពេលដែលមានមជ្ឈត្តករបីរូប ហើយមួយរូបមិនបានចុះហត្ថលេខា មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីហេតុផលដែលនាំឱ្យមានអវត្តមាននៃហត្ថលេខានោះផង ។

៥. មជ្ឈត្តវិនិច្ឆ័យអាចធ្វើឡើងជាសាធារណៈបាន លុះត្រាតែមានការយល់ព្រមពីភាគីទាំងពីរប៉ុណ្ណោះ ។

៦. វេទិកាមជ្ឈត្តកម្មត្រូវផ្ញើច្បាប់ចម្លងនៃមជ្ឈត្តវិនិច្ឆ័យ ដែលបានចុះហត្ថលេខាដោយមជ្ឈត្តករទាំង-អស់ ទៅកាន់ភាគីវិវាទ ។

៧. ប្រសិនបើច្បាប់មជ្ឈត្តការនៃប្រទេសដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង តម្រូវឱ្យវេទិកាមជ្ឈត្ត-កម្មចងក្រងជាឯកសារ ឬចុះបញ្ជីមជ្ឈត្តវិនិច្ឆ័យនោះ វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តតាមតម្រូវការនោះ ក្នុងថេរៈវេលាដែលច្បាប់នោះបានកំណត់ ។

**ប្រព័ន្ធច្បាប់សម្រាប់អនុវត្ត ការស្រុះស្រួល**

១. វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តច្បាប់ ដែលភាគីវិវាទបានកំណត់ថាអាចអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនោះ ។ ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់ដូច្នោះទេ វេទិកាមជ្ឈត្តកម្មត្រូវប្រើប្រាស់ច្បាប់ដែលកំណត់ឡើងតាមវិវាទនៃច្បាប់ នូវវិធានណាដែលខ្លួនចាត់ថាអាចអនុវត្តបាន ។

២. វេទិកាមជ្ឈត្តកម្មអាចសម្រេចតាមការស្រុះស្រួល ឬតាមសមធម៌ លុះត្រាតែភាគីវិវាទផ្តល់សិទ្ធិយ៉ាងជាក់លាក់ឱ្យខ្លួនធ្វើដូច្នោះ ហើយច្បាប់សម្រាប់លើនីតិវិធីមជ្ឈត្តការនោះ អនុញ្ញាតិឱ្យធ្វើមជ្ឈត្តការរបៀបនោះបាន ។

៣. នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសេចក្តីសម្រេចស្របតាម លក្ខខ័ណ្ឌនាននៃកិច្ចសន្យា និងត្រូវយកមកពិចារណានូវរាល់ទម្លាប់ផ្នែកពាណិជ្ជកម្មនានាដែលអាចអនុវត្តបានចំពោះជំនួញនេះ ។

**ការស្រុះស្រួល ឬចូលបញ្ចប់នៃទៀនបើម្បីបញ្ចប់វិវាទ**

**មាត្រា ៣៤**

១. ប្រសិនបើមុនពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង ភាគីវិវាទឯកភាពលើដំណោះស្រាយណាមួយចំពោះវិវាទនោះ វេទិកាមជ្ឈត្តកម្មអាចចេញដីកាបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការនោះ ឬធ្វើកំណត់ត្រាដំណោះស្រាយនោះក្នុងទម្រង់ជា**មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល** ប្រសិនបើមានការ

ស្នើសុំភាគីទាំងសង្ខាង ហើយវេទិកាមជ្ឈត្តកម្មនោះបានទទួលយល់ព្រម។ វេទិកាមជ្ឈត្តកម្មមិនចាំបាច់បញ្ជាក់ពីហេតុផលផ្សេងៗក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យប្រភេទនេះឡើយ ។

២. ប្រសិនបើមុនពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង ការបន្តដំណើរការមជ្ឈត្តការប្រែជាមិនចាំបាច់ ឬមិនអាចទៅរួច ដោយសារមូលហេតុដែលមិនមានចែងក្នុងកថាខ័ណ្ឌ១ វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងទៅភាគីវិវាទ អំពីគោលបំណងរបស់ខ្លួនដែលចង់ចេញដីការបង្គាប់បញ្ចប់ដំណើរការមជ្ឈត្តការនោះ។ វេទិកាមជ្ឈត្តកម្មមានសិទ្ធិក្នុងការចេញដីការបែបនេះ លើកលែងតែភាគីណាមួយមានមូលដ្ឋានសមស្របដើម្បីជំទាស់។

៣. វេទិកាមជ្ឈត្តកម្មត្រូវផ្ញើជូនភាគីវិវាទទាំងអស់ នូវច្បាប់ចម្លងនៃដីការបញ្ចប់ដំណើរការមជ្ឈត្តការ ឬ*មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល* ដោយមានហត្ថលេខារបស់មជ្ឈត្តករទាំងអស់ផង។ ប្រសិនបើ**មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល**ត្រូវបានធ្វើឡើង បទប្បញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ និងកថាខ័ណ្ឌ៤ ដល់ ៧ នឹងត្រូវយកមកអនុវត្ត ។

## ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៣៥

១. ក្នុងកំឡុងពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យរួចមក ភាគីម្ខាងអាចស្នើទៅវេទិកា-មជ្ឈត្តកម្ម ឱ្យធ្វើការបកស្រាយមជ្ឈត្តវិនិច្ឆ័យនោះ ដោយមានការជូនដំណឹងទៅភាគីម្ខាងទៀតផង។

២. ការបកស្រាយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលសែសិបប្រាំថ្ងៃបន្ទាប់ពីទទួលបានសំណើ។ ការបកស្រាយត្រូវចាត់ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ហើយបញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ ដល់ ៧ នឹងត្រូវយកមកអនុវត្ត ។

## កំណែតម្រូវលើមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៣៦

១. ក្នុងកំឡុងពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យរួចមក ភាគីម្ខាងអាចស្នើទៅវេទិកា-មជ្ឈត្តកម្ម ដោយមានជូនដំណឹងទៅភាគីម្ខាងទៀតផង ឱ្យធ្វើកំណែតម្រូវនៅក្នុងមជ្ឈត្តវិនិច្ឆ័យរាល់កំហុសផ្នែកកុំព្យូទ័រ កំហុសផ្នែកកិច្ចការរដ្ឋបាល និងកំហុសផ្នែកបោះពុម្ព ឬកំហុសដទៃទៀតដែលមានលក្ខណៈស្រដៀងនោះ។ វេទិកាមជ្ឈត្តកម្មអាចធ្វើកំណែតម្រូវដោយគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីបានផ្សព្វផ្សាយមជ្ឈត្តវិនិច្ឆ័យរួចមក។

២. កំណែតម្រូវទាំងនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយបញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ ដល់៧ នឹងត្រូវ យកមកអនុវត្ត។

**បញ្ញត្តិវិនិច្ឆ័យបន្ថែម**

**មាត្រា ៣៧**

១. ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីទទួលបានបញ្ញត្តិវិនិច្ឆ័យ ភាគីម្ខាង អាចស្នើទៅវេទិកាមជ្ឈត្តកម្ម ដោយមានការជូនដំណឹងទៅភាគីម្ខាងទៀតផង ឱ្យធ្វើបញ្ញត្តិវិនិច្ឆ័យបន្ថែម អំពីការទាមទារដែលបាន លើកឡើងក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែមិនបានដាក់ចូលនៅក្នុងបញ្ញត្តិវិនិច្ឆ័យនោះ។

២. ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ឃើញថាសំណើសុំធ្វើបញ្ញត្តិវិនិច្ឆ័យបន្ថែមមានភាពត្រឹមត្រូវ ហើយ យល់ឃើញថាខ្លួនអាចកែតម្រូវលើចំនុចដែលបាត់បង់បាន ដោយមិនចាំបាច់មានសវនាការឬ ភស្តុតាង ដទៃទៀតនោះ វេទិកាមជ្ឈត្តកម្មត្រូវបំពេញបញ្ញត្តិវិនិច្ឆ័យរបស់ខ្លួនក្នុងរយៈពេលហុកសិបថ្ងៃ បន្ទាប់ពី ទទួលបានសំណើ។

៣. នៅពេលធ្វើបញ្ញត្តិវិនិច្ឆ័យបន្ថែម បញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ដល់៧ នឹងត្រូវយកមកអនុវត្ត។

**ថ្លៃចំណាយផ្សេងៗ**

**មាត្រា ៣៨**

វេទិកាមជ្ឈត្តកម្មត្រូវកំណត់ក្នុងបញ្ញត្តិវិនិច្ឆ័យរបស់ខ្លួននូវថ្លៃចំណាយផ្សេងៗដើម្បីធ្វើមជ្ឈត្តការ។ ពាក្យ ថា "ថ្លៃចំណាយ" រួមមានត្រឹមតែ:

(ក) ថ្លៃឈ្នួលនៃវេទិកាមជ្ឈត្តកម្ម ដោយមានបញ្ជាក់កម្រៃសម្រាប់មជ្ឈត្តករនីមួយៗ ដោយឡែកពីគ្នា និង ត្រូវបានកំណត់ដោយវេទិកាមជ្ឈត្តកម្មផ្ទាល់ស្របតាមមាត្រា៣៩

(ខ) ថ្លៃធ្វើដំណើរ និងចំណាយដទៃទៀតរបស់មជ្ឈត្តករទាំងអស់

(គ) ថ្លៃដំបូន្មានជំនាញការ និងជំនួយដទៃទៀតដែលតម្រូវដោយវេទិកាមជ្ឈត្តកម្ម

(ឃ) ថ្លៃធ្វើដំណើរ និងចំណាយដទៃទៀតរបស់សាក្សី តាមកម្រិតដែលវេទិកាមជ្ឈត្តកម្មអនុម័ត

(ង) ថ្លៃចំណាយលើតំណាង និងជំនួយផ្នែកច្បាប់របស់ភាគីឈ្នះ ប្រសិនបើតម្លៃនោះត្រូវបានទាមទារក្នុង ពេលដំណើរការមជ្ឈត្តការ និងត្រឹមតែកម្រិតមួយដែលវេទិកាមជ្ឈត្តកម្មកំណត់ថាជាចំនួនសមរម្យ។

(ច) ថ្លៃឈ្នួល និងចំណាយផ្សេងៗរបស់អាជ្ញាធរតែងតាំង ក៏ដូចជាចំណាយផ្សេងៗរបស់អគ្គលេខាធិការ នៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តកម្មនាទីក្រុងឡាអេ។

**មាត្រា ៣៩**

១. ថ្លៃឈ្នួលនៃវេទិកាមជ្ឈត្តកម្មត្រូវមានចំនួនសមរម្យ ដោយយកកត្តាចំនួនទឹកប្រាក់ក្នុងវិវាទ ភាព ស្មុគស្មាញនៃបញ្ហា ពេលវេលាដែលមជ្ឈត្តករចំណាយ និងកាលៈទេសៈដទៃទៀតនៃរឿងក្តីនោះមកធ្វើការ ពិចារណាផងដែរ។

២. ប្រសិនបើអាជ្ញាធរតែងតាំងមួយត្រូវបានភាគីវិវាទព្រមបង្កើតឡើង ឬត្រូវបានជ្រើសតាំងដោយអគ្គ-លេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តកម្មនាទីក្រុងឡាអេ ហើយប្រសិនបើអាជ្ញាធរនោះបានធ្វើតារាងតម្លៃសម្រាប់មជ្ឈត្តករនៅក្នុងរឿងក្តីអន្តរជាតិដែលខ្លួនគ្រប់គ្រង វេទិកាមជ្ឈត្តកម្មត្រូវយកតារាងតម្លៃនោះមកពិចារណាដើម្បីកំណត់ថ្លៃឈ្នួលរបស់ខ្លួន ក្នុងកម្រិតមួយដែលខ្លួនយល់ថាសមស្របនឹងកាលៈទេសៈនៃរឿងក្តី។

៣. ប្រសិនបើអាជ្ញាធរតែងតាំងនោះមិនបានបង្កើតតារាងតម្លៃសម្រាប់មជ្ឈត្តករក្នុងរឿងក្តីអន្តរជាតិទេ ភាគីណាក៏បានអាចស្នើទៅអាជ្ញាធរតែងតាំង នៅពេលណាមួយ ឱ្យចេញសេចក្តីថ្លែងមួយដែលចែងពីអំពីមូលដ្ឋាននៃការយកថ្លៃឈ្នួលសម្រាប់ប្រើជាទំលាប់ក្នុងរឿងក្តីអន្តរជាតិនានាដែលអជ្ញាធរនោះតែងតាំង មជ្ឈត្តករឱ្យដោះស្រាយ។ ប្រសិនបើអាជ្ញាធរតែងតាំងយល់ព្រមចេញសេចក្តីថ្លែងបែបនោះ វេទិកាមជ្ឈត្តកម្មត្រូវយកព័ត៌មានក្នុងនោះមកពិចារណាដើម្បីកំណត់ថ្លៃឈ្នួលរបស់ខ្លួន ក្នុងកំរឹតមួយដែលខ្លួនយល់ថាសមស្របនឹងកាលៈទេសៈនៃរឿងក្តី។

៤. នៅក្នុងករណីដែលបានលើកឡើងក្នុងកថាខ័ណ្ឌ២ និង៣ នៅពេលដែលមានសម្នើពីភាគីម្ខាង ហើយអាជ្ញាធរតែងតាំងយល់ព្រមបំពេញនាទីនោះ មុននឹងកំណត់ថ្លៃឈ្នួលរបស់ខ្លួន វេទិកាមជ្ឈត្តកម្មត្រូវពិគ្រោះយោបល់ជាមួយអាជ្ញាធរតែងតាំងជាមុនសិន ដោយអជ្ញាធរនោះអាចផ្តល់យោបល់ទាំងឡាយណាដែល ខ្លួនចាត់ថាសមស្របចំពោះវេទិកាមជ្ឈត្តកម្មកម្មពាក់ព័ន្ធនឹងតម្លៃប្រាក់ឈ្នួលទាំងនោះ។

**មាត្រា ៤០**

១. លើកលែងតែដូចមានចែងក្នុងកថាខ័ណ្ឌ២ ថ្លៃចំណាយលើមជ្ឈត្តការ ជាគោលការណ៍ ត្រូវទទួលបន្ទុកដោយភាគីដែលចាញ់។ យ៉ាងណាមិញ វេទិកាមជ្ឈត្តកម្មអាចបែងចែកបន្ទុកចំណាយឱ្យភាគីនិមួយៗ ប្រសិនបើខ្លួនយល់ថាមានលក្ខណៈសមស្រប ផ្អែកលើកាលៈទេសៈផ្សេងៗនៃរឿងក្តី។

២. ពាក់ព័ន្ធនឹងការចំណាយលើតំណាង និងជំនួយផ្នែកច្បាប់ដូចមានចែងក្នុងមាត្រា៣៨ កថាខ័ណ្ឌ(ង) វេទិកាមជ្ឈត្តកម្មមានសេរីភាពក្នុងការសម្រេចថា ភាគីណាត្រូវទទួលបន្ទុកលើការចំណាយនោះ ឬក៏អាចបែងចែកបន្ទុកចំណាយនោះឱ្យភាគីនិមួយៗ ប្រសិនបើខ្លួនយល់ថាការបែងចែកនោះមានភាពសមហេតុសមផល ផ្អែកលើកាលៈទេសៈទាំងឡាយនៃរឿងក្តី។

៣. នៅពេលចេញដីការបញ្ចប់ដំណើរការមជ្ឈត្តការ ឬធ្វើមជ្ឈត្តវិនិច្ឆ័យតាមការស្រុះស្រួល វេទិកា-មជ្ឈត្តកម្ម ត្រូវកំណត់ថ្លៃចំណាយលើមជ្ឈត្តការដូចមានចែងក្នុងមាត្រា៣៨ និងមាត្រា៣៩ កថាខ័ណ្ឌ១ នៅក្នុងដីការ ឬមជ្ឈត្តវិនិច្ឆ័យនោះ ។

៤. វេទិកាមជ្ឈត្តកម្មមិនអាចយកថ្លៃឈ្នួលបន្ថែមសម្រាប់ការបកស្រាយ ឬការកែតម្រូវ ឬការបំពេញមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣៥ ដល់៣៧ បានឡើយ ។

**ការតម្កល់ប្រាក់ចំណាយ**

មាត្រា ៤១

១. នៅពេលចាប់បង្កើតឡើង វេទិកាមជ្ឈត្តកម្មអាចស្នើឱ្យភាគីនីមួយៗតម្កល់ប្រាក់ស្មើៗគ្នា សម្រាប់ថ្លៃចំណាយផ្សេងៗដូចមានចែងក្នុងមាត្រា ៣៨ កថាខ័ណ្ឌ(ក) (ខ) និង(គ) ។

២. ក្នុងពេលដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចស្នើប្រាក់តម្កល់បន្ថែមពីភាគីវិវាទ ។

៣. ប្រសិនបើមានអាជ្ញាធរតែងតាំងមួយ ត្រូវបានព្រមព្រៀងដោយភាគីវិវាទ ឬជ្រើសតាំងដោយ អគ្គ-លេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តកម្មនាទីក្រុងឡាអេ និងនៅពេលមានសម្នើពីភាគីម្ខាង ហើយអាជ្ញាធរតែងតាំងយល់ព្រមបំពេញតួនាទីនោះ វេទិកាមជ្ឈត្តកម្មត្រូវពិគ្រោះយោបល់ជាមួយអាជ្ញាធរតែងតាំងនោះជាមុនសិន មុននឹងកំណត់តម្លៃប្រាក់តម្កល់ ឬប្រាក់តម្កល់បន្ថែម ដោយអជ្ញាធរនោះ អាចផ្តល់យោបល់ទាំងឡាយណាដែលខ្លួនចាត់ថាសមស្របចំពោះវេទិកាមជ្ឈត្តកម្ម ពាក់ព័ន្ធនឹងតម្លៃប្រាក់តម្កល់ ឬប្រាក់តម្កល់បន្ថែមទាំងនោះ ។

៤. ប្រសិនបើពុំមានការបង់ប្រាក់តម្កល់ដែលបានតម្រូវនោះ ឱ្យបានគ្រប់ចំនួន ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលសម្នើនោះទេ វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងដល់ភាគីវិវាទដើម្បីឱ្យ ភាគីណាមួយអាចធ្វើការបង់ប្រាក់ដែលបានតម្រូវនោះ ។ ប្រសិនបើពុំមានការបង់ប្រាក់ទេ វេទិកាមជ្ឈត្តកម្មអាចបញ្ជាឱ្យពន្យាពេល ឬបញ្ចប់ដំណើរការមជ្ឈត្តការនោះ ។

៥. បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួច វេទិកាមជ្ឈត្តកម្មត្រូវផ្តល់របាយការណ៍គណនេយ្យមួយដល់ភាគីវិវាទដែលបានបង់ប្រាក់តម្កល់ និងត្រូវប្រគល់សមតុល្យដែលមិនបានចំណាយដល់ភាគីទាំងនោះវិញ ។

---

ព័ត៌មានបន្ថែមអាចទទួលពីៈ

អគ្គលេខាធិការដ្ឋាន UNCITRAL

មជ្ឈមណ្ឌលអន្តរជាតិទីក្រុងវៀន

ប្រអប់សំបុត្រ P.O Box 500

A- 1400 ទីក្រុងវៀន ប្រទេសអូទ្រីស

ទូរស័ព្ទៈ (+៤៣ ១) ២៦០៦០-៤០៦០

ហ្វាក់ៈ (+៤៣ ១) ២៦០៦០- ៥៨១៣

អ៊ិនធឺណែតៈ http://www.uncitral.org

អ៊ីមែលៈ uncitral@uncitral.org

**ឧបសម្ព័ន្ធ៣.**

# ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងសម្រួលដល់ការដោះស្រាយជាបន្ទាន់ តាមការផ្សះផ្សានូវវិវាទពាណិជ្ជកម្មដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទដើម្បីការពារសិទ្ធិនិងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ និងដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

ច្បាប់នេះមិនប៉ះពាល់ដល់អានុភាពគតិយុត្តិនៃច្បាប់នានាឯទៀតរបស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សាបាន ឬ ដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សាមិនបាន ។

**មាត្រា ២.-**

និយមន័យ និងវិធាននៃការបកស្រាយពាក្យដែលប្រើក្នុងច្បាប់នេះ :

ក- "មជ្ឈត្តការ" គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬ នៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ ។

ខ- "វេទិកាមជ្ឈត្តកម្ម" គឺជាមជ្ឈត្តករមួយនាក់ ឬ មួយក្រុម ។

គ- "តុលាការ" គឺជាស្ថាប័ន ឬ អង្គការនៃប្រព័ន្ធតុលាការរបស់ប្រទេសមួយ ។

ឃ- "កិច្ចព្រមព្រៀងផ្សះផ្សា" ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬ វិវាទបែបណាមួយដែលកើតឡើង ឬ ដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬ គ្មានក៏ដោយ ។

ង-ក្រៅពីមាត្រា ៣៦ កាលណាបទប្បញ្ញត្តិនានានៃច្បាប់នេះទុកសេរីភាពឱ្យភាគីវិវាទកំណត់ពីបញ្ហាណាមួយ សេរីភាពនេះគឺរាប់បញ្ចូលទាំងសិទ្ធិរបស់ភាគីវិវាទក្នុងការអនុញ្ញាតឱ្យមានភាគីទី ៣ រួមបញ្ចូលទាំងស្ថាប័នមួយ ដើម្បីធ្វើការសម្រេចលើបញ្ហានោះ ។

ច-ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់នេះ យោងតាមអ្វីដែលភាគីវិវាទបានព្រមព្រៀង ឬ អាចនឹងព្រមព្រៀងគ្នា ឬ យោងតាមមធ្យោបាយផ្សេងទៀតនៃកិច្ចព្រមព្រៀងរបស់ភាគីវិវាទ កិច្ចព្រមព្រៀងនោះ ។

ឆ-ក្រៅពីមាត្រា ៣៣ (១) និងមាត្រា ៤០ (១) នៃច្បាប់នេះ កាលណាបទប្បញ្ញត្តិនៃច្បាប់នេះយោងតាមការប្តឹងទាមទារ បទប្បញ្ញត្តិនោះក៏ត្រូវអនុវត្តចំពោះការប្តឹងទាមទារបកវិញដែរ ហើយនៅពេលដែលយោងតាមការដោះសាពីការប្តឹងទាមទារ ក៏ត្រូវអនុវត្តចំពោះការដោះសាពីការប្តឹងទាមទារបកវិញដែរ ។

ជ-មជ្ឈត្តការមានលក្ខណៈជា "អន្តរជាតិ" ក្នុងករណី :

ជ.១-ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សាមានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នា ក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

ជ.២-ទីកន្លែងមួយក្នុងចំណោមទីកន្លែងខាងក្រោមនោះ ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ :

-ទីកន្លែងធ្វើមជ្ឈត្តការ : ប្រសិនបើបានកំណត់ ឬ បានយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ។

-ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬ ទីកន្លែងជិតជាងគេនៃរឿងពាក់ព័ន្ធនឹងវិវាទ ។

ជ.៣-ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងទៅនឹងប្រទេសលើសពីមួយ ។

ជ.៤-តាមគោលបំណងក្នុងកថាខណ្ឌ (ជ) នេះ :

-ប្រសិនបើភាគីវិវាទមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយកន្លែង ទីកន្លែងដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតទៅនឹងកិច្ចព្រមព្រៀងផ្សះផ្សាគឺជាទីកន្លែងពាណិជ្ជកម្ម ។

-ប្រសិនបើភាគីវិវាទមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគីនោះ ។

ឈ-ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ច

សន្យាក៏ដោយ ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍ : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក ។

**មាត្រា ៣.–**

លើកលែងតែភាគីទាំងអស់បានព្រមព្រៀងផ្សេងពីនេះ :

១-លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួល ក្នុងករណីដែលបានប្រគល់ឱ្យអ្នកទទួលដោយផ្ទាល់ដៃ ឬ ប្រគល់ដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានប្រៃសណីយ៍របស់អ្នកទទួល ។ ប្រសិនបើរកកន្លែងទាំងនោះមិនឃើញទេ ក្រោយពីការស្វះស្វែងរកយ៉ាងល្អិតល្អន់រួចមក លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួលក្នុងករណីបានផ្ញើតាមរយៈលិខិតអនុសិដ្ឋ ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ហេតុផលថា ពិតជាបានខំប្រឹងប្រែងប្រគល់លិខិតទៅដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានរបស់អ្នកទទួលដែលស្គាល់ចុងក្រោយបំផុត ។

២-បទប្បញ្ញត្តិនានាក្នុងមាត្រា ៣ នៃច្បាប់នេះ មិនយកទៅអនុវត្តលើលិខិតឆ្លើយឆ្លងក្នុងពេលដំណើរការកាត់ក្តីរបស់តុលាការទេ ។

**មាត្រា ៤.–**

ត្រូវបានចាត់ទុកថាបានបោះបង់សិទ្ធិជំទាស់របស់ខ្លួន ប្រសិនបើភាគីវិវាទមួយបានដឹងថាភាគីវិវាទផ្សេងទៀត អាចប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ពុំគោរពតាមការតម្រូវរបស់កិច្ចព្រមព្រៀងផ្សះផ្សា ប៉ុន្តែភាគីវិវាទនោះនៅតែបន្តដំណើរការមជ្ឈត្តការដោយមិនបានជំទាស់ទៅនឹងការមិនគោរពនោះ ហើយក្នុងករណីដែលមានចែងពីរយៈពេលកំណត់សម្រាប់ការជំទាស់ ភាគីវិវាទនោះពុំបានធ្វើការពន្យារពេលជាចាំបាច់ ។

**មាត្រា ៥.-**

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តុលាការធ្វើអន្តរាគមន៍បានតែក្នុងករណីទាំងឡាយណា ដែលច្បាប់នេះបានចែង ។

**មាត្រា ៦.-**

មុខងារផ្សេងៗដែលមានចែងក្នុងមាត្រា ១៩ កថាខណ្ឌទី ៣, ៤ និង ៥ មាត្រា ២១ កថាខណ្ឌទី ៣ មាត្រា ២២ មាត្រា ២៤ កថាខណ្ឌទី ៣ នៃច្បាប់នេះ ត្រូវបំពេញដោយ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌល ជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

## ជំពូកទី ២
## កិច្ចព្រមព្រៀងផ្សះផ្សា

**មាត្រា ៧.-**

កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក ។

កិច្ចព្រមព្រៀងផ្សះផ្សាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។ ដែលហៅថាកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរ គឺជាកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយ ភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ញើរលិខិតឆ្លាម ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធ អេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការប្តូរ គ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាម ទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ។ សេចក្តីយោងក្នុងកិច្ចសន្យា និង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបាន ល្គឹកណាកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការ ដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា ។

**មាត្រា ៨.-**

នៅពេលដោះស្រាយបណ្ដឹងវិវាទ តុលាការដែលទទួលដោះស្រាយវិវាទដែលជាកម្ម-វត្ថុកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវបញ្ជូនភាគីវិវាទទៅធ្វើមជ្ឈត្តការ ប្រសិនបើមានសំណើពីភាគីវិវាទមួយ វៀរលែងតែតុលាការនោះរកឃើញថាកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវចាត់ទុកជាមោឃៈ ឬ មិនអាចអនុវត្តបាន ។

ទោះបីជាមានបណ្ដឹងទាមទារទៅតុលាការដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏ដំណើរការរបស់វេទិកាមជ្ឈត្តកម្មអាចចាប់ផ្ដើម ឬ បន្តដំណើរការបានតទៅទៀត ហើយតុលាការត្រូវបង្វែរសមត្ថកិច្ចជូនទៅវេទិកាមជ្ឈត្តកម្មវិញ ដោយរង់ចាំការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៩.-**

នៅមុនពេល ឬ ក្នុងពេលកំពុងដំណើរការមជ្ឈត្តការ ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្ដល់វិធានការបណ្ដោះអាសន្ន ដើម្បីការពារ និងការផ្ដល់នូវវិធានការទាំងនោះដោយតុលាការពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ ។

## ជំពូកទី ៣
## មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការនៃក្រសួងពាណិជ្ជកម្ម

**មាត្រា ១០.-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមួយឯករាជ្យ នៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ។ គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគឺ :

១-ជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់គ្រប់គ្រងរឿងមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលកិច្ចព្រមព្រៀងជាក់ច្បាស់មួយនៃភាគីវិវាទ ដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

៣-ធានាឱ្យមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់ ។ គោល

បំណងនេះរួមបញ្ចូលការកំណត់ស្តង់ដាសម្រាប់លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ។

**មាត្រា ១១.-**

រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ បរទេសដែលជាមជ្ឈត្តករត្រូវចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមានភារកិច្ចកំណត់ពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវបញ្ជីឈ្មោះមជ្ឈត្តករជារៀងរាល់ឆ្នាំ ។ បញ្ជីនេះមិនមានលក្ខណៈដាច់ណាត់ទេ ភាគីវិវាទអាចជ្រើសរើសមជ្ឈត្តករក្រៅពីបញ្ជីក៏បាន ។

**មាត្រា ១២.-**

អាចសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការបាន រូបវន្តបុគ្គល និងនីតិបុគ្គលដូចខាងក្រោម :

-រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះឈ្មោះក្នុងបញ្ជីរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-សភាពាណិជ្ជកម្ម

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និង សេវាករ ។

សំណើសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដែលមានចំនួនមិនលើសពីប្រាំពីរ (៧) នាក់ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិរយៈពេលបី (៣) ឆ្នាំ ហើយអាចឈរឈ្មោះបន្តមួយអាណត្តិទៀតបាន ។

**មាត្រា ១៣.-**

សភាពាណិជ្ជកម្មអាចរៀបចំមជ្ឈមណ្ឌលមជ្ឈត្តកម្មមួយនៅភ្នំពេញ ។ រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មរបស់ខ្លួនដោយឡែកសម្រាប់ដោះស្រាយវិវាទរវាងសមាជិក និងរវាងសមាជិកជាមួយអ្នកដទៃ ។

**មាត្រា ១៤.–**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវគ្រប់គ្រងដោយ :

-មហាសន្និបាត

-ក្រុមប្រឹក្សាប្រតិបត្តិ ។

ភារកិច្ចសំខាន់ៗរបស់មហាសន្និបាតមាន :

-ប្រជុំមួយដង ឬ ពីរដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ឬ តាមសំណើរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ។

-ជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ

-ពិនិត្យរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ

-សម្រេចលើស្ថានភាពហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-កំណត់សោហ៊ុយ ដែលជាតម្លៃនៃការធ្វើមជ្ឈត្តការ

-ពិនិត្យសម្រេចលើរាល់សំណើកែប្រែលិខិតបទដ្ឋានដែលទាក់ទងដល់ដំណើរការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ និងដំណើរការមជ្ឈត្តការ ។

-បំពេញភារកិច្ចផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៥.–**

មហាសន្និបាតរួមប្រជុំដោយសមាជិកជារូបវន្តបុគ្គល និងតំណាងមួយរូបរបស់សមាជិកជានីតិបុគ្គលនិមួយៗ ។

**មាត្រា ១៦.–**

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកដោយមហាសន្និបាត ។ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៧.-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

**មាត្រា ១៨.-**

ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តករត្រូវមានចំនួនសេស ។

បើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួនបី (៣) នាក់ ។

**មាត្រា ១៩.-**

ការជ្រើសតាំងមជ្ឈត្តករត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

១-មិនត្រូវបដិសេធជនណាម្នាក់មិនឱ្យធ្វើមជ្ឈត្តករ ដោយសារមូលហេតុនៃសញ្ជាតិរបស់គេឡើយ លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

២-ភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីនៃការតែងតាំងមជ្ឈត្តករមួយ (១) នាក់ ឬ ច្រើននាក់ យោងតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

៣-ករណីមិនបានព្រមព្រៀងពីនីតិវិធីនេះ :

ក-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករបី (៣) នាក់ ភាគីវិវាទនីមួយៗត្រូវជ្រើសតាំងមជ្ឈត្តករមួយ (១) នាក់ ហើយមជ្ឈត្តករទាំងពីរនាក់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទីបី ។ ប្រសិនបើភាគីវិវាទណាមួយពុំបានជ្រើសតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពេលទទួលសំណើជ្រើសតាំងពីភាគីវិវាទម្ខាងទៀត ឬ ប្រសិនបើមជ្ឈត្តករទាំងពីរ (២) នាក់ ពុំបានព្រមព្រៀងលើការតែងតាំងមជ្ឈត្តករទីបីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីត្រូវបានគេជ្រើសតាំងរួចមក តុលាការ ( តុលាការពាណិជ្ជ-កម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជ-

កម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទី ៣ តាមការស្នើសុំនៃភាគីវិវាទណាមួយ ។

ខ-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករតែមួយនាក់ ប្រសិនបើភាគីវិវាទមិនអាចព្រមព្រៀងលើការជ្រើសតាំងមជ្ឈត្តករទេនោះ តុលាការ (តុលាការ ពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះត្រូវជ្រើសតាំងមជ្ឈត្តករតាមសំណូមពររបស់ភាគីវិវាទណាមួយ ។

៤-តាមនីតិវិធីជ្រើសតាំងមជ្ឈត្តករ ដែលបានព្រមព្រៀងដោយភាគីវិវាទភាគីវិវាទណាក៏ដោយ អាចធ្វើសំណូមពរទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះឱ្យចាត់វិធានការចាំបាច់ ក្នុងករណីណាមួយដូចខាងក្រោម :

ក-ភាគីវិវាទមួយមិនបានប្រតិបត្តិតាមការតម្រូវក្នុងនីតិវិធី ឬ

ខ-ភាគីវិវាទ ឬ មជ្ឈត្តករពីរ (២) នាក់ មិនអាចឈានដល់ការព្រមព្រៀងដូចដែលគេរំពឹងទុកតាមនីតិវិធីនេះ ឬ

គ-ភាគីទីបី ដោយរាប់បញ្ចូលទាំងស្ថាប័នមួយផង មិនបានអនុវត្តតួនាទីណាមួយដូចដែលបានប្រគល់ឱ្យក្នុងនីតិវិធីនោះ ។ មាត្រានេះ មិនត្រូវបានយកមកអនុវត្តទេ ប្រសិនបើការព្រមព្រៀងស្តីពីនីតិវិធីជ្រើសតាំងមជ្ឈត្តករមានចែងពីវិធីផ្សេងទៀតសម្រាប់ធានាដល់ការជ្រើសតាំងនោះ ។

៥-ការជ្រើសតាំងរបស់តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ លើបញ្ហាណាមួយតាមកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ គឺជាការសម្រេចដែលមិនអាចតវ៉ាបានឡើយ ។ នៅក្នុងការជ្រើសតាំងមជ្ឈត្តករម្នាក់ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិចារណាពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលបានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង ។ ក្នុងករណីមានមជ្ឈត្តករតែមួយនាក់

ឬ មានមជ្ឈត្តករទីបី នៅក្នុងការធ្វើមជ្ឈត្តការដែលមានលក្ខណៈអន្តរជាតិ តុលាការ ( តុលា-ការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិនិត្យលទ្ធភាពជ្រើសតាំងមជ្ឈត្តករដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ភាគីវិវាទ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា ១៩ នៃច្បាប់នេះ ។

**មាត្រា ២០.-**

បុគ្គលម្នាក់ដែលត្រូវគេជ្រើសតាំងជាមជ្ឈត្តករ ត្រូវបង្ហាញពីលក្ខណៈពិសេសដែលអាចបង្កឱ្យមានការសង្ស័យពីភាពមិនលម្អៀង ឬ ពីភាពឯករាជ្យរបស់ខ្លួន ចាប់ពីពេលដែលត្រូវគេជ្រើសតាំងមក រហូតដល់ពេលបញ្ចប់ដំណើរការមជ្ឈត្តការ ។ មជ្ឈត្តករត្រូវបង្ហាញពីលក្ខណៈពិសេសទាំងនោះឱ្យភាគីវិវាទបានដឹង ដោយគ្មានពន្យារពេល លើកលែងតែភាគីវិវាទបានដឹងពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករនោះរួចហើយ ។

មជ្ឈត្តករម្នាក់អាចត្រូវជំទាស់តែក្នុងករណីដែលកើតមានការសង្ស័យពីលក្ខណៈពិសេសដែលប៉ះពាល់ដល់ភាពមិនលម្អៀង ឬ ភាពឯករាជ្យរបស់ខ្លួន ឬ នៅពេលដែលខ្លួនមិនមានលក្ខណៈសម្បត្តិដូចដែលភាគីវិវាទបានព្រមព្រៀង ។ ភាគីវិវាទមួយអាចជំទាស់នឹងមជ្ឈត្ត-ករដែលខ្លួនបានជ្រើសតាំង ឬ បានចូលរួមជ្រើសតាំងតែក្នុងករណីដែលមូលហេតុនៃការជំទាស់នោះត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ ។

**មាត្រា ២១.-**

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

១-ភាគីវិវាទ អាចព្រមព្រៀងលើនីតិវិធីនៃការជំទាស់នឹងមជ្ឈត្តករដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ៣ ក្នុងមាត្រានេះ ។

២-ក្នុងករណីគ្មានការព្រមព្រៀងលើនីតិវិធីនៃការជំទាស់នេះ ភាគីវិវាទមួយដែលមានបំណងជំទាស់នឹងមជ្ឈត្តករ ត្រូវធ្វើលិខិតតវ៉ាបញ្ជាក់មូលហេតុពីការជំទាស់នោះជាលាយលក្ខណ៍អក្សរទៅកាន់វេទិកាមជ្ឈត្តកម្ម ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ក្រោយពេលបានដឹងពីលក្ខណៈពិសេស ដូចចែងក្នុងមាត្រា ២០ នៃកថាខណ្ឌទី ២ ។ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ លើកលែងតែមជ្ឈត្តករដែល

គេជំទាស់នោះ ដកខ្លួនចេញពីមុខតំណែង ឬ លើកលែងតែភាគីវិវាទមួយទៀតបានឯកភាពនឹងការជំទាស់នោះ ។

៣-ប្រសិនបើការជំទាស់ដែលត្រូវធ្វើតាមនីតិវិធីដែលព្រមព្រៀងដោយភាគីវិវាទ ឬ តាមនីតិវិធីក្នុងកថាខណ្ឌទី ២ នៃមាត្រានេះពុំបានសម្រេចទេនោះ ភាគីជំទាស់អាចស្នើសុំឱ្យតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយលើការជំទាស់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងបដិសេធការជំទាស់ ។ ក្នុងពេលរង់ចាំការសម្រេចរបស់តុលាការលើសំណើជំទាស់នេះ វេទិកាមជ្ឈត្តកម្មក្នុងនោះមានទាំងមជ្ឈត្តករដែលត្រូវគេជំទាស់ផងអាចបន្តដំណើរការមជ្ឈត្តការ ហើយអាចធ្វើសេចក្តីសម្រេចបាន ។

**មាត្រា ២២.-**

ប្រសិនបើមជ្ឈត្តករម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុខាងច្បាប់ ឬ មូលហេតុជាក់ស្តែងណាមួយ ឬ មូលហេតុដទៃទៀតក្នុងរយៈពេលមួយសមស្របនោះ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមជ្ឈត្តករនោះដកខ្លួនចេញពីមុខតំណែង ឬ ដោយភាគីវិវាទឯកភាពបញ្ចប់អាណត្តិនោះ ។ ផ្ទុយពីនេះ បើនៅតែមានភាពខ្វែងគ្នាស្តីពីមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំងនេះ ភាគីណាក៏ដោយអាចស្នើសុំឱ្យតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាកាកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយពីការបញ្ចប់អាណត្តិនោះ ។

តាមមាត្រានេះ ឬ មាត្រា ២១ កថាខណ្ឌទី ២ នៃច្បាប់នេះ ប្រសិនបើមជ្ឈត្តករម្នាក់ដកខ្លួនចេញពីមុខតំណែង ឬ ប្រសិនបើភាគីមួយឯកភាពចំពោះការបញ្ចប់អាណត្តិរបស់មជ្ឈត្តករនោះ ហេតុការណ៍នេះមិនបណ្តាលឱ្យមានការទទួលយកជាការបាននូវមូលហេតុណាមួយដែលចែងក្នុងមាត្រានេះ ឬ មាត្រា ២០ កថាខណ្ឌទី ២ នៃច្បាប់នេះឡើយ ។

**មាត្រា ២៣.-**

ក្នុងករណីដែលអាណត្តិរបស់មជ្ឈត្តករម្នាក់ត្រូវបញ្ចប់តាមបញ្ញត្តិនៃមាត្រា ២១ ឬ មាត្រា ២២ នៃច្បាប់នេះ មជ្ឈត្តករជំនួសនឹងត្រូវជ្រើសតាំងស្របតាម វិធាននៃមាត្រា ១៩ នៃច្បាប់នេះ ។

## ជំពូកទី ៥
## សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម

**មាត្រា ២៤.-**

សមត្ថកិច្ចរបស់វេទិការមជ្ឈត្តកម្មត្រូវកំណត់ដូចខាងក្រោម :

១-វេទិកាមជ្ឈត្តកម្មអាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះមានការជំទាស់នានាដែលទាក់ទងនឹងអត្ថិភាព ឬ សុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ សម្រាប់គោលដៅនេះ ខចែងស្តីពីការផ្សះផ្សាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទិនទៅនឹងល័ក្ខខ័ណ្ឌដទៃទៀតក្នុងកិច្ចសន្យាឡើយ ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការមិននាំអោយខចែងស្តីពីការផ្សះផ្សានោះបាត់សុពលភាពឡើយ ។

២-ទឡ្ហីករណ៍ដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានអំណាចធ្វើមជ្ឈត្តការនោះត្រូវបង្ហាញឱ្យឃើញមុនការដាក់ជូនពាក្យដោះសា ។ មិនត្រូវហាមឃាត់ភាគីវិវាទមួយមិនឱ្យលើកឡើងពីទឡ្ហីករណ៍បែបនេះ ដោយសារតែភាគីនោះបានតែងតាំង ឬ បានចូលរួមតែងតាំងមជ្ឈត្តករឡើយ ។ ទឡ្ហីករណ៍ដែលបញ្ជាក់ថា ក្របខ័ណ្ឌជំលោះដែលមានកំរិតហួសពីក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មត្រូវបង្ហាញភ្លាមៗនៅពេលដែលបញ្ហាហួសក្របខ័ណ្ឌសមត្ថកិច្ចនេះ ត្រូវបានគេលើកឡើងក្នុងពេលធ្វើមជ្ឈត្តការ ។ ក្នុងចំណោមករណីទាំងពីរ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណ៍ ដែលលើកឡើងក្រោយរយៈពេលកំណត់ ប្រសិនបើពិចារណាឃើញថា ការយឺតយ៉ាវនេះមានភាពត្រឹមត្រូវ ។

៣-វេទិកាមជ្ឈត្តកម្មអាចធ្វើសេចក្តីសម្រេចលើទឡ្ហីករណ៍ដូចចែងក្នុងកថាខណ្ឌ

ទី ២ នៃមាត្រានេះ ដោយចាត់ទុកថាជាបញ្ហាដំបូង ឬ ថាជាការសម្រេចតាមជាក់ស្តែង ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាជាបញ្ហាដំបូងដែលខ្លួនមានអំណាចសម្រេចនោះ ភាគីណាក៏ដោយ ក៏អាចធ្វើសំណើទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឱ្យសម្រេចចុងក្រោយលើបញ្ហានេះក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីការសម្រេចនោះរបស់វេទិកា ។ ការសម្រេចរបស់តុលាការក្នុងរឿងនេះគឺជាការសម្រេចដែលមិនអាចតវ៉ាបាន ។ ក្នុងពេលរង់ចាំការសម្រេចពីតុលាការនោះ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យបាន ។

**មាត្រា ២៥.–**

តាមការស្នើសុំរបស់ភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីណាមួយចាត់វិធានការបណ្តោះអាសន្នទៅតាមការចាំបាច់ទាក់ទិននឹងកម្មវត្ថុវិវាទ វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទណាមួយបង់ប្រាក់ធានាសមស្របសម្រាប់វិធានការនេះ ។

## ជំពូកទី ៦
## ដំណើរការនៃនីតិវិធីមជ្ឈត្តការ

**មាត្រា ២៦.–**

ភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនបាន ។

**មាត្រា ២៧.–**

ភាគីវិវាទអាចព្រមព្រៀង ឬ មិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ ។

ក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មរួមមានអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ ។

**មាត្រា ២៨.-**

ភាគីវិវាទអាចព្រមព្រៀងពីទីកន្លែងមជ្ឈត្តការ ។ ក្នុងករណីមិនបានព្រមព្រៀងពីទីកន្លែងទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ទីតាំងដោយគិតគូរពីលក្ខណៈពិសេសនៃវិវាទ ក្នុងនោះត្រូវមានការឯកភាពពីភាគីវិវាទផង ។

ថ្វីបើមានបទប្បញ្ញត្តិក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏វេទិកាមជ្ឈត្តកម្មអាចប្រជុំនៅកន្លែងណាមួយដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងបំណងពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬ ធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬ ឯកសារដទៃទៀត ។

**មាត្រា ២៩.-**

ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយ ចាប់ផ្តើមឡើងនៅថ្ងៃនៃកាលបរិច្ឆេទ ដែលភាគីឆ្លើយតបបានទទួលសំណើសុំឱ្យធ្វើមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

**មាត្រា ៣០.-**

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬ លើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬ លើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ ។

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬ ដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣១.-**

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬ កំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសាលើចំណុចទាំងនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្តឹងទាមទារ ឬ ការដោះសា ត្រូវបញ្ជាក់ផ្សេងពីនេះ ។ ភាគីវិវាទអាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសា ឬ អាចបន្ថែមការយោងលើឯកសារ ឬ ភស្តុតាងដទៃទៀត ដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬបំពេញបន្ថែមលើពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសាររបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរការធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យារពេលដើម្បីកែសម្រួលនេះពុំមានលក្ខណៈសមស្រប ។

**មាត្រា ៣២.-**

លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ដើម្បីបង្ហាញពីភស្តុតាង ឬ ទឡ្ហីករណ៍ផ្ទាល់មាត់ ឬ ក៏ត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋាននៃឯកសារ ឬ លិខិតស្នាមដទៃទៀត ។ ក៏ប៉ុន្តែបើមានសំណើពីភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវរៀបចំសវនាការបែបនេះ ក្នុងដំណាក់កាលសមស្របណាមួយនៃមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានឯកភាពថា មិនត្រូវធ្វើសវនាការ ។

ត្រូវផ្តល់ដំណឹងឱ្យបានគ្រប់គ្រាន់ជាមុនដល់ភាគីវិវាទស្តីពីសវនាការ ឬ ក៏ការប្រជុំណាមួយរបស់វេទិកាមជ្ឈត្តកម្ម ដែលមានគោលបំណងធ្វើអធិការកិច្ចលើសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ និងឯកសារដទៃទៀត ។

រាល់សេចក្តីថ្លែង ឯកសារ ឬ ព័ត៌មានដទៃទៀត ដែលភាគីវិវាទមួយផ្តល់ជូនវេទិកាមជ្ឈត្តកម្ម ក៏ត្រូវបញ្ជូនទៅឱ្យភាគីវិវាទម្ខាងទៀតដែរ ។ របាយការណ៍របស់អ្នកជំនាញការ ឬ

ឯកសារភស្តុតាងណាមួយ ដែលវេទិកាមជ្ឈត្តកម្មអាចយកជាសំអាង ដើម្បីធ្វើការសម្រេច ក៏ត្រូវបញ្ជូនជាដំណឹងឱ្យភាគីវិវាទដែរ ។

**មាត្រា ៣៣.-**

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ហើយបើគ្មានការបង្ហាញមូលហេតុគ្រប់គ្រាន់ :

១-វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការមជ្ឈត្តការ ក្នុងករណីដែលអ្នកប្តឹងពុំមានបញ្ជាក់លើពាក្យបណ្តឹងទាមទាររបស់ខ្លួនតាមមាត្រា ៣១ នៃ កថាខណ្ឌទី ១ នៃច្បាប់នេះ ។

២-បើភាគីឆ្លើយតបពុំអាចផ្តល់សេចក្តីដោះសាររបស់ខ្លួនដូចចែងក្នុងមាត្រា ៣១ នៃកថាខណ្ឌទី ១ នៃច្បាប់នេះ វេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការមជ្ឈត្តការដោយពុំចាត់ទុកការខកខាននេះថា ជាការទទួលស្គាល់ពាក្យចោទប្រកាន់របស់ភាគីប្តឹងទាមទារឡើយ ។

៣-បើភាគីវិវាទណាមួយពុំបានបង្ហាញមុខនៅសវនាការ ឬ ពុំបានផ្តល់ឯកសារភស្តុតាង វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខ ។

**មាត្រា ៣៤.-**

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាច :

១-តែងតាំងអ្នកជំនាញការម្នាក់ ឬ ច្រើននាក់ ដើម្បីរាយការណ៍ឱ្យខ្លួនស្តីពីបញ្ហាជាក់លាក់នានា ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

២-តម្រូវឱ្យភាគីវិវាទមួយផ្តល់ព័ត៌មាន ឬ ឯកសារ ឬ អនុញ្ញាតឱ្យអ្នកជំនាញការពិនិត្យលើឯកសារ សម្ភារៈដែលសមស្របផ្សេងៗដែលទាក់ទងដល់ការធ្វើអធិការកិច្ចរបស់អ្នកជំនាញការ ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើមានភាគីវិវាទមួយស្នើសុំ ឬ វេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញការបន្ទាប់ពីបានបង្ហាញរបាយការណ៍ផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សររួចហើយ ត្រូវចូលរួមក្នុងសវនាការដែលក្នុងឱកាសនោះ ភាគីវិវាទអាចលើកសំណួរ និងអញ្ជើញជំនាញការផ្សេងទៀត ក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីចំណុចជាក់លាក់នៃជម្លោះ ។

**មាត្រា ៣៥.-**

វេទិកាមជ្ឈត្តកម្ម ឬ ភាគីវិវាទមួយដោយបានការឯកភាពពីវេទិកាមជ្ឈត្តកម្ម អាចស្នើសុំជំនួយពីតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ក្នុងការត្រួតពិនិត្យភស្តុតាង ។ តុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬតុលាការកំពូល) អាចអនុវត្តតាមសំណើនេះនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន និងដោយអនុលោមតាមវិធានស្តីពីការត្រួតពិនិត្យភស្តុតាង ។

## ជំពូកទី ៧
## ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម
## និងការបញ្ចប់ដំណើរការមជ្ឈត្តការ

**មាត្រា ៣៦.-**

ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យវេទិកាមជ្ឈត្តកម្មត្រូវ ៖

១-សម្រេចពីវិវាទមួយទៅតាមវិធាននៃច្បាប់ ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនេះ ។ ការកំណត់យកច្បាប់ ឬ ប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសំអាងលើភាពផ្ទុយគ្នានៃច្បាប់ ឬវិធាននៃច្បាប់នោះឡើយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

២-ប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ ។

៣-ធ្វើមជ្ឈត្តវិនិច្ឆ័យស្របតាមសមធម៌ ឬ តាមការស្រុះស្រួលតែក្នុងករណីដែលភាគីវិវាទអនុញ្ញាតច្បាស់លាស់ឱ្យធ្វើដូច្នោះ ។

៤-ធ្វើមជ្ឈត្តវិនិច្ឆ័យឱ្យស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា និងត្រូវយកចិត្តទុកដាក់ផងដែរដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញនោះ ។

**មាត្រា ៣៧.–**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិ-កាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.–**

មុនពេលចាប់ផ្ដើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី ៖

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្ដើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេ-ទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈ-ត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្ដែងនៃវិវាទដែរ ។

**មាត្រា ៣៩.–**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទ្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម ៖

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែក វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ វៀរលែងតែ

**មាត្រា ៣៧.–**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.–**

មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី :

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្តើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្តែងនៃវិវាទដែរ ។

**មាត្រា ៣៩.–**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទម្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម :

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ លើកលែងណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែក វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ វៀរលែងតែ

មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួលរបស់ភាគី ដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

៣-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីសោហ៊ុយចំណាយក្នុងការធ្វើមជ្ឈត្តការ ដែលភាគីវិវាទមានចំណែកត្រូវចេញ ក្នុងនោះមានប្រាក់កម្រៃសម្រាប់មជ្ឈត្តករនិងការចំណាយផ្សេងៗ ដែលបានបម្រុងទុកជាមុន ដោយអនុលោមតាមបែបបទដែលព្រមព្រៀងដោយភាគីវិវាទ ឬ អនុលោមតាមការយល់សមស្របរបស់មជ្ឈត្តករ ប្រសិនបើគ្មានការព្រមព្រៀងដោយភាគីទេ ។ មជ្ឈត្តវិនិច្ឆ័យអាចចែងផងដែរពីសោហ៊ុយចំណាយសមស្របសម្រាប់ការពិគ្រោះច្បាប់ដែលត្រូវសងទៅឱ្យភាគីឈ្នះ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នោះ ឬ មជ្ឈត្តករយល់ថាសមស្រប ។

៤-មជ្ឈត្តវិនិច្ឆ័យត្រូវចែងពីកាលបរិច្ឆេទ និងទីកន្លែងផ្សះផ្សាដូចកំណត់ក្នុងមាត្រា ២៨ កថាខណ្ឌទី ១ នៃច្បាប់នេះ ។ ត្រូវចាត់ទុកទីកន្លែងធ្វើមជ្ឈត្តការជាទីកន្លែងធ្វើមជ្ឈត្ត-វិនិច្ឆ័យ ។

៥-បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួចហើយ អត្ថបទចម្លងនៃមជ្ឈត្តវិនិច្ឆ័យនោះ ដែលចុះហត្ថលេខាដោយមជ្ឈត្តករតាមបែបបទក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ជូនទៅឱ្យភាគីវិវាទនីមួយៗ ។

**មាត្រា ៤០.-**

ដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយធ្វើមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ ឬ ដោយដីកាបង្គាប់របស់វេទិកាមជ្ឈត្តកម្មស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។

វេទិកាមជ្ឈត្តកម្មចេញដីកាបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការ នៅក្នុងករណីដែល:

១-ភាគីប្ដឹងទាមទារដកពាក្យទាមទាររបស់ខ្លួន វៀរលែងតែភាគីឆ្លើយតបធ្វើការជំទាស់នឹងការដកពាក្យនោះ ហើយវេទិកាមជ្ឈត្តកម្មទទួលស្គាល់ពីអត្ថប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលដំណោះស្រាយវិវាទជាស្ថាពរ ។

២-ភាគីវិវាទឯកភាពឱ្យបញ្ចប់ដំណើរការមជ្ឈត្តការ ។

៣-វេទិកាមជ្ឈត្តកម្មរកឃើញមូលហេតុដទៃទៀត ដែលបញ្ជាក់ពីភាពមិនចាំបាច់សម្រាប់បន្តដំណើរការ ឬ ការធ្វើមជ្ឈត្តការនោះពុំអាចបន្តទៅទៀតកើត ។

អាណត្តិរបស់វេទិកាមជ្ឈត្តកម្មបញ្ចប់ជាមួយនឹងការបញ្ចប់ដំណើរការមជ្ឈត្តការតាមបទប្បញ្ញត្តិនៃមាត្រា ៤១ និងមាត្រា ៤២ កថាខណ្ឌទី ៤ នៃច្បាប់នេះ ។

**មាត្រា ៤១.–**

ការកែតម្រូវនិងការបកស្រាយមជ្ឈត្តវិនិច្ឆ័យត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម :

១-ក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលមជ្ឈត្តវិនិច្ឆ័យ វៀរលែងតែភាគីវិវាទបានព្រមព្រៀងលើរយៈពេលបន្តទៀត :

ក-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀតអាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មកែតម្រូវកំហុសផ្នែកគណនា កំហុសផ្នែកការងារលេខាធិការ និងកំហុសនៃការបោះពុម្ព ឬ កំហុសដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា ។

ខ-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មផ្តល់ការបកស្រាយ ឬ ការបំភ្លឺលម្អិតពីចំណុច ឬ ផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នេះ ។ ប្រសិនបើយល់ថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្មត្រូវបកស្រាយ ឬ បំភ្លឺលម្អិតក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ បន្ទាប់ពីទទួលសំណើ ។ ការបកស្រាយ ឬ ការបំភ្លឺលម្អិតនោះ ត្រូវបញ្ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ។

២-ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ក្រោយកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មអាចកែតម្រូវកំហុសដូចដែលចែងក្នុងកថាខណ្ឌទី ១ក នៃមាត្រានេះ ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ។

៣-វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ក្រោយពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជាដោយសារការទាមទារនានា ដែលលើកឡើងក្នុងដំណើរការមជ្ឈត្តការនោះ មិនបានដាក់ចូលទៅក្នុងមជ្ឈត្តវិនិច្ឆ័យ ។ ប្រសិនបើយល់ឃើញថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ។

៤-ប្រសិនបើចាំបាច់ និងដោយបានជូនដំណឹងដល់ភាគីវិវាទ វេទិកាមជ្ឈត្តកម្ម អាចពន្យាររយៈពេលដែលកំណត់សម្រាប់ការកែតម្រូវការបកស្រាយ ការបំភ្លឺលម្អិត ឬ ការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមតាមកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥-បទប្បញ្ញត្តិនានានៃមាត្រា ៣៩ នៃច្បាប់នេះ ត្រូវយកទៅអនុវត្តសម្រាប់កែតម្រូវការបកស្រាយ ឬ ការបំភ្លឺលម្អិតលើមជ្ឈត្តវិនិច្ឆ័យ ឬ ការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ។

# ជំពូកទី ៨
# ការប្តឹងជំទាស់ ការទទួលស្គាល់
# និង ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

## ផ្នែកទី១
## ស្ថាប័នមានសមត្ថកិច្ចក្នុងការប្តឹងជំទាស់
## ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៤២.-

សេចក្តីសម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៤៣.-

តុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងជំទាស់របស់ភាគីវិវាទ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥) ថ្ងៃ ។

## ផ្នែកទី ២
## បណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៤៤.-

ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទម្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោម ៖

១-បណ្តឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ អាចធ្វើទៅបានលុះត្រា តែស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ និងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ។

២-សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្ត-ករបានក្នុងករណី :

ក-ភាគីដែលដាក់ពាក្យសុំបដិសេធបានផ្តល់ភស្តុតាងគ្រប់គ្រាន់ថា :

ក.១-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា ៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ក.២-ភាគីដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការ ឬ ភាគីនេះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព ។

ក.៣-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើបញ្ហាដែលដាក់ឱ្យធ្វើមជ្ឈត្តការនោះ អាចផ្តាច់ចេញពីបញ្ហាដែលមិនបានដាក់ឱ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឱ្យធ្វើមជ្ឈត្តការពីមុនប៉ុណ្ណោះ ។

ក.៤-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ ពុំស្របនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការខាងលើមិនសមស្របតាមច្បាប់នេះ ។

ខ-សាលាឧទ្ធរណ៍ និង តុលាការកំពូលរកឃើញថា :

ខ.១- កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈ-ត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ខ.២-មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជា-ណាចក្រកម្ពុជា ។

៣-ការដាក់ពាក្យសុំបដិសេធមិនអាចធ្វើបានឡើយ បើរយៈពេលបានកន្លងផុតសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលភាគីសុំបដិសេធនោះទទួលបានមជ្ឈត្តវិនិច្ឆ័យ ឬ ប្រសិនបើសំណើនោះធ្វើឡើងតាមមាត្រា ៤១ នៃច្បាប់នេះ រយៈពេលសាមសិប (៣០) ថ្ងៃ គិតពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយលើសំណើនោះ ។

៤-នៅពេលទទួលដំណឹងបដិសេធមជ្ឈត្តវិនិច្ឆ័យ បើមានលក្ខណៈសមស្របហើយមានសំណើពីភាគីមួយ សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចផ្អាកដំណើរការបដិសេធនេះ នៅក្នុងរយៈពេលមួយដែលកំណត់ដោយសាលាឧទ្ធរណ៍ និង តុលាការកំពូល ដើម្បីផ្តល់ឱកាសដល់វេទិកាមជ្ឈត្តកម្មធ្វើដំណើរការមជ្ឈត្តការឡើងវិញ ឬ ចាត់វិធានការមួយតាមការយល់ឃើញរបស់វេទិកាថា អាចនឹងលុបបំបាត់មូលហេតុនៃការសុំបដិសេធនោះបាន ។

## ផ្នែកទី ៣
## ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៤៥.-

មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមក ត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រានេះ និងមាត្រា ៤៤ ។

ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬ ដែលដាក់ពាក្យសុំឱ្យមានការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ឬ អត្ថបទចតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬ កិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម ។

### មាត្រា ៤៦.-

ទោះបីជាមជ្ឈត្តវិនិច្ឆ័យធ្វើនៅប្រទេសណាក៏ដោយ ការជំទាស់ទៅនឹងការទទួលស្គាល់ ឬ ជំទាស់ទៅនឹងការដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ អាចធ្វើបានតែក្នុងករណី :

១-អនុវត្តន៍តាមសំណើរបស់ភាគីជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដោយភាគីនោះផ្តល់ភស្តុតាងដល់សាលាឧទ្ធរណ៍ថា :

ក-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចបានយោងក្នុងមាត្រា ៧ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងនោះពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមការកំណត់ណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ភាគីដែលជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ ពុំទទួលបានព័ត៌មានត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ

គ-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ ក៏បញ្ហាដែលបានសម្រេចនោះហួសពីក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើការសម្រេចលើបញ្ហាដែលបានដាក់ជូនឱ្យផ្សះផ្សា អាចផ្តាច់ចេញពីបញ្ហាដែលពុំបានដាក់ឱ្យផ្សះផ្សានោះ ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យលើបញ្ហាដែលបានដាក់ជូនអាចត្រូវគេទទួលស្គាល់ និងដាក់អោយអនុវត្ត ឬ

ឃ-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការពុំសមស្របជាមួយនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ ប្រសិនបើគ្មានកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ គឺពុំសមស្របទៅនឹងច្បាប់នៃប្រទេសដែលការផ្សះផ្សាបានប្រព្រឹត្តទៅ ឬ

ង-មជ្ឈត្តវិនិច្ឆ័យនោះពុំទាន់បានក្លាយទៅជាកាតព្វកិច្ចនៅឡើយសម្រាប់ភាគីវិវាទ បើយោងតាមច្បាប់នៃប្រទេសដែលធ្វើសេចក្តីសម្រេចនោះ ឬ ម្យ៉ាងទៀតមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ឬ ព្យួរទុក ដោយតុលាការនៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យ ឬ

២-ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថា :

ក-កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមការធ្វើមជ្ឈត្តការឡើយ បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យនោះ អាចផ្ទុយនឹងនយោបាយសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា ។

បើមានការសុំឱ្យសាលាឧទ្ធរណ៍បដិសេធ ឬ ព្យួរទុកមជ្ឈត្តវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ង) នៃមាត្រានេះ ហើយប្រសិនបើសាលាឧទ្ធរណ៍យល់ថាត្រឹមត្រូវ សាលាឧទ្ធរណ៍ដែលភាគីវិវាទស្នើសុំការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ អាចបញ្ឈប់ការសម្រេចរបស់ខ្លួន ហើយអាចបញ្ជាឱ្យភាគីវិវាទម្ខាងទៀតផ្តល់ការធានាសមស្របទៅតាមសំណូមពររបស់ភាគីដែលសុំឱ្យមានការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.–**

បទប្បញ្ញត្តិទាំងឡាយណាក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ។

ភ្នំពេញ,ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៦

**អនុប្រធានទី ១ រដ្ឋសភា**

**ហេង សំរិន**